ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស នៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តស្វាយរៀង

# COMMUNITY PARTICIPATION IN IMPROVING STUDENT LEARNING OUTCOMES IN HIGH SCHOOLS IN SVAY RIENG PROVINCE


**ផាន់ សំអាត**

**PHANN SAM ATH**


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៩ - ២០២១

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផល សិក្សារបស់សិស្ស នៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តស្វាយរៀង

# COMMUNITY PARTICIPATION IN IMPROVING STUDENT LEARNING OUTCOMES IN HIGH SCHOOLS IN SVAY RIENG PROVINCE

**ផាន់ សំអាត**

**PHANN SAM ATH**

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៩ - ២០២១

សាស្ត្រាចារ្យដឹកនាំ៖ លោកបណ្ឌិត នួន វីរ៉ា

សាស្ត្រាចារ្យដឹកនាំរង៖ លោក ចាន់ ធឿន

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**ការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស នៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀង**» សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំគឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុងហើយស្នាដៃនេះពុំទាន់ត្រូវបានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលបានសញ្ញាបត្រនៅសាកលវិទ្យាល័យ ឬនៅវិទ្យាស្ថាននានាដែលមានសញ្ញាបត្រ ស្មើឡើយ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារមួយណាដែលត្រូវបានប្រើប្រាស់នៅក្នុងការសរសេរអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះក្នុងបញ្ជីឯកសារយោងឡើយ។

និក្ខេបបទស្រាវជ្រាវខាងលើនេះ ពិតជាត្រូវបានស្រាវជ្រាវ និងចងក្រងឡើងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន។

ថ្ងៃ.........................ខែ.................ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ខែវិច្ឆិកា ឆ្នាំ២០២១

**ហត្ថលេខាបេក្ខជន**

**ផាន់ សំអាត**

# លិខិតបញ្ជាក់

លោកបណ្ឌិត **នួន ទីរ៉ា** ជាសាស្ត្រាចារ្យដឹកនាំ

លោក **ចាន់ ធឿន** ជាសាស្ត្រាចារ្យដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **ផាន់ សំអាត** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ ដែលមានចំណងជើងថា «**ការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀង**» ពិតប្រាកដមែន។

ថ្ងៃ.............................ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញថ្ងៃទី...............ខែវិច្ឆិកា ឆ្នាំ២០២១

| | |
|---|---|
| ...................................... | .................................... |
| **លោកបណ្ឌិត នួន ទីរ៉ា** | **លោក ចាន់ ធឿន** |
| នាយករង | មន្ត្រីដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ |
| វិទ្យាស្ថានជាតិអប់រំ | វិទ្យាស្ថានជាតិអប់រំ |

# លិខិតឧទ្ទេសនាម គណៈកម្មការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខៈ ៣៧០៥ អយក. ១ ០៥

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ១៤៣៤ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។

-បទប្បញ្ញត្តិស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ និងទី៩ ឆ្នាំសិក្សា២០២០-២០២១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៤-លោកបណ្ឌិត | ឈូក ច័ន្ទឆាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកស្រី | ប៊ិន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | សំអោ អង្គារតន៍ | អគ្គ.គផក | សមាជិក |
| ១១-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | សមាជិក |
| ១២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈាង សង្ហាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | កាង ស៊ីងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោក | ប៉ូ ប៊ុន្នន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | | |
|---|---|---|---|
| ២២-លោកស្រី | ខែក សំណាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥-លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៦-លោក | លន លីណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៧-លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៩-ល.ស | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៨-លោក | ជាង ចាន់ណាក់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣០-លោក | អ៊ុច ផលរដ្ឋ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ពុធ ៦ កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

"ដើម្បីជ្រាបជាព័ត៌មាន"

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ

"ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ -ឯកសារ រដអ

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ផាន់ សំអាត** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ នៃវិទ្យាស្ថានជាតិអប់រំ ឆ្នាំសិក្សា២០១៩-២០២១ ពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានបញ្ចប់ការស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដោយជោគជ័យ។ ជាមួយលទ្ធផលដ៏ត្រចះត្រចង់នេះ ខ្ញុំបាទក៏មិនភ្លេចផងដែរ ចំពោះការជួយជ្រោមជ្រែង គាំទ្រ និងយកចិត្តទុកដាក់ពីមជ្ឈដ្ឋានជុំវិញជាច្រើន។ ខ្ញុំបាទសូម គោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- លោកអ្នកមានគុណទាំងពីរគឺលោកឪពុក ផាន់ សី និងអ្នកម្តាយ ស្វាយ សុផាត ដែលបានផ្តល់កំណើត ផ្តល់ដំបូន្មានល្អៗ ខិតខំចិញ្ចឹមបីបាច់ថែរក្សា និងតស៊ូផ្គត់ផ្គង់ឱ្យកូនបានសិក្សា រហូតទទួលបានផ្លែផ្កាដូចសព្វថ្ងៃនេះ។
- **លោកបណ្ឌិត នូវ វីរ៉ា** ដែលជាគ្រូដឹកនាំបង្គោល ដែលតែងតែចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីពន្យល់ ណែនាំ និងផ្តល់អនុសាសន៍ល្អៗ ដល់រូបខ្ញុំតាំងពីដើមរហូតមក ទើបធ្វើឱ្យការសិក្សាស្រាវជ្រាវរបស់ខ្ញុំបាទបានទទួលជោគជ័យនៅពេលនេះ។
- **លោក ចាន់ ធឿន** ដែលជាគ្រូដឹកនាំរង ដែលតែងតែឆ្លៀតពេលវេលាដ៏មានតម្លៃ ក្នុងការផ្តល់ជា អនុសាសន៍ល្អៗ កែសម្រួលពាក្យពេជន៍ ឃ្លា ប្រយោគ អក្ខរាវិរុទ្ធ និងរបៀបសរសេរនិក្ខេបបទ ព្រមទាំង របៀបវិភាគទិន្នន័យ។
- គណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោក លោកស្រី សាស្ត្រាចារ្យទាំងអស់ដែលបានខិតខំចំណាយពេលវេលាដ៏មានតម្លៃ មកបង្ហាត់បង្រៀននិងពន្យល់គ្រប់មេរៀនដល់ខ្ញុំបាទ ព្រមទាំងនិស្សិតទាំងអស់គ្នាដោយមិនគិតពីការលំបាកហត់នឿយ។
- លោកគ្រូ អ្នកគ្រូដែលបានបង្រៀនខ្ញុំបាទចាប់តាំងពីបឋមសិក្សារហូតបរិញ្ញាបត្រជាន់ខ្ពស់។
- មិត្តភក្តិទាំងអស់ ក៏ដូចជាមិត្តរួមថ្នាក់ជំនាន់ទី៨ ទាំងអស់ដែលតែងផ្តល់កម្លាំងចិត្តនិង ចែករំលែក

ឯកសារ ចំណេះដឹង បទពិសោធន៍ និងព័ត៌មានល្អៗដល់រូបខ្ញុំ។

- គណៈនាយកទាំង១០វិទ្យាល័យ លោកគ្រូ អ្នកគ្រូ មាតាបិតាសិស្ស អាជ្ញាធរមូលដ្ឋាន និងសិស្សានុសិស្ស នៃសាលាគោលដៅទាំងអស់ ដែលបានជួយបំពេញកម្រងសំណួរខ្ញុំបាទ។

ជាទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធិពរជ័យ សិរិមង្គល គោរពជូនចំពោះលោកឪពុក អ្នកម្តាយ ឯកឧត្តម សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ បងប្អូន និងមិត្តភក្តិទាំងអស់សូមជួបប្រទះតែ សេចក្តីសុខ សេចក្តីចម្រើន គ្រប់ប្រការ មានសុខភាពមាំមួន សម្រេចបានជោគជ័យគ្រប់ភារកិច្ច និងទទួលបាននូវ ពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**

# មាតិកា


**សេចក្តីអះអាងរបស់បេក្ខជន** ..... i

**លិខិតបញ្ជាក់** ..... ii

**លិខិតឧទ្ទេសនាម គណៈកម្មការការពារនិក្ខេបបទ** ..... iii

**សេចក្តីថ្លែងអំណរគុណ** ..... v

**បញ្ជីតារាង** ..... x

**បញ្ជីក្រាប** ..... xii

**មូលន័យសង្ខេប** ..... xiii

Abstract ..... xv

**ជំពូក១៖ សេចក្តីផ្តើម** ..... 1

១.១. លំនាំបញ្ហានៃការស្រាវជ្រាវ ..... 1

១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ ..... 6

១.៣. គោលបំណងនៃការស្រាវជ្រាវ ..... 8

១.៤. សំណួរស្រាវជ្រាវ ..... 9

១.៥. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ..... 9

១.៦. សារៈសំខាន់នៃការស្រាវជ្រាវ ..... 9

១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... 10

**ជំពូក២៖ រំលឹកទ្រឹស្តី** ..... 12

២.១. ពាក្យគន្លឹះ ..... 13

២.២. ទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ ..... 14

២.៣. សារៈសំខាន់នៃគ្រួសារ និងសហគមន៍ ..... 15

២.៤. សារៈសំខាន់នៃទំនាក់ទំនងសាលារៀន និងសហគមន៍ ..... 17

២.៥. តួនាទី និងភារកិច្ចរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀន ....................................... 20
២.៦. ឥទ្ធិពលវិជ្ជមានរបស់មាតាបិតាលើការចូលរួមក្នុងការអប់រំកូន ....................................... 24
២.៧. បញ្ហាប្រឈមនៃការចូលរួមរបស់សហគមន៍ និងតួនាទីរបស់សាលារៀន ....................................... 25
២.៨. យុទ្ធវិធីដើម្បីទាក់ទាញសហគមន៍ឱ្យចូលរួមអភិវឌ្ឍសាលារៀន ....................................... 27
២.៨.១.យុទ្ធវិធីដើម្បីទាក់ទាញសហគមន៍ឱ្យចូលរួមក្នុងការអភិវឌ្ឍសាលារៀន ....................................... 27
២.៨.២. យុទ្ធវិធីដើម្បីទាក់ទាញសហគមន៍ឱ្យចូលរួមអភិវឌ្ឍសាលារៀន ....................................... 30
**ជំពូក៣៖ វិធីសាស្ត្រស្រាវជ្រាវ** ....................................... 32
៣.១. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ....................................... 32
៣.២. ការជ្រើសរើសភាគសំណាក ....................................... 32
៣.៣. ឧបករណ៍ស្រាវជ្រាវ ....................................... 35
៣.៣.១. កម្រងសំណួរសម្រាប់សិស្ស ....................................... 35
៣.៣.២. កម្រងសំណួរសម្រាប់លោកគ្រូ អ្នកគ្រូ ....................................... 36
៣.៣.៣. កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង ....................................... 37
៣.៣.៤. កម្រងសំណួរសម្រាប់មាតាបិតាសិស្ស/អាណាព្យាបាលសិស្ស ....................................... 38
៣.៣.៥. កម្រងសំណួរសម្រាប់អាជ្ញាធរ ....................................... 39
៣.៤. ដំណើរការនៃការប្រមូលទិន្នន័យ ....................................... 40
៣.៥. ការវិភាគទិន្នន័យ ....................................... 41
៣.៦. កម្រិតចង្អុលបង្ហាញ ....................................... 42
៣.៧. ក្រមសីលធម៌នៃការស្រាវជ្រាវ ....................................... 43
**ជំពូក៤៖ លទ្ធផល និងការពិភាក្សា** ....................................... 44
៤.១. ឧបករណ៍វិភាគទិន្នន័យ ....................................... 44
៤.២. ដំណាក់កាលនៃការវិភាគទិន្នន័យ ....................................... 44

៤.៣. លទ្ធផលនៃការវិភាគទិន្នន័យ ....................................................................................45
៤.៣.១. ការវិភាគទិន្នន័យលើកម្រងសំណួរគណៈគ្រប់គ្រងសាលា ..................................45
៤.៣.២. ការវិភាគទិន្នន័យលើកម្រងសំណួរសម្រាប់លោកគ្រូ អ្នកគ្រូ................................55
៤.៣.៣. ការវិភាគទិន្នន័យលើកម្រងសម្រាប់សិស្ស ......................................................62
៤.៣.៤. ការវិភាគទិន្នន័យលើកម្រងសំណួរមាតាបិតា/អាណាព្យាបាលសិស្ស .................... 71
៤.៣.៥. ការវិភាគទិន្នន័យលើកម្រងសម្រាប់អាជ្ញាធរដែនដី............................................80
សំយោគទិន្នន័យលទ្ធផលតាមកម្រងសំណួរដែលបានរកឃើញ.............................................89
៤.៤. ការពិភាក្សាចំពោះលទ្ធផល............................................................................................93
**ជំពូក៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ**.........................................................................97
៥.១. សេចក្តីសន្និដ្ឋាន .........................................................................................................97
៥.២. សំណូមពរ ................................................................................................................100
៥.៣. អនុសាសន៍សម្រាប់ការសិក្សាស្រាវជ្រាវបន្ត...............................................................102
ឯកសារយោង ...................................................................................................................103
ឧបសម្ព័ន្ធ «ក» កម្រងសំណួរ...........................................................................................105
ឧបសម្ព័ន្ធ «ខ» លិខិតឧទ្ទេសនាម និងឯកសារពាក់ព័ន្ធ .....................................................126

# បញ្ជីតារាង


តារាង 1 ៖ ឈ្មោះវិទ្យាល័យក្នុងខេត្តស្វាយរៀង ....................................................... 32

តារាង 2 ៖ ការជ្រើសរើសសំណាក ....................................................... 34

តារាង 3 ៖ ព័ត៌មានទូទៅគណៈគ្រប់គ្រង ....................................................... 45

តារាង 4 ៖ ការគ្រប់គ្រងផ្នែករដ្ឋបាល ....................................................... 47

តារាង 5 ៖ ការគ្រប់គ្រងផ្នែកបច្ចេកទេស ....................................................... 48

តារាង 6 ៖ ការគ្រប់គ្រងផ្នែកថវិកា ....................................................... 50

តារាង 7 ៖ ការគ្រប់គ្រងផ្នែកបុគ្គលិក ....................................................... 52

តារាង 8 ៖ ការទំនាក់ទំនងរបស់នាយកសាលា ....................................................... 53

តារាង 9 ៖ ការចូលរួមរបស់នាយកសាលាក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស .................. 54

តារាង 10 ៖ ព័ត៌មានទូទៅរបស់លោកគ្រូ អ្នកគ្រូ ....................................................... 55

តារាង 11 ៖ ការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ ....................................................... 57

តារាង 12 ៖ ការលើកទឹកចិត្តរបស់គ្រូ ចំពោះសិស្ស ....................................................... 58

តារាង 13 ៖ ការទំនាក់ទំនងរបស់លោកគ្រូ អ្នកគ្រូ ....................................................... 59

តារាង 14 ៖ ការចូលរួមរបស់លោកគ្រូ អ្នកគ្រូក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស .............. 60

តារាង 15 ៖ បញ្ហាប្រឈមរបស់លោកគ្រូ អ្នកគ្រូ ....................................................... 61

តារាង 16 ៖ ព័ត៌មានទូទៅរបស់សិស្ស ....................................................... 62

តារាង 17 ៖ ការសិក្សាផ្ទាល់ខ្លួនរបស់សិស្ស ....................................................... 65

តារាង 18 ៖ កត្តាខាងក្រៅ (ការលើកទឹកចិត្តរបស់គ្រូ) ....................................................... 66

តារាង 19 ៖ កត្តាខាងក្រៅ(ការលើកទឹកចិត្តរបស់មាតាបិតា និងបងប្អូន មិត្តភក្តិ) ......................... 67

តារាង 20 ៖ ការទំនាក់ទំនរបស់សិស្ស ....................................................... 68

តារាង 21 ៖ សរុបមកការខិតខំរៀនរបស់សិស្សដើម្បីទទួលបានលទ្ធផលល្អ ................................ 69

តារាង 22 ៖ ព័ត៌មានទូទៅរបស់មាតាបិតាសិស្ស ..................................................................71

តារាង 23 ៖ មាតាបិតាតាមដានការសិក្សាកូន ..................................................................73

តារាង 24 ៖ ការផ្តល់ថវិកា និងការលើកទឹកចិត្តកូនរបស់មាតាបិតា ..................................................................75

តារាង 25 ៖ ការទំនាក់ទំនងរបស់មាតាបិតា ..................................................................76

តារាង 26 ៖ ការចូលរួមរបស់មាតាបិតាក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ......................78

តារាង 27 ៖ ព័ត៌មានទូទៅរបស់អាជ្ញាធរ ..................................................................80

តារាង 28 ៖ ការចូលរួមធ្វើផែនការអភិវឌ្ឍសាលារបស់អាជ្ញាធរដែនដី គណៈកម្មការទ្រទ្រង់សាលា .....82

តារាង 29 ៖ ការកៀរគរកម្មវិធីអប់រំផ្សេងៗរបស់អាជ្ញាធរ/គណៈកម្មការទ្រទ្រង់សាលា .......................84

តារាង 30 ៖ ទំនាក់ទំនងរបស់អាជ្ញាធរ/គណៈកម្មការទ្រទ្រង់សាលា ..............................................85

តារាង 31៖ ការចូលរួមរបស់អាជ្ញាធរក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ..........................86

តារាង 32 ៖ ការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស .....................88

តារាង 33 ៖ សង្ខេបទិន្នន័យ ..................................................................89

# បញ្ជីក្រាប

ក្រាប 2 ៖ បញ្ហាប្រឈមរបស់សិស្ស ....................................................................................70

ក្រាប 3 ៖ បញ្ហាប្រឈមរបស់មាតាបិតាសិស្សមិនសូវបានចូលរួមក្នុងការសិក្សារបស់កូន ...................79

ក្រាប 4 ៖ បញ្ហាប្រឈមរបស់អាជ្ញាធរដែលមិនសូវបានចូលរួមក្នុងការសិក្សារបស់សិស្ស....................88

# មូលន័យសង្ខេប

សាលារៀន សហគមន៍ និងសង្គម ត្រូវមានទំនាក់ទំនងគ្នាពុំអាចកាត់ផ្តាច់ពីគ្នាបានឡើយ ពីព្រោះថាសហគមន៍ និងសង្គមមិនអាចរីកចម្រើនបានដោយគ្មានការចូលរួមពីសាលារៀនបានឡើយ ហើយសាលារៀនក៏មិនអាចអភិវឌ្ឍទៅបានដោយខ្វះការចូលរួមពីសហគមន៍ និងសង្គមបានដែរ។ ម្យ៉ាងទៀតលទ្ធផលសិក្សារបស់សិស្សចំណុះឱ្យកត្តាធំៗចំនួន៤គឺ នាយកល្អ គ្រូល្អ សិស្សល្អ និង មាតាបិតា និងសហគមន៍ល្អ។ លើសពីនោះទៀតដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាពក្នុងការអប់រំ គឺចាំបាច់ត្រូវតែមានការចូលរួមពីគ្រប់ភាគីជាពិសេសខាងសាលារៀន មាតាបិតា និងសហគមន៍។ ជាកាពិតណាស់ការចូលរួមរបស់សហគមន៍ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ចំពោះលទ្ធផលសិក្សារបស់សិស្ស ដែលធ្វើឱ្យសិស្សទទួលបានលទ្ធផលល្អ ប្រឡងជាប់បានច្រើនជាដើម។ ប៉ុន្តែការចូលរួមរបស់ពួកគាត់ហាក់ដូចជាមិនទាន់គ្រប់គ្រាន់នៅឡើយ ដោយសារមូលហេតុផ្សេងៗ។

ការសិក្សាស្រាវជ្រាវពីការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀង មានគោលបំណងពីរគឺ៖ (១)សិក្សាពីកម្រិតនៃការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស នៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀង។ (២)សិក្សាពីបញ្ហាប្រឈមដែលនាំឱ្យសហគមន៍មិនសូវបានចូលរួមសកម្មភាពជាមួយសាលារៀនក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស(កូន)។

វិធីសាស្ត្រស្រាវជ្រាវគឺអនុវត្តតាមបែបបរិមាណវិស័យ។ ភាគសំណាកក្នុងការសិក្សាស្រាវជ្រាវនេះគឺមានចំនួន១០វិទ្យាល័យ ដែលស្ថិតនៅក្នុងស្រុក/ក្រុងចំនួន០៥ ក្នុងខេត្តស្វាយរៀង។ ភាគសំណាកទាំងអស់មានដូចជា៖ គណៈគ្រប់គ្រងសាលា(នាយក)២០នាក់ លោកគ្រូ អ្នកគ្រូ១០០នាក់ សិស្សានុសិស្សចំនួន៤០០នាក់ និងសហគមន៍(មាតាបិតា១០០នាក់ និងអាជ្ញាធរដែនដី២០នាក់)បានជ្រើសរើសចេញពីវិទ្យាល័យទាំង១០ និងសហគមន៍ ដែលនៅក្នុងក្រុង/ស្រុកចំនួន០៥នៃខេត្តស្វាយរៀង។ ឧបករណ៍ដែលប្រើប្រាស់សម្រាប់ការស្រាវជ្រាវនេះគឺកម្រងសំណួរ។ កម្រងសំណួរត្រូវបានរៀបចំជា៥ប្រភេទគឺ កម្រង

សំណួរសម្រាប់គណៈគ្រប់គ្រងសាលា(នាយក/នាយករង) លោកគ្រូ អ្នកគ្រូ សិស្ស និងសហគមន៍(មាតាបិតាសិស្ស និងអាជ្ញាធរ)។ ទិន្នន័យដែលប្រមូលបាន ត្រូវបានវិភាគតាមកម្មវិធី Microsot Excel ដោយរកចំនួនភាគរយ (%) តម្លៃមធ្យម (Mean) គម្លាតស្តង់ដា (S.D) កម្រិត និងលំដាប់។

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះបានបង្ហាញថា៖

(១)ការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស នៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀង គឺស្ថិតនៅក្នុងកម្រិតមធ្យម ដែលមានតម្លៃមធ្យម(Mean)=3.34 ហើយគម្លាតស្តង់ដា(SD)=0.21។ ការចូលរួមរបស់សហគមន៍នេះដោយផ្អែកទៅលើផ្នែកធំៗចំនួនពីរ(២)ដែលតំណាងឱ្យសហគមន៍ គឺការចូលរួមរបស់មាតាបិតាសិស្ស និងការចូលរួមរបស់អាជ្ញាធរ ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។ ការចូលរួមរបស់មាតាបិតាក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស គឺស្ថិតនៅកម្រិតមធ្យម ដែលមានតម្លៃមធ្យម (Mean)=3.49។ ចំណែកឯការចូលរួមរបស់អាជ្ញាធរក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ក៏ស្ថិតនៅកម្រិតមធ្យម ដែលមានតម្លៃជាមធ្យម (Mean)=3.19។

(២)មានបញ្ហាប្រឈម ជាច្រើនដែលធ្វើឱ្យសហគមន៍ (មាតាបិតា និងអាជ្ញាធរ) មិនសូវបានចូលរួមក្នុងការលើកកម្ពស់លទ្ធផល សិក្សារបស់សិស្ស។ បញ្ហាទាំងនោះមានដូចជា៖ (១) គ្រួសារមានជីវភាពខ្វះខាត (២) រវល់ធ្វើការ និងរកស៊ី (៣) មាតាបិតាសិស្សខ្លះគិតថាឱ្យកូនទៅរៀននៅសាលាគឺគ្រប់គ្រាន់ហើយ (៤) គ្មានជំនាញក្នុងការអប់រំ (៥) មាតាបិតាសិស្សខ្លះមានចំណេះដឹងទាប។

សរុបមកការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស នៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀង **ស្ថិតនៅកម្រិតមធ្យម**។ ការចូលរួមរបស់សហគមន៍ស្ថិតនៅកម្រិតមធ្យមនេះដែរ ដោយសារមានបញ្ហាប្រឈមមួយចំនួនដូចជា៖ គ្រួសារមានជីវភាពខ្វះខាត រវល់ធ្វើការ និងរកស៊ី មាតាបិតាសិស្សខ្លះគិតថាឱ្យកូនទៅរៀននៅសាលាគឺគ្រប់គ្រាន់ហើយ គ្មានជំនាញនិងវិធីសាស្ត្រក្នុងការអប់រំកូន និងមាតាបិតាសិស្សខ្លះមានចំណេះដឹងទាបជាដើម។

# Abstract

Schools, communities and societies must be inextricably linked because communities and societies cannot thrive without the participation of schools, and schools cannot be developed without the participation of communities and society. On the other hand, students' learning outcomes depended on four major factors: good principals, good teachers, good students, and good parents and communities. In addition, in order to improve the quality and effectiveness of education, it is necessary to involve all parties, especially schools, parents and the community. Of course, community participation is very important for students' academic achievement, which enables students to get good results, pass exams, and so on. But their involvement does not seem to be enough for various reasons.

The study on community participation in improving the academic performance of high school students in Svay Rieng province had two objectives: (1) to study the level of community participation in improving the academic achievement of high school students in Svay Rieng province. (2) to learn about the challenges that lead the community to become less involved in school activities to improve student learning outcomes.

Research method was quantitative by sector. The study sample consisted of 10 high schools located in 5 districts / towns in Svay Rieng province. The sample consisted of: 20 school administrators (principals), 100 teachers, 400 students and communities (100 parents and 20 jurors) in 10 high schools in 05 towns / districts in the province. Svay Rieng. The instrument used for this research was a questionnaire. The questionnaire was organized into 5 questionnaires for school administrators (principal), teachers, students and the community (parents, students and authorities). The data collected were analyzed statistically, such as percentage (%), mean, standard deviation (S.D) and rank.

The results of this study was shown that:

(1) Community participation in improving the academic performance of high school students in Svay Rieng was within the mean range (Mean) = 3.34 and the standard deviation (SD) = 0.21. Community involvement was based on two major sections that represented the community: parental involvement and the authority of the authorities to improve student achievement. Parental involvement in improving student learning outcomes was at an average level of Mean = 3.49. The involvement of the authorities in improving student achievement was at an average value of 3.19.

(2) There were many challenges that make the community (parents and authorities) less involved in improving student learning outcomes. These problems included: (1) poor families (2)

busy working and business (3) some parents think that sending their children to school was enough (4) lack of education skills (5) parents some had low knowledge.

Community involvement in improving the outcomes of high school students in Svay Rieng was moderate. Community participation was also at a moderate level due to a number of challenges, such as: Poor families, busy working and business, some parents think that sending their children to school was not enough and didn’t have the skills and methods to educate their children and parents. Some had low knowledge and so on.

# ជំពូក១

# សេចក្តីផ្តើម

## ១.១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅលើពិភពលោករបស់យើងនេះប្រទេសណាក៏ដោយ សាលារៀន សហគមន៍ និងសង្គម ត្រូវមានទំនាក់ទំនងគ្នាពុំអាចកាត់ផ្តាច់ពីគ្នាបានឡើយ។សាលារៀនពុំអាចអភិវឌ្ឍបានដោយគ្មានការចូលរួមពីសហគមន៍ និងសង្គមបានឡើយ។ ផ្ទុយទៅវិញ សហគមន៍ និងសង្គមក៏ពុំអាចគង់វង្ស រីកចម្រើន និងអភិវឌ្ឍបានដោយខ្វះការចូលរួមពីសាលារៀនបានដែរ។ ម្យ៉ាងទៀតនៅក្នុងពិភពលោករបស់យើងនេះចំណេះដឹងគឺជាអំណាច ហើយការអប់រំបានផ្តល់នូវសិទ្ធិអំណាច។ ដើម្បីទទួលបានចំណេះដឹង មនុស្សគ្រប់រូប ត្រូវតែសិក្សារៀនសូត្រ និងទទួលយកការបណ្តុះបណ្តាលនៅតាមសាលារៀន។

ក្នុងសតវត្សទី២១នេះ នៅលើសាកលលោកបានផ្តោត និងយកទុកចិត្តដាក់យ៉ាងខ្លាំងទៅលើវិស័យអប់រំ ដោយបានកំណត់គោលនយោបាយរួមគ្នាមួយ ក្នុងឱកាសសន្និសិទ្ធនៅទីក្រុងអ៊ីនឈុន (Incheon) សាធារណៈរដ្ឋកូរ៉េ ចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ គឺ «ការអប់រំប្រកបដោយចីរភាព និងធានាការអប់រំប្រកបដោយគុណភាព សមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសនៃការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា»(សេចក្តីប្រកាសទីក្រុងអ៊ីនឈុន(Incheon)2015)[1]។ប្រទេសដែលចូលរួមមាន១៦០ប្រទេស ដែលជាភាគីហត្ថលេខីបាននឹងកំពុងធ្វើកំណែទម្រង់លើវិស័យអប់រំរបស់ខ្លួនទៅតាមបម្រែបម្រួលនៃសង្គម សេដ្ឋកិច្ច នយោបាយ វប្បធម៌ និងគោលដៅអប់រំនៃបរិបទប្រទេសរៀងៗខ្លួន។ ការអប់រំវាក៏ពាក់ព័ន្ធនឹងការគ្រប់គ្រងរបស់នាយក វិធីសាស្ត្របង្រៀន សកម្មភាពបង្រៀនរបស់គ្រូ ដែលតែងតែប្រែប្រួលទៅតាមសកលភាវូបនីយកម្មរីកចម្រើនជឿនលឿន និងនិន្នាការពិភពលោកនៃការបង្រៀន និងរៀន ហើយប្រែប្រួលតាមលក្ខណៈវិទ្យាសាស្ត្រ។ ការអប់រំបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍ ធនធានមនុស្សនិងជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ មួយវិញទៀតការអប់រំមានសារៈ

[1] វិស័យអប់រំឆ្នាំ២០៣០ សេចក្តីប្រកាសទីក្រុងអ៊ីនឈុន(Incheon )ទំព័រ ៣

សំខាន់ណាស់ សម្រាប់មនុស្សគ្រប់រូបដើម្បីជាប្រទីបបំភ្លឺផ្លូវដល់ជនគ្រប់រូប។ គ្រប់ប្រទេសទាំងអស់បានផ្តោតការយក ចិត្តទុកដាក់លើការអប់រំកុមារ និងយុវជននៅគ្រប់កម្រិតភូមិសិក្សាព្រោះថាកុមារ និងយុវជនគឺជាទំពាំងស្នងឫស្សី និងជាធនធានមនុស្សប្រកបដោយសក្តានុភាពនាពេលអនាគតក្នុងការអភិវឌ្ឍសហគមន៍ក៏ដូចជាប្រទេសជាតិនីមួយៗឱ្យទទួលបាននូវភាពជោគជ័យ រីកចម្រើនលើគ្រប់វិស័យ។ ការអប់រំនេះហើយគឺជា មូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម វប្បធម៌ និងជានាំឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកប ដោយចីរភាព(សុខ ផល្លា2018)[2]។ តាមរយៈការអប់រំមនុស្សគ្រប់រូបនឹងទទួលបាននូវចំណេះដឹង ជំនាញ របៀបរស់នៅជាមួយមនុស្សដូចគ្នា ប្រកបដោយភាពសុខដុមរមនា ចេះដោះស្រាយបញ្ហានានាដែលបានកើតមានលើជីវភាពរស់នៅប្រចាំថ្ងៃ និងការរៀបចំផែនការជីវិតសម្រាប់ខ្លួនឯងបានល្អគ្រប់ៗគ្នា។ ប្រទេសជាតិនីមួយៗ បាននឹងកំពុងរិះរកគ្រប់មធ្យោបាយក្នុងការបណ្តុះបណ្តាលធនធានមនុស្សឱ្យមាន ចំណេះដឹង ជំនាញ និងឥរិយាបថ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ទីផ្សារការងារ និងសង្គមជាតិ (រ៉ុតសោភ័ណ្ឌ 2020)[3]។

ចំណែកឯនៅប្រទេសកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាដែលមានក្រសួងអប់រំ យុវជន និងកីឡា ជាសេនាធិការទទួលបន្ទុកលើផ្នែកបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា នោះបានកំណត់នូវចក្ខុវិស័យរបស់ខ្លួនគឺកសាង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយ គុណភាព និងគុណធម៌ ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើន ផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។ ការកំណត់ចក្ខុវិស័យនេះឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍដែលបានកំណត់តាំងពីឆ្នាំ២០០៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិឆ្នាំ២០១៤-២០១៨ នេះបានរៀបចំឡើងដើម្បីអនុវត្តនូវរបៀបវារៈ គោលនយោបាយដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដែលត្រូវផ្សព្វផ្សាយនៅខែកញ្ញា ឆ្នាំ២០១៣។ ហើយមុំមួយក្នុងចំណោមមុំទាំង

---

[2] និក្ខេបបទ សុខ ផល្លា ស្ថានភាពនៃការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំក្នុងខេត្តឧត្តមមានជ័យ2018 ទំព័រទី9

[3] និក្ខេបបទ រ៉ុត សោភ័ណ្ឌ កត្តាដែលនាំឱ្យសិស្សជ្រើសរើសមុខវិជ្ជាវិទ្យាសាស្ត្រសង្គមនៅមធ្យមសិក្សាទុតិយភូមិករណីសិក្សាក្នុងខេត្តស្វាយរៀង2020 ទំព័រទី2

បួននៃយុទ្ធសាស្ត្រនោះបានលើកឡើងអំពី «ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស» គឺសំដៅទៅលើការពង្រឹងគុណភាពលើវិស័យអប់រំ។ ដើម្បីសម្រេចមុំនេះក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវគោលនយោបាយអប់រំសំខាន់ៗបីគឺៈ

១-គោលនយោបាយទី១ៈ ធានាលទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌

២-គោលនយោបាយទី២ៈ លើកកម្ពស់គុណភាព និងភាពឆ្លើយតប

៣-គោលនយោបាយទី៣ៈ ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ (ក្រសួងអប់រំ យុវជន និងកីឡា)[4]។ ប៉ុន្តែក្រោយមកគោលនយោបាយអប់រំទាំង៣នេះត្រូវបានបង្រួមមកសល់តែ២វិញ ដោយក្រសួងបានកំណត់ គោលនយោបាយអប់រំទី១) ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និងទី២) ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ (ក្រសួងអប់រំយុវជននិងកីឡា2019)។ វិស័យអប់រំជាវិស័យអាទិភាពមួយ ក្នុងចំណោមវិស័យ អាទិភាពទាំងឡាយដែលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានកំពុងយកចិត្តទុកដាក់ ដើម្បីលើកកម្ពស់ការអប់រំឱ្យកាន់តែល្អប្រសើរឡើង។

ដើម្បីឆ្លើយតបនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល ដោយបានចាត់ទុកការអភិវឌ្ឍធនធានមនុស្សជាអាទិភាពទី១ ក្រសួងអប់រំ យុវជន និងកីឡា ប្តេជ្ញាសម្រេចឱ្យបាននូវមុំទី១ស្តីពី «ការពង្រឹងគុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា» ផ្តោតអាទិភាពលើ (១) ការយកចិត្តទុកដាក់លើគ្រូបង្រៀន (២) ការពង្រីកវិសាលភាពសាលារៀនគ្រប់កម្រិត (៣) ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលារៀន (៤) ការជំរុញការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ (៥) ការអប់រំបំណិនឱ្យស្របតាមទីផ្សារការងារ (៦) ការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលគ្រប់ជ្រុងជ្រោយ និង(៧) ការត្រៀមប្រកួតកីឡាស៊ីហ្គេមឆ្នាំ២០២៣។

ដំណាក់កាលបន្ទាប់ឆ្នាំ២០១៩-២០២៣ និងឆ្ពោះទៅឆ្នាំ២០៣០ ក្រសួងអប់រំ យុវជន និងកីឡា

[4] ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៤-២០១៨ ទំព័រ ១៦-១៧

ប្តេជ្ញាសម្រេចឱ្យបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ស្តីពីការអប់រំ ដោយឈរលើគោលការណ៍ គុណភាព សមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ម្យ៉ាងទៀត ក្រសួងបន្ត កាត់បន្ថយគម្លាតជំនាញដោយសហការជាមួយអ្នកពាក់ព័ន្ធ ក្នុងការបង្កើនការផ្គត់ផ្គង់ជំនាញដែលមាន តម្រូវការខ្ពស់ក្នុងវិស័យអាទិភាពមួយចំនួនដោយដាក់ចេញនូវការអប់រំតាមបែបឌីជីថលដើម្បីឆ្លើយតបទៅ នឹងគោលនយោបាយ និងទិសដៅនៃសេដ្ឋកិច្ចឌីជីថលកម្ពុជា (ក្រសួងអប់រំ យុវជន និងកីឡា 2019)[5]។

ចំពោះគោលដៅអប់រំចំណោះទូទៅដែលទ្រទ្រង់ឱ្យចក្ខុវិស័យអប់រំនេះ គឺមានគោលដៅអប់រំ សិស្ស ឱ្យក្លាយជាមនុស្សពេញលេញ (វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា) ជាពលរដ្ឋថ្លៃថ្នូរ ពលរដ្ឋ ល្អ នៅក្នុងសង្គមជាតិ។

មួយវិញទៀតដើម្បីទទួលបានជោគជ័យ ក្នុងការកសាងធនធានមនុស្ស សម្រាប់បំពេញតម្រូវការ ទីផ្សារការងារ សាលារៀនតែឯងពិតជាមិនអាចធ្វើឱ្យសម្រេចបានទេ វាទាមទារដាច់ខាតមានការចូលរួម យ៉ាងខ្លាំងក្លាពីគ្រប់មជ្ឈដ្ឋានដែលពាក់ព័ន្ធ ជាពិសេសគណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ អាជ្ញាធរ ដែនដី សហគមន៍ មាតាបិតាសិស្ស គណៈកម្មការទ្រទ្រង់សាលា និងសិស្សានុសិស្ស។ ក្នុងការពង្រឹង និង ពង្រីកទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ជាសកម្មភាពដ៏សំខាន់ពុំអាចខ្វះបានឡើយ សម្រាប់ការ ចូលរួមលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។

សាលារៀនចំណោះទូទៅជាថ្នាលបណ្តុះបណ្តាល ដែលមានតួនាទីអប់រំកុមារ និងយុវជនទូទៅ គ្រប់ផ្នែក ប៉ុន្តែមិនមែនជាកន្លែងតែមួយគត់ ដែលអាចធានាបានទាំងស្រុងថា បានពេញលេញ គ្រប់គ្រាន់ សម្រាប់ការអប់រំនោះទេ ពីព្រោះរៀងរាល់ថ្ងៃកុមារ យុវជន បានមកសាលារៀនសូត្រ និងរស់នៅក្នុងសាលា រៀនតែរយៈពេលមួយកំណត់ច្បាស់លាស់ប៉ុណ្ណោះ។ បើនៅបឋមសិក្សារៀនមួយពេលបួនម៉ោង ហើយនៅ មធ្យមសិក្សា៧ម៉ោងក្នុងមួយថ្ងៃ។ចំណែកឯពេលវេលាដែលនៅសល់មួយភាគធំលើសលប់គឺគេនៅជាមួយ គ្រួសារ និងសង្គម។ ការអប់រំទាមទារឱ្យមានការចូលរួម ពីគ្រប់ភាគីពាក់ព័ន្ធដែលមាន សហគមន៍ មាតា បិតាសិស្ស អាជ្ញាធរដែនដី កុំចាំពឹងផ្អែកតែលើសាលារៀនតែមួយមុខ។ ហេតុនេះហើយទើបឥទ្ធិពលនៃ

[5] ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ទំព័រ អារម្ភកថា

ការអប់រំរបស់សាលារៀនចំណោះទូទៅ ពុំអាចគ្របដណ្ដប់ទៅលើកុមារ យុវជនឱ្យសម្រេចទៅតាមសំណូមពរដែលក្រសួងអប់រំ យុវជន និងកីឡាចង់បាននោះទេ។ អាស្រ័យហេតុនេះហើយទើបទំនាក់ទំនងរវាងការអប់រំនៅសាលារៀនការអប់រំរបស់គ្រួសារនិងការអប់រំរបស់សង្គមចាំបាច់ត្រូវធ្វើដំណើរការព្រមៗគ្នាឯកភាពគ្នាគ្រប់វិស័យនោះទើបសម្រេចបាននូវគោលដៅអប់រំដល់ជំនាន់កុមារនិងយុវជនបានត្រឹមត្រូវពិតប្រាកដ។ ទោះបីការអប់រំនៅក្នុងសាលារៀនល្អដល់កម្រិតណាក៏ដោយ ប្រសិនបើខ្វះការអប់រំក្នុងគ្រួសារ និងការអប់រំរបស់សង្គម ហើយនោះលទ្ធផលគឺ ពិតជាមិនអាចពេញលេញល្អប្រសើរស្របទៅតាមបំណង ប្រាថ្នានោះឡើយ។ តាមការសង្កេត និងបទពិសោធន៍កន្លងមកសាលារៀនល្អ មានការរីកចម្រើន គឺមាន កត្តាច្រើនយ៉ាងចូលរួម ក្នុងនោះគ្រូបង្រៀនគឺជាកម្លាំងស្នូលជាពិសេសគឺគ្រូបន្ទុកថ្នាក់ដែលចេះទាក់ទាញទឹកចិត្តឪពុកម្ដាយរបស់សិស្សានុសិស្ស និងបុគ្គលដែលមានឥទ្ធិពលផ្សេងៗទៀតរបស់សង្គមឱ្យចូលរួមក្នុងការអប់រំរបស់សាលារៀន។ការចូលរួមរបស់ពួកគាត់បានធ្វើឱ្យមានការរកឃើញនូវមូលហេតុនៃការរៀនខ្សោយការបំពានវិន័យរបស់សិស្ស ការមិនចូលរៀនរបស់សិស្ស និងការរួមចំណែកធ្វើឱ្យសកម្មភាពជានាក្នុងសាលារៀនកាន់តែមានចរិតល្អ វិសេសវិសាលថែមទៀត។

គ្រួសារជាកោសិការបស់សង្គម ឬជាកោសិការបស់សហគមន៍។ គណៈកម្មការទ្រទ្រង់សាលារៀនសហគមន៍ មាតាបិតាសិស្សអាចជួយគាំទ្រ ឬជួយបំពេញការអប់រំទាំងស្មារតី និងសម្ភារក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ដូចជាការជួយកុមារ យុវជនឱ្យ ចូលរៀនបានគ្រប់ៗគ្នា ផ្ដល់ឱកាស និងពេលវេលាគ្រប់គ្រាន់សម្រាប់ការរៀនសូត្ររបស់កូនៗ តាមដានការសិក្សារបស់កូនៗរាល់ខែដោយចុះហត្ថលេខាលើសៀវភៅតាមដានការសិក្សារបស់កូន ខលតាមទូរស័ព្ទសួរគ្រូទទួលបន្ទុកថ្នាក់អំពីការសិក្សារបស់កូនចំនួនអវត្តមានរបស់កូនៗ ជួយកសាងថែទាំនិងកែលម្អសាលារៀន ជួយផ្ដល់សម្ភារចាំបាច់ ជួយការពារឥទ្ធិពលមិនល្អកុំឱ្យចូលសាលារៀនជាដើម។ ដើម្បីបុព្វហេតុអនាគតដ៏រុងរឿងរបស់ខ្លួន ក៏ដូចគ្រួសារដែរសហគមន៍ ត្រូវតែជួយរៀបចំ ជួយគាំទ្រ ជួយបំពេញអប់រំសាធារណៈ និងត្រូវចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍអនាគតសមាជិកសកម្ម ពោលគឺកុមារ យុវជន ទាំងឡាយដែលកំពុងសិក្សានៅក្នុងសាលារៀនសព្វថ្ងៃឱ្យបានល្អប្រសើរឡើង។

## ១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធវាពិតជាមានសារៈសំខាន់ណាស់ និងចាំបាច់បំផុតដើម្បីឱ្យការសិក្សារបស់សិស្សទទួលបានលទ្ធផលល្អប្រសើរ។ ភាគីពាក់ព័ន្ធទាំងនោះមានដូចជា មាតាបិតា លោកគ្រូ អ្នកគ្រូ នាយកសាលា អាជ្ញាធរដែនដី និងការខិតខំប្រឹងប្រែងរៀនសូត្រដោយខ្លួនឯងជាដើម។ ការចូលរួមរបស់មាតាបិតា សាលារៀន និងសហគមន៍លើការអប់រំវាជាកត្តាសំខាន់ដែលជះឥទ្ធិពលដល់ការសិក្សាអប់រំសិស្ស យោងតាមការសិក្សាស្រាវជ្រាវរបស់លោក Estein (2001) បានបញ្ជាក់ថា «កូនៗអាចរៀន និងអភិវឌ្ឍខ្លួនឯងតាមរយៈគ្រួសារ សាលារៀន និងសហគមន៍។ សិស្សដែលទទួលបានការយកចិត្តទុកដាក់គាំទ្រពីមាតាបិតា មានលទ្ធផលការសិក្សាល្អប្រសើរក្នុងសាលារៀនជាងសិស្សដែលមិនបានទទួលការគាំទ្រ និងយកចិត្តទុកដាក់ពីមាតាបិតា ឬអាណាព្យាបាល»។ មាតាបិតាគឺជាគ្រូបាអាចារ្យដំបូង និងជាព្រះរសរបស់កូនៗគ្រប់រូប ចំណែកឯគ្រូបង្រៀនជាឪពុកម្ដាយទី២របស់សិស្សតែប៉ុណ្ណោះ។ ជាមួយគ្នានោះឥទ្ធិពលនិងមនោសញ្ចេតនារបស់គាត់ចំពោះកូនក្នុងសហគមន៍ក៏មានភាពខ្លាំងក្លាជាងឥទ្ធិពល និងមនោសញ្ចេតនារបស់គ្រូក្នុងសាលារៀនផងដែរ។ នេះអាចបញ្ជាក់បានថាការចូលរួមរបស់មាតាបិតា គ្រួសារ សហគមន៍ ជាផ្នែកមួយយ៉ាងសំខាន់ចំពោះការអភិវឌ្ឍលើវិស័យអប់រំ និងភាពជោគជ័យនៃការអប់រំក្នុងសាលារៀន។ ផ្ទុយទៅវិញប្រសិនបើពុំមានការចូលរួមពីពួកគាត់ទេនោះ ការអប់រំនឹងធ្លាក់ចុះសិស្សានុសិស្សមិនអាចទទួលបានការអប់រំល្អទាំងចំណេះដឹង បំណិនជីវិត ការគិតស៊ីជម្រៅ និងសីលធម៌ក្នុងការរស់នៅ។ លើសពីនេះទៀត ពួកគេអាចធ្លាក់ខ្លួនក្លាយជាអ្នកជំងឺសង្គមដោយការសេពគ្រឿងញៀនតាមរយៈការសេពគប់បាបមិត្ត ការគេចសាលារៀនទៅប្រព្រឹត្តអំពើពាលា និងបទល្មើសផ្សេងៗនៅក្នុងសង្គមជាដើម។ ដូច្នេះដើម្បីឱ្យកូនៗក្លាយជាធនធានមានប្រយោជន៍សម្រាប់គ្រួសារ និងសង្គម មាតាបិតាចាំបាច់ត្រូវផ្ដល់ទាំង៥យ៉ាងដល់កូនគឺ ១. សេចក្ដីស្រឡាញ់, ២. ការថែទាំ និងការការពារ, ៣. បរិយាកាសរៀនសូត្រប្រកបដោយភាពវិជ្ជមាន, ៤ ឥរិយាបថនៃការផ្ដល់តម្លៃលើការរៀន និង ៥. ការបណ្ដុះបណ្ដាលសីលធម៌។ (A parent's Guide from Preschool through Eighth Grade) និពន្ធដោយ William. J Bennet, Chester E Finn, JR John, T.E Gribb.( សុខ ផល្លា,2018 )។

សាលារៀនគឺជាកោសិកាស្នូលនៃប្រព័ន្ធអប់រំ។ សាលារៀនល្អ គឺសាលារៀនដែលមានគណៈគ្រប់គ្រង និងលោកគ្រូ អ្នកគ្រូល្អ គោរពវិន័យ មានឆន្ទៈម្ចាស់ការ ភក្តីភាព មានក្រមសីលធម៌ល្អ មានមនសិការវិជ្ជាជីវៈ មានចំណេះដឹងជំនាញច្បាស់លាស់ មានចក្ខុវិស័យវែងឆ្ងាយ មានបេសកកម្មច្បាស់លាស់ បានកំណត់នូវលទ្ធផលខ្ពស់ដែលត្រូវសម្រេចឱ្យបាន នូវទស្សនវិស័យនេះដែលបានលើកឡើង។ បើយោងតាមសៀវភៅដែលនិពន្ធដោយឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដែលមានចំណងជើងថាកំណែទម្រង់សាលារៀននៅកម្ពុជា បានលើកឡើងថា លទ្ធផលសិក្សារបស់សិស្សចំណុះឱ្យកត្តាធំៗចំនួន៤គឺ៖ ១. នាយកល្អ , ២. គ្រូល្អ , ៣. សិស្សល្អ, ៤. មាតាបិតា និងសហគមន៍ល្អ (បណ្ឌិតសភាចារ្យហង់ជួនណារ៉ុន,2020)[6]

ដូចនេះដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពក្នុងការអប់រំ គឺចាំបាច់ត្រូវតែមានការចូលរួមពីគ្រប់ភាគីពិសេសខាងសាលារៀន មាតាបិតា និងសហគមន៍។ ចំណែកឯការសិក្សាស្រាវជ្រាវនេះគឺផ្តោតសំខាន់លើការចូលរួមរបស់ពួកគាត់ផ្ទាល់ ព្រោះថាបើពុំមានការផ្សារភ្ជាប់គ្នា រវាងសាលារៀននិងសហគមន៍ទេនោះ សាលារៀនពិតជាពុំអាចធ្វើឱ្យសម្រេចរាល់គោលការណ៍អប់រំសំខាន់ៗ នៃការអប់រំបានឡើយ ដូចជា៖ ១. សាលារៀនផ្សារភ្ជាប់នឹងសង្គម, ២. ទ្រឹស្តីផ្សារភ្ជាប់នឹងការប្រតិបត្តិ, ៣. ការបណ្តុះបណ្តាលធនធានមនុស្សផ្សារភ្ជាប់នឹងទីផ្សារពលកម្ម។ បើយើងក្រឡេកមើលទៅប្រទេសសិង្ហបុរីវិញ វិស័យអប់រំគេគឺផលិតមូលធនមនុស្ស ដែលមានលក្ខណៈសម្បត្តិសមស្របតាមតម្រូវការ ដើម្បីឆ្លើយតបទៅនឹងដំណើរការវិវត្តរបស់សេដ្ឋកិច្ច និងតម្រូវការអភិវឌ្ឍ ជាក់ស្តែងរបស់ខ្លួន។ រដ្ឋាភិបាលមិនបណ្តោយឱ្យគ្រឹះស្ថានសិក្សាអប់រំ ផលិតធនធានមនុស្សច្រើនលើស លប់ ខុសពីតម្រូវការទីផ្សារការងារ ដែលនាំឱ្យមានអតិផរណាជំនាញវិជ្ជាជីវៈណាមួយឡើយ។ ម្យ៉ាងទៀតលោកគ្រូ អ្នកគ្រូ នាយកសាលាជាអ្នកផ្តល់ព័ត៌មាន សំណូមពរដល់មាតាបិតា អាណាព្យាបាល និងសហគមន៍ ដើម្បីឱ្យពួកគេមានទំនុកចិត្ត និងចូលរួមសហការគ្នាទៅវិញទៅមកក្នុងការតាមដាន និងលើកកម្ពស់ លទ្ធផលសិក្សាកូនៗរបស់ពួកគាត់។ ការចូលរួមរបស់មាតាបិតា សាលារៀន និងសហគមន៍គឺពិតជាមានសារៈសំខាន់យ៉ាងខ្លាំងចំពោះវិស័យអប់រំ ជាពិសេសបានធ្វើ

6 កំណែទម្រង់សាលារៀននៅកម្ពុជា បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ២០២០

ឱ្យលទ្ធផលសិក្សារបស់សិស្សបានល្អប្រសើរឡើង។ ម្យ៉ាងទៀតការចូលរួមរបស់ពួកគាត់គឺធ្វើឱ្យសិស្សបានចូលរៀនទៀងទាត់ កាត់បន្ថយការបោះបង់ការសិក្សា មិនសូវមានសិស្សគេចសាលា ធ្វើឱ្យសិស្សមានចិត្តចង់រៀនដោយសារមានការលើកទឹកចិត្ត និងគាំទ្រពីពួកគាត់ បានដឹងពីលទ្ធផលសិក្សារបស់កូន និងចំនួនអវត្តមាន ហើយព្រមទាំងបានធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សល្អផងដែរ។ ទន្ទឹមនឹងសារៈប្រយោជន៍នៃការចូលរួមរបស់ មាតាបិតា សាលារៀន និងសហគមន៍យ៉ាងច្រើននេះ យើងក៏សង្កេតឃើញថាការចូលរួមរបស់មាតាបិតា និងសហគមន៍នៅមានកម្រិតនៅឡើយដោយសារពួកគាត់មានបញ្ហាមួយចំនួនទើបធ្វើឱ្យគាត់មិនសូវបានចូលរួមក្នុងការអប់រំជាមួយសាលារៀន។ បញ្ហាទាំងនោះមានដូចជា កត្តាជីវភាពគ្រួសារ កត្តាចំណេះដឹង មុខរបរ ចំណាកស្រុក រវល់ធ្វើការរកស៊ី និងមិនសូវយល់ពីសារៈសំខាន់នៃការអប់រំចំពោះកូនជាដើម។ ដោយសារតែសង្កេតឃើញថាមានបញ្ហានានាជាច្រើន រវាងការចូលរួម របស់មាតាបិតា អាណាព្យាបាល និងសហគមន៍ ជាមួយនិងសាលារៀនលើការផ្ដល់សេវាអប់រំ និងលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនេះហើយ ទើបឱ្យមានការលើកជាប្រធានបទស្រាវជ្រាវនេះឡើង គឺ «**ការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស នៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀង**» មកធ្វើការសិក្សាស្រាវជ្រាវក្នុងគោលបំណងដូចការរៀបរាប់ខាងក្រោមស្រាប់។

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងសិក្សារកឱ្យឃើញនូវ៖

(១) សិក្សាពីកម្រិតនៃការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀង។

(២)សិក្សាពីបញ្ហាប្រឈមដែលនាំឱ្យសហគមន៍(មាតាបិតានិងអាជ្ញាធរ)មិនសូវបានចូលរួមសកម្មភាព ជាមួយសាលារៀនក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស (កូន)។

## ១.៤. សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃការស្រាវជ្រាវខាងលើ សំណួរស្រាវជ្រាវត្រូវបានកំណត់ដូចខាងក្រោម៖

១. តើការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស នៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀង ស្ថិតនៅក្នុងកម្រិតណា?

២. តើបញ្ហាប្រឈមអ្វីខ្លះ ដែលនាំឱ្យសហគមន៍មិនសូវបានចូលរួមការងារអប់រំ ជាមួយសាលារៀនក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស(កូន)?

## ១.៥. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ដោយយោងទៅតាមពេលវេលា ថវិកាមានកំណត់របស់អ្នកសិក្សាស្រាវជ្រាវ និងបញ្ហាស្ថានភាពជំងឺ Covid-19[7] នៅតែមាន និងអូសបន្លាយរហូតមក ការសិក្សានេះបានជ្រើសរើសយកវិទ្យាល័យចំនួន១០ ដែលស្ថិតនៅក្នុងស្រុក/ក្រុងចំនួន០៥ ក្នុងខេត្តស្វាយរៀងមកធ្វើការសិក្សាស្រាវជ្រាវ។ ការសិក្សានេះបានកំណត់ ជ្រើសរើសយកសិស្សានុសិស្សដែលកំពុងសិក្សានៅថ្នាក់ទី១០,១១ និងទី១២ ចំនួន៤០០នាក់ ក្នុងឆ្នាំសិក្សា២០២០-២០២១, លោកគ្រូ អ្នកគ្រូចំនួន១០០នាក់, នាយក/នាយិកាសាលាចំនួន២០នាក់ សហគមន៍ (មាតាបិតាសិស្សចំនួន១០០ នាក់ និងអាជ្ញាធរ ចំនួន២០នាក់)។

## ១.៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវពីប្រធានបទ «**ការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស នៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀង**» ពិតជាមានសារៈសំខាន់ណាស់ព្រោះ វាបាន រកឃើញនូវកត្តាដែលនាំឱ្យលទ្ធផលសិក្សារបស់សិស្សបានល្អប្រសើរ ហើយលទ្ធផលក៏កើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ និងបានដឹងពីកម្រិតនៃការចូលរួមរបស់ភាគីពាក់ព័ន្ធក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ព្រមទាំងបញ្ហាប្រឈមមួយចំនួនដែលសហគមន៍ មិនសូវបានចូលរួមជាមួយសាលាក្នុងការ

7 Covid-19: ជាជំងឺផ្លូវដង្ហើមដ៏សាហាវ ដែលបង្កដោយ coronavirus កើតនៅក្នុងឆ្នាំ២០១៩

លើកកម្ពស់លទ្ធផលសិក្សារបស់សិស្សផងដែរ។ តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ នឹងជួយដល់សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ មាតាបិតាសិស្ស គណៈគ្រប់គ្រងសាលា និងក្រសួងអប់រំ យុវជន និងកីឡា ដឹងពីមូលហេតុ និងកត្តានានាដែលនាំឱ្យសិស្សានុសិស្សទទួលបានលទ្ធផលសិក្សាល្អប្រសើរកើនឡើង។ ជាងនេះទៅទៀតបានជួយដល់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការចាត់វិធានការ និងបង្កើតគោលនយោបាយ ដោយផ្ដល់ឱកាសឱ្យសហគមន៍បានចូលរួម ក្នុងសកម្មភាពនានារបស់សាលាក្នុងការលើកកម្ពស់លទ្ធផល សិក្សារបស់សិស្សានុសិស្ស និងរកវិធីដោះស្រាយទៅលើបញ្ហាប្រឈមនានាដែលសហគមន៍មិនសូវបាន ចូលរួមដើម្បីឱ្យសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា គឺចង់ប្រែក្លាយខ្លួនទៅជាប្រទេសឧស្សាហកម្មនៅឆ្នាំ២០២៥ ជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០(ក្រសួងអប់រំ យុវជន និងកីឡា)[8] ។

## ១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះចែកចេញជាប្រាំជំពូកដូចខាងក្រោម៖

ជំពូក១៖ សេចក្ដីផ្ដើមរួមមាន លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ វិសាលភាពនិងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

ជំពូក២៖ និយាយពីការរំលឹកទ្រឹស្ដីដោយក្នុងនោះបានលើកយកចំណុច និយមន័យពាក្យគន្លឹះ ទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ សារៈសំខាន់នៃគ្រួសារនិងសហគមន៍ ទំនាក់ទំនងសាលារៀន និងសហគមន៍ តួនាទីនិងភារកិច្ចរបស់សហគមន៍ ឥទ្ធិពលវិជ្ជមានរបស់អាណាព្យាបាលលើការ ចូលរួមក្នុងការអប់រំកូន បញ្ហាប្រឈមនៃការចូលរួម និងតួនាទីរបស់សាលារៀន និងយុទ្ធវិធីដើម្បីទាក់ទាញសហគមន៍ឱ្យចូលរួមអភិវឌ្ឍសាលារៀន។

ជំពូក៣៖ រៀបរាប់អំពីវិធីសាស្ត្រស្រាវជ្រាវដែលអ្នកសិក្សាស្រាវជ្រាវបានយកមកប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវនេះ។ នៅក្នុងជំពូកនេះអ្នកស្រាវជ្រាវ បង្ហាញពីការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវការជ្រើស

[8] សៀវភៅផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨,ទំព័រ១៣

វើសភាគសំណាក ការប្រើប្រាស់ឧបករណ៍ឧបករណ៍ស្រាវជ្រាវ ការប្រមូលទិន្នន័យ ការវិភាគទិន្នន័យ កម្រិតចង្អុលបង្ហាញ និងក្រមសីលធម៌នៃការស្រាវជ្រាវ។

ជំពូក៤៖ លទ្ធផល និងការពិភាក្សា ក្នុងផ្នែកនេះអ្នកស្រាវជ្រាវលើកឡើងពីលក្ខណៈជាក់ស្តែងដែលបានធ្វើការសិក្សាស្រាវជ្រាវ គឺត្រូវឆ្លើយតបទៅនឹងចំណុចដែលចោទសួរនៅក្នុងចំណោទបញ្ហា។ ចំពោះលទ្ធផលត្រូវបានបកស្រាយយ៉ាងលម្អិតទៅលើគោលបំណងនៃការស្រាវជ្រាវ ដោយយោងទៅលើលទ្ធផលនៃការស្រាវជ្រាវទ្រឹស្តី ឬខ្លឹមសារដែលមានក្នុងកម្រងសំណួរ។

ជំពូក៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ។ ក្នុងជំពូកនេះអ្នកស្រាវជ្រាវនឹងបង្ហាញពីអ្វីដែលបានរកឃើញទាក់ទងនឹងកម្រិតនៃការចូលរួម បញ្ហាប្រឈមនានា ទស្សនទានរបស់ភាគីពាក់ព័ន្ធ ចំពោះការចូលរួមក្នុងវិស័យអប់រំ និងសំណូមពរមួយចំនួន ដើម្បីធ្វើឱ្យការចូលរួម និងការរៀបចំគោលនយោបាយអប់រំឱ្យឆ្លើយតបនឹងតម្រូវការសង្គម។ ធ្វើការសង្ខេបការសិក្សាស្រាវជ្រាវ រួចទាញជាសេចក្តីសន្និដ្ឋានលើចំណុចដែលបានវិភាគ និងផ្តល់យោបល់ ឬសំណូមពរ ទៅលើចំណុចដែលត្រូវដោះស្រាយ និងកែលម្អ។

# ជំពូក២

# រំលឹកទ្រឹស្តី

តាមការសិក្សាស្រាវជ្រាវលើឯកសារមួយចំនួនដែលមានទំនាក់ទំនងទៅនឹងការចូលរួមរបស់មាតាបិតាទៅលើការអប់រំកូន សហគមន៍ និងអ្នកពាក់ព័ន្ធដ៏ទៃទៀត ចំពោះសិស្សក្នុងការទទួលបានការអប់រំមួយដ៏ល្អ និងភាពជោគជ័យរបស់ពួកគេគឺសុទ្ធតែបានបង្ហាញអំពីការចូលរួមយកចិត្តទុកដាក់ពីសំណាក់មាតាបិតា អាណាព្យាបាល លោកគ្រូ អ្នកគ្រូ នាយកសាលានិងសហគមន៍ជាដើម។ នៅក្នុងការសិក្សាស្រាវជ្រាវនេះនឹងផ្តោតយ៉ាងសំខាន់ទៅលើការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅ កម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀង។ ការចូលរួមរបស់សហគមន៍ពិតជាមានសារៈសំខាន់ក្នុងការរៀនរបស់សិស្សព្រមទាំង ចូលរួមលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សឱ្យបានល្អប្រសើរផងដែរ។ ការចូលរួមរបស់មាតាបិតា អាណាព្យាបាល សហគមន៍ជាមួយសាលារៀន គឺមានតាំងពីយូរលង់ណាស់មកហើយ ដោយគេសង្កេតឃើញថាក្រោយពីទទួលបានឯករាជ្យពីប្រទេសបារាំង (៩ វិច្ឆិកា ១៩៥៣) ប្រព័ន្ធអប់រំនៅប្រទេសកម្ពុជាមានការរីកចម្រើនយ៉ាងខ្លាំង។សាលារៀនបានរីកសាយជាច្រើនកន្លែងទូទាំងប្រទេសហើយប្រជាជនខ្មែរមានសន្ទុះទឹកចិត្ត សប្បាយរីករាយ ចំពោះការរៀនសូត្រយ៉ាងខ្លាំង។ នៅគ្រប់ឃុំគ្រប់ស្រុកមានបង្កើតសាលារៀន សហគមន៍ទ្រទ្រង់សាលារៀនដោយព្រះសង្ឃ និងឪពុកម្តាយសិស្ស។ គេបាននាំគ្នារកបច្ច័យតាមរយៈការធ្វើបុណ្យផ្កាប្រាក់សាមគ្គី យកលុយមកកសាងសាលារៀននៅតាមភូមិឃុំរបស់ខ្លួន និងបានបញ្ជូនកូនឱ្យមករៀនយ៉ាងច្រើនកុះករ។ នេះបង្ហាញឱ្យឃើញថា សហគមន៍ មាតាបិតាសិស្ស ពិតជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងវិស័យអប់រំ ក៏ប៉ុន្តែការយកចិត្តទុកដាក់នេះបានថយចុះទៅវិញនៅពេលដែលប្រទេសកម្ពុជាបានឆ្លងកាត់សម័យកាលដ៏ជូរចត់មួយគឺសម័យកម្ពុជាប្រជាធិបតេយ្យ (សម័យប៉ុលពត ១៩៧៥-១៩៧៩)។ ទោះបីជាឆ្លងកាត់ដំណាក់កាលនយោបាយ ច្រើនសម័យយ៉ាងណាក្តីក៏វិស័យអប់រំនៅតែអាចបន្តដំណើរការរបស់ខ្លួនទៅមុខ ជាបន្តបន្ទាប់ព្រមទាំងទទួលបានការគាំទ្រ និង

មិនអាចខ្វះបានពីការចូលរួម របស់សហគមន៍[9]។

## ២.១. ពាក្យគន្លឹះ

**ការចូលរួម**[10] តាមន័យក្នុងវចនានុក្រមសម្តេច ជួន ណាត គឺសំដៅលើការផ្សំបញ្ចូលគ្នា ការចូលគ្នា ការប្រមូលឱ្យចូលគ្នា ការមូលមួយនឹងគ្នា។

**សហគមន៍**[11] មកពីពាក្យថា សហ+គមន៍ មានន័យថា សហ=រួម , គមន៍=ទំនាក់ទំនង។ ដូចនេះសហគមន៍=ទំនាក់ទំនងរួម។ បញ្ញត្តិសហគមន៍គឺសំដៅលើមនុស្សគ្រប់ស្រទាប់ ដែលរស់នៅក្នុងតំបន់មួយ ដោយធ្វើទំនាក់ទំនងជាមួយគ្នា ទាំងផ្នែកសម្ភារ និងស្មារតី។

**សហគមន៍**[12] «គឺសំដៅលើមនុស្សគ្រប់ស្រទាប់ដែលរស់នៅក្នុងតំបន់ដោយធ្វើទំនាក់ទំនងជាមួយគ្នា»។

ចំណែកលោកបណ្ឌិត **ប្រាមោទ្យបញ្ញាកាន** (Dr. Pramote Benchakarn) នាយកវិទ្យាស្ថានរាជភ័ត្តបុរីរ៉ាមបានឱ្យនិយមន័យថា«សហគមន៍បានដល់តំបន់មួយដែលមានព្រំប្រទល់ដែនទឹកដី ច្បាស់លាស់ មានប្រជាជនរស់នៅទាក់ទងគ្នាប្រកបដោយវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី និងច្បាប់» (ក្រសួងអប់រំ យុវជន និងកីឡា 2009)។

ទោះបីជាការឱ្យនិយមន័យមានខ្លឹមសារប្លែកគ្នាខ្លះយ៉ាងណាក្តីក៏ចំណុចសំខាន់នៃពាក្យសហគមន៍ គឺសំដៅក្រុមមនុស្សដែលរស់នៅមានទំនាក់ទំនងគ្នា ទាំងផ្នែកស្មារតី និងសម្ភារ។ ដោយឡែកនៅក្នុងទំនាក់ទំនងសាលារៀន និងសហគមន៍ គេនិយមចែកជាពីរផ្នែកគឺ៖

**ក.សហគមន៍ជាតិ** បានដល់គ្រូបង្រៀនបុគ្គលិកសិក្សាគណៈគ្រប់គ្រងសាលាកម្មករសិស្សានុសិស្ស មាតាបិតាសិស្ស សហគមន៍ គណៈកម្មការទ្រទ្រង់សាលារៀនប្រជាជនទូទៅអាជ្ញាធរដែនដី រដ្ឋអំណាចភូមិ ឃុំ ស្រុក ព្រះសង្ឃ អាចារ្យវត្ត ដូនជី តាជី កងកម្លាំងប្រដាប់អាវុធ សមាគមន៍ជាតិ សមាគមន៍អាណិកជនខ្មែរ និងមន្ត្រីរាជការស្ថាប័នផ្សេងៗ ទូទាំងប្រទេស។

---

[9] ប្រវត្តិអប់រំនៅកម្ពុជា ដោយលោក ស៊ន សំណាង និងយ៉ង់ ធី ១៩៩៩ ទំព័រ ៣៣

[10] វចនានុក្រមខ្មែរ ១៩៦៧ បោះពុម្ពដោយសាសនបណ្ឌិត្យ លើកទី៥ ទំព័រ ៧៨៩

[11] ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៦ ទំព័រ.១៦២

[12] ឯកសារស្តីពីទំនាក់ទំនងសាលារៀន និងសហគមន៍របស់ក្រសួងអប់រំ យុវជន និងកីឡា បោះពុម្ពឆ្នាំ ២០០៩

**ខ.សហគមន៍អន្តរជាតិៈ** **គឺបានដល់ទីភ្នាក់ងារផ្តល់ជំនួយជាពហុភាគីដល់ប្រព័ន្ធអប់រំដូចជាអេឌីប៊ី** (ADB) វើលបេង(WB) យូនីសេស(UNICEF) យូអិនឌីភី(UNDP) យូអិនអេហ្វភីអេ(UNFPA) យូណេស្កូ(UNESCO) អឺយូ(EU)... និងអ្នកផ្តល់ជំនួយទ្វេភាគីដូចជា ចាយកា(JICA) កយកា (KOICA)យូសេដ(USIAD) អូសសេដ(AUSAID) ជីជីហ្សែត(GTZ)...ព្រមទាំងការផ្តល់ជំនួយតាមរយៈអង្គការក្រៅរដ្ឋាភិបាលនានាផងដែរ។

**លទ្ធផលសិក្សា**មានន័យថាផលសិក្សាបានសម្រេចហើយ,ផលនៃការសិក្សាដែលបានសម្រេចហើយ។

**សរុបមក** ការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលរបស់សិស្ស គឺសំដៅលើការផ្សំបញ្ចូលគ្នានៃមនុស្សគ្រប់ស្រទាប់វណ្ណៈដែលរស់នៅមានទំនាក់ទំនងគ្នា នៅក្នុងតំបន់ ស្រុក ដើម្បីផ្សំបញ្ចូលគ្នានូវគំនិតប្រាជ្ញា ស្មារតី ទ្រព្យសម្បត្តិ ពេលវេលា ក្នុងការធ្វើសកម្មភាពបណ្តុះវិជ្ជា កិរិយាមារយាទរបស់ក្មេង សិស្សានុសិស្សនៅក្នុង តំបន់ ស្រុកនោះជាពិសេសការសិក្សារបស់សិស្សបានល្អប្រសើរឡើង។ ម្យ៉ាងទៀតអាចនិយាយបានថា ជាការចូលរួមរបស់ឪពុកម្តាយ អាជ្ញាធរ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដែលពាក់ព័ន្ធលើការងារសិក្សារៀនសូត្ររបស់សិស្សជាប្រចាំ ដើម្បីធ្វើឱ្យលទ្ធផលនៃការសិក្សារបស់សិស្ស បានល្អប្រសើរឡើង។

## ២.២. ទំនាក់ទំនងរវាងសាលារៀន និងសហគមន៍

សហគមន៍គឺជាប្រភពដ៏សំខាន់បំផុតនៃការអភិវឌ្ឍសាលារៀនហើយសាលារៀន និងសហគមន៍ត្រូវមានទំនាក់ទំនងគ្នាទៅវិញទៅមក។ ដើម្បីអភិវឌ្ឍវិស័យអប់រំគឺត្រូវមានការ ចូលរួមពីគ្រប់អ្នកពាក់ព័ន្ធមានជាអាទិ៍ផ្នែកសាធារណៈ ផ្នែកឯកជន អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍[13]។ សហគមន៍និងមាតាបិតាសិស្សមានករណីកិច្ច បញ្ជូនកូនដែលមានអាយុ ៦ (ប្រាំមួយ)ឆ្នាំ ឬ៧០ (ចិតសិប) ខែឡើងទៅឱ្យបានចូលរៀន ព្រមទាំងគាំទ្រពួកគេទាំងស្មារតី និងសម្ភារ ដើម្បីឱ្យគេចូលរៀន និងបន្តរៀនរហូតចប់ការអប់រំ កម្រិតមូលដ្ឋាន។ មិនតែប៉ុណ្ណោះសហគមន៍ត្រូវផ្សារភ្ជាប់សាលារៀននិងគ្រួសារដើម្បីជួយសាលារៀនលើការបណ្តុះបណ្តាល និងកែលម្អបរិស្ថាន។ ដើម្បីអភិវឌ្ឍវិស័យអប់រំ

[13] ច្បាប់ស្តីពីអប់រំ ឆ្នាំ២០០៧ មាត្រា ៣៦ ទំព័រទី១៣ ។

សហគមន៍ ត្រូវផ្តល់ធនធានយ៉ាងពេញលេញ ទាំងធនធានមនុស្ស ទាំងសម្ភារ ឬថវិកា ដើម្បីឱ្យវិស័យអប់រំមានការរីកចម្រើន និងផលិតធនធានមនុស្សដើម្បីយកមកអភិវឌ្ឍសហគមន៍ ឬសង្គមវិញ។ ទំនាក់ទំនងរវាងការអប់រំរបស់សាលារៀន ការអប់រំរបស់គ្រួសារ និងការអប់រំរបស់សង្គមចាំបាច់ត្រូវដំណើរការព្រមៗគ្នាឯកភាពគ្នាគ្រប់វិស័យ នោះទើបសម្រេច បាននូវគោលដៅអប់រំបានត្រឹមត្រូវពិតប្រាកដ។ ការអប់រំនៅសាលារៀនគឺបានតែមួយផ្នែកប៉ុណ្ណោះចាំបាច់ត្រូវតែមានការអប់រំរបស់គ្រួសារនិងការអប់រំរបស់សហគមន៍ថែមទៀត ដើម្បីជម្រុញការអប់រំក្នុងសាលារៀនកាន់តែមានប្រសិទ្ធភាព។ ទោះបីជាការអប់រំក្នុងសាលារៀនល្អដល់កម្រិតណាក៏ដោយ ប្រសិនបើខ្វះការអប់រំរបស់សង្គមហើយនោះ លទ្ធផលគឺពិតជាមិនអាចពេញលេញល្អសមស្របទៅតាមបំណងប្រាថ្នានោះឡើយ។

សាលារៀនចំណោះទូទៅត្រូវមានតួនាទីជាអ្នកដឹកនាំ ដែលមានគ្រូបង្រៀនជាកម្លាំងស្នូលក្នុងកិច្ចការទំនាក់ទំនងរវាងការអប់រំរបស់សាលារៀន ជាមួយការអប់រំរបស់គ្រួសារ និងការអប់រំរបស់សង្គម។ តាមការពិសោធកន្លងមកបណ្តាថ្នាក់ដែលល្អ គឺថ្នាក់ដែលមានគ្រូទទួលបន្ទុកចេះគួបផ្សំនូវការអប់រំទាំងបីបញ្ចូលគ្នា(ការអប់រំនៅសាលារៀន គ្រួសារ និងសង្គម)។ បណ្តាគ្រូទទួលបន្ទុកទាំងនោះចេះទាក់ទាញនូវទឹកចិត្ត ឪពុកម្តាយរបស់សិស្សានុសិស្ស និងបណ្តាកម្លាំងផ្សេងៗទៀតរបស់សង្គមឱ្យចូលរួមក្នុងការអប់រំរបស់សាលារៀនធ្វើឱ្យមានការរកឃើញនូវមូលហេតុនៃការរៀនខ្សោយ ការមិនយកចិត្តទុកដាក់រៀនសូត្រ ការបំពានវិន័យរបស់សិស្ស ការគេចសាលារបស់សិស្ស ការរួមចំណែកធ្វើឱ្យសកម្មភាពនានាក្នុងសាលារៀនកាន់តែមានចរិតល្អថែមទៀត។

## ២.៣. សារៈសំខាន់នៃគ្រួសារ និងសហគមន៍[14]

បើយោងតាម Warlene D.Gary and Robert Witherspoon(2011)បានលើកឡើងថា «ការផ្តល់ការអប់រំតម្រូវឱ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់មាតាបិតា គ្រួសារ និងសហគមន៍ ទើបធ្វើឱ្យការអប់រំជានាបាននូវគុណភាពល្អពិតប្រាកដ។ តាមរយៈទស្សនៈនេះការធ្វើការងារដោយសហការជាមួយ

[14] និក្ខេបបទ សុខ ផល្លា ឆ្នាំ២០១៨ ទំព័រ.១៨

គ្រួសារ សហគមន៍នឹងបង្កើនសមត្ថភាពដៃគូនីមួយៗ នៃអ្នកពាក់ព័ន្ធនឹងការងារអប់រំនេះឱ្យពួកគេបានរៀនសូត្រពីគ្នាទៅវិញទៅមក ដើម្បីគាំទ្រគោលដៅរួមគឺសេចក្តីសង្ឃឹម និងសុបិនដ៏ល្អសម្រាប់កូនចៅជំនាន់ក្រោយរបស់យើង។ ការសិក្សាមួយទៀតបង្ហាញថា ទំនាក់ទំនងមាតាបិតា ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់កូនមានលក្ខណៈផ្សេងៗគ្នាពីផ្ទះមួយទៅផ្ទះមួយ ឬពីគ្រួសារមួយទៅគ្រួសារមួយ ជាមួយសាលារៀន។ ការបញ្ជាក់នេះត្រូវបានបង្ហាញតាមរយៈសកម្មភាពដែល ពួកគាត់ជូនកូនមកសាលារៀន ការផ្គត់ផ្គង់កូនប្រចាំថ្ងៃ ដូចជា សម្ភារសិក្សា ថវិកា ការស្លៀកពាក់ឱ្យបានសមរម្យឱ្យកូន ការសាកសួរព័ត៌មាន ឬប្រឹក្សាយោបល់ជាមួយពួកគាត់ ការតាមដានការសិក្សារបស់កូន ការណែនាំកូនឱ្យធ្វើកិច្ចការផ្ទះដែលគ្រូដាក់ឱ្យធ្វើ ផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ឱ្យកូនបានរៀនសូត្រ សកម្មភាពទាំងនេះជាការបង្កឱកាសឱ្យកូនបានសិក្សារៀនសូត្រ មានចំណេះដឹងតាមរយៈការអប់រំ។ បើយោងតាមលោក Born stein 2005 ; Epstein ទង្វើនេះបង្ហាញឱ្យឃើញថា ឪពុកម្តាយ បានគិតគូពីអនាគតរបស់កូនស្របជាមួយនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានកំណត់ថាឪពុកម្តាយគ្រប់រូបត្រូវបញ្ជូនកូនគ្រប់អាយុឱ្យមករៀនគ្រប់ៗគ្នា។ វាក៏ឆ្លុះបញ្ចាំងពីការយល់ដឹង និងការឱ្យតម្លៃលើការអប់រំផងដែរ។ យើងដឹងហើយថា ចំណេះដឹងគឺជាអំណាច។ ចំណេះវិជ្ជាគឺជាទ្រព្យដ៏ប្រសើរ លើសទ្រព្យទាំងឡាយទាំងពួង។ ដើម្បីឱ្យចំណេះវិជ្ជានិងចំណេះដឹងនេះចូលទៅដល់សិស្សានុសិស្សបានគឺ ត្រូវទាមទារធ្វើឱ្យសាលារៀនដែលជាមជ្ឈមណ្ឌលផ្តល់និងផ្ទេរចំណេះដឹងនោះមានលក្ខណៈល្អប្រសើរឡើង តាមរយៈការធ្វើការងារជាដៃគូយ៉ាងជិតស្និទ្ធរវាងសាលារៀន មាតាបិតាសិស្ស សហគមន៍ និងអាជ្ញាធរដែនដី។

សហគមន៍ខ្លាំង សាលារៀនខ្លាំង នោះធ្វើឱ្យសិស្សខ្លាំង។ គោលបំណងសំខាន់របស់សហគមន៍ និងសាលារៀន គឺត្រូវធានាថាសិស្សម្នាក់ៗទទួលបានចំណេះដឹង ជំនាញ បំណិន ទម្លាប់ និងឥរិយាបថដែលជាធាតុចាំបាច់សម្រាប់ ជោគជ័យក្នុងជីវិត។ ការសិក្សាការអប់រំក្នុងសាលារៀនការអប់រំផ្ទាល់ខ្លួន ការអប់រំក្នុងគ្រួសារ ការអប់រំក្នុងសង្គម ការអប់រំវិជ្ជាជីវៈ ការអប់រំចិត្តសាស្ត្រសង្គម ដែលជាធាតុចាំបាច់សម្រាប់ភាពជោគជ័យក្នុងជីវិតរស់នៅរបស់មនុស្សគ្រប់គ្នា។ សាលារៀនជះឥទ្ធិពលដោយផ្ទាល់ទៅលើសិស្ស ក្នុងការរៀនហើយសហគមន៍ក៏បានចូលរួមចំណែកលើការរៀនរបស់សិស្សយ៉ាងសំខាន់ជាមួយសាលារៀនក្នុង

ការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅចុងឆ្នាំសិក្សាផងដែរ។ ទង្វើនេះបានបង្ហាញឱ្យឃើញថាឪពុកម្តាយ បានគិតគូពីអនាគតរបស់កូន ស្របជាមួយនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលកំណត់ថាឪពុកម្តាយគ្រប់រូបត្រូវបញ្ជូនកូនគ្រប់អាយុឱ្យចុះឈ្មោះចូលរៀនបានគ្រប់ៗគ្នា។

សហគមន៍ជាដៃគូដ៏សំខាន់ និងមិនអាចខ្វះបានរបស់សាលារៀនក្នុងការអប់រំកុមារ យុវជនឱ្យគេក្លាយជាមនុស្សល្អ មានគុណធម៌ ចរិយាធម៌ មានចំណេះវិជ្ជាគ្រប់គ្រាន់អាចបន្តការសិក្សា ហើយទីបញ្ចប់គេនឹងក្លាយជាមនុស្សពេញលេញ ជាពលរដ្ឋល្អនៅក្នុងសង្គម។

ជាតិសាសន៍នីមួយៗដែលមានប្រជាជនរស់នៅលើទឹកដីរបស់ខ្លួន រួមទាំងប្រទេសកម្ពុជាផងដែរ ពួកគេតែងតែមានទំនៀមទម្លាប់ ប្រពៃណីដ៏ល្អ គោរពប្រតិបត្តិតាមមាគ៌ាសាសនាចេះគោរពគ្នា ជួយយកអាសារគ្នា មានសាមគ្គីភាព យោគយល់អធ្យាស្រ័យល្អជាមួយគ្នាជាដើម។ ទន្ទឹមនឹងនេះ ប្រជាជនខ្មែរយើងក៏មានបទពិសោធន៍ដ៏សម្បូរបែប លើការងារគ្រប់គ្រង ការងារជំនាញផ្សេងៗ ផ្នែកបច្ចេកទេស ការងារកសិកម្ម ការធ្វើជំនួញជួញដូរជិតឆ្ងាយ។ល។ ដោយមើលឃើញថាសហគមន៍ជាប្រភពនៃចំណេះដឹងជំនាញ និងបទពិសោធន៍ដ៏សម្បូរបែបនេះហើយទើបសាលារៀន គ្រូបង្រៀនត្រូវការ ការចូលរួមសហការពីគ្រប់ភាគីពាក់ព័ន្ធជាមួយសាលារៀនជាពិសេស មាតាបិតា អាណាព្យាបាល សហគមន៍ និងអាជ្ញាធរមូលដ្ឋានដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។

## ២.៤. សារៈសំខាន់នៃទំនាក់ទំនងសាលារៀន និងសហគមន៍[15]

សាលារៀនជាផ្នែកមួយរបស់សង្គម។ សាលារៀនត្រូវមានការផ្សារភ្ជាប់គ្នារវាងសាលារៀន និងសហគមន៍។ នោះសាលារៀនពិតជាអាចសម្រេចបានរាល់គោលការណ៍សំខាន់ៗនៃការអប់រំបានដូចជា «សាលាផ្សារភ្ជាប់នឹងសង្គម» « ទ្រឹស្តីផ្សារភ្ជាប់នឹងប្រតិបត្តិ» និង « ការបណ្តុះបណ្តាលធនធានមនុស្សផ្សារ ភ្ជាប់នឹងទីផ្សារពលកម្ម »

នៅក្នុងសង្គមណាក៏ដោយសាលារៀន និងសង្គមត្រូវមានទំនាក់ទំនងគ្នាពុំអាចកាត់ផ្តាច់ពីគ្នាបានឡើយ។ ចំណែកឯសាលារៀនពុំអាចអភិវឌ្ឍបានដោយខ្វះការចូលរួមពីសហគមន៍ឡើយ។ ផ្ទុយទៅវិញ

[15] ទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០៩ ទំ.១៦-១៨

សហគមន៍ ក៏ពុំអាចគង់វង្ស ស្ថិតស្ថេរ និងរីកចម្រើនបានដោយខ្វះការផ្ដល់កម្លាំងចលករពីសាលារៀនដែរ។ សាលារៀនចំណេះទូទៅ មាននាទីអប់រំគ្រប់ផ្នែក ប៉ុន្ដែមិនមែនជាកន្លែងតែមួយគត់ដែលអាចធានាទាំងស្រុងថាពេញលេញ គ្រប់ការអប់រំនោះទេពីព្រោះរៀងរាល់ថ្ងៃកុមារ និងយុវជន បានរៀនសូត្រនិងរស់នៅក្នុងសាលារៀនតែក្នុងរយៈពេលមួយកំណត់ច្បាស់លាស់ប៉ុណ្ណោះ។ ឯពេលវេលាដែលនៅសល់មួយភាគធំលើសលប់គឺគេនៅជាមួយគ្រួសារ និងសង្គម។ ហេតុដូចនេះហើយទើបឥទ្ធិពលនៃការអប់រំរបស់សាលារៀនពុំអាចគ្របដណ្ដប់លើកុមារ និងយុវជនឱ្យសម្រេចទៅតាមសំណូមពរដែលក្រសួងអប់រំ យុវជន និងកីឡាចង់បាននោះទេ។ ដើម្បីទទួលបានលទ្ធផលល្អទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ រួមទាំងសាលារៀន គ្រួសារ និងសង្គម ។

ទំនាក់ទំនងរវាងការអប់រំក្នុងសាលារៀន ការអប់រំក្នុងគ្រួសារ និងការអប់រំក្នុងសង្គមចាំបាច់ត្រូវដំណើរការព្រមៗគ្នាឯកភាពគ្នាគ្រប់វិស័យនោះទើបសម្រេចបាននូវគោលដៅអប់រំដល់យុវវ័យបានត្រឹមត្រូវពិតប្រាកដ។ គណៈកម្មការទ្រទ្រង់សាលារៀន សហគមន៍អាចជួយគាំទ្រ ជួយបំពេញការអប់រំ ទាំងស្មារតី និងសម្ភារ ដូចជាការជួយកុមារឱ្យចូលរៀនកសាងសាលារៀនផ្ដល់សម្ភារចំបាច់ និងការពារឥទ្ធិពលសាលារៀន។ ដើម្បីបុព្វហេតុអនាគតដ៏រុងរឿងរបស់ខ្លួន ក៏ដូចជាគ្រួសារដែរ សហគមន៍ត្រូវតែជួយរៀបចំគាំទ្របំពេញការងារអប់រំសាធារណៈនិងត្រូវតែចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍអនាគតសមាជិកសកម្ម ពោលគឺកុមារា កុមារី យុវជន យុវនារីទាំងឡាយ ដែលកំពុងតែសិក្សានៅក្នុងសាលារៀនសព្វថ្ងៃ។ នៅក្នុងទំនាក់ទំនងសាលារៀន និងសហគមន៍អាចជួយគ្នាទៅវិញទៅមកដូចជា៖

### ក. សាលារៀនជួយដល់សហគមន៍

- ខិតខំបង្រៀន និងអប់រំកុមារ យុវជនឱ្យបានល្អ
- ខិតខំផលិតពលករ ឬអ្នកមានមុខជំនាញផ្សេងៗ ដើម្បីបម្រើផលប្រយោជន៍សហគមន៍
- ជួយបំផុសមាតាបិតាសិស្សក្នុងការងារទំនាក់ទំនងសាលារៀន និងសហគមន៍
- ថែរក្សា វប្បធម៌ ប្រពៃណីជាតិឱ្យស្ថិតស្ថេរគង់វង្ស
- ជួយផ្ដល់ឱ្យសហគមន៍នូវចំណេះដឹងថ្មីៗ និងបច្ចេកវិទ្យាទំនើប

- ជួយសម្រួលឱ្យសហគមន៍ធ្វើពិធីផ្សេងៗ ក្នុងសាលារៀនឱ្យបានច្រើន
- អនុញ្ញាតឱ្យប្រជាជនចូលរួមសកម្មភាពសាលារៀន
- ជាអ្នកឈានមុខផ្លាស់ប្តូរ ទំនៀមទម្លាប់អ្វីដែលអន់ថយ ការបំបាត់ជំនឿអរូបីផ្សេងៗ។

## ខ. សហគមន៍ជួយដល់សាលារៀន

- ជំរុញកូនចៅឱ្យទៅរៀនទៀងទាត់
- តាមដាន ត្រួតពិនិត្យកិច្ចការដែលគ្រូដាក់ឱ្យធ្វើ ឱ្យកូនធ្វើនៅផ្ទះ
- តាមដាន និងជួយបង្រៀនកូនចៅនៅផ្ទះ
- ទំនាក់ទំនងជាមួយគ្រូបង្រៀន នាយកសាលារៀន អំពីករណីសិស្សបោះបង់ ឬខិលខូច
- ជួយការងារស្ថិតិកុមារ និងជួយការកែលម្អបរិស្ថានសាលារៀន
- ចូលរួមធ្វើផែនការអភិវឌ្ឍសាលារៀន
- ចូលរួមការពារ យាមកាម ថែរក្សាការពារទ្រព្យសម្បត្តិសាលារៀន
- ចូលរួមចំណាយពលកម្មក្នុងការសាងសង់សាលារៀន
- ជួយជួសជុលអគារនិងគ្រឿងសង្ហារឹមក្នុងសាលា
- ចូលរួមដោះស្រាយសម្ភារបរិក្ខារ
- ចូលរួមសកម្មភាពបុណ្យទានផ្សេងៗ ដើម្បីប្រមូលថវិកាសាងសង់សាលារៀន
- ផ្តល់ទីកន្លែង សម្ភារដែលសាលារៀនត្រូវការ (ពេលទស្សនកិច្ចសិក្សា)
- ចូលរួមជាមួយសាលារៀន ដើម្បីកាត់បន្ថយអត្រាត្រួតថ្នាក់ និងបោះបង់ការសិក្សា
- ផ្តល់គំនិតយោបល់ មតិចូលរួមដែលមានប្រយោជន៍ដល់សាលារៀន ពិសេសនាយកសាលា
- ចូលរួមទប់ស្កាត់ កាត់បន្ថយភាពអនាធិបតេយ្យរបស់សិស្ស
- ផ្តល់អ្នកឯកទេសជំនាញផ្សេងៗឱ្យមកបង្ហាញសិស្ស អំពីជំនាញកសិកម្ម ពេទ្យសត្វ សុខភាព ច្បាប់ចរាចរណ៍ គ្រឿងញៀន។ល។

### គ. ទំនាក់ទំនងល្អជាមួយសហគមន៍[16]

- ផ្តល់ព័ត៌មានឱ្យសហគមន៍ មាតាបិតា អាណាព្យាបាលសិស្សឱ្យបានទាន់ពេលវេលា និងទៀងទាត់ពីការសិក្សារបស់សិស្ស នាំឱ្យសាលាទទួលបាននូវព័ត៌មានត្រឡប់សម្រាប់កែលម្អ បានទាន់ពេលវេលា
- សហគមន៍ចូលរួមជាមួយសាលារៀន
- សហគមន៍ផ្តល់ព័ត៌មានត្រឡប់ មតិយោបល់កែលម្អទាន់ពេលវេលា
- សហគមន៍ និងអ្នកពាក់ព័ន្ធចូលរួមគ្រប់សកម្មភាពអភិវឌ្ឍសាលារៀន
- ការរៀនប្រកបដោយប្រសិទ្ធភាព និងភាពកក់ក្តៅជាការចូលរួមយ៉ាងល្អពីសំណាក់សហគមន៍ និងមានការលើកទឹកចិត្ត ដើម្បីសម្រេចបានលទ្ធផលល្អ។

## ២.៥. តួនាទី និងភារកិច្ចរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀន[17]

សហគមន៍ និងសាលារៀនត្រូវស្គាល់ពីតួនាទីនិងភារកិច្ចរៀងៗខ្លួនហើយធ្វើទំនាក់ទំនងឬសកម្មភាពល្អជាមួយគ្នាដើម្បីបម្រើបុព្វហេតុឱ្យគ្នាទៅវិញទៅមក។ សហគមន៍ និងសាលារៀន គឺជាកោសិការបស់សង្គមជាតិដែលពុំអាចផ្តាច់ចេញពីគ្នាបានឡើយ។ សាលារៀនត្រូវបានបង្កើត និងកសាងឡើងដោយសហគមន៍ជារបស់សហគមន៍ ដូចនេះសាលារៀនពុំអាចអភិវឌ្ឍតែឯងបានដោយគ្មានការចូលរួមពីសហគមន៍បានឡើយ។

ចំណែកឯ សហគមន៍ពុំអាចមានភាពគង់វង្ស និងរឹងមាំរីកចម្រើនបានដោយគ្មានកម្លាំងចលករពីសាលារៀនបានឡើយ។ មានន័យថាសាលារៀនគឺជាស្ថាប័នប្រចាំសហគមន៍ ជាមជ្ឈមណ្ឌលសកម្មរបស់សហគមន៍សម្រាប់ធ្វើការអប់រំប្រជាជនគ្រប់វ័យតាំងពីក្មេងរហូតដល់ចាស់ ដែលមានកម្មវិធីសម្រាប់សិក្សាជារបៀបបណ្តុះពូជ និងរបៀបធ្វើការអភិវឌ្ឍសហគមន៍ឱ្យរីកចម្រើន ថ្លៃថ្នូរ សុភមង្គល។ ដើម្បីសម្រេចគោលដៅអប់រំជាតិក្នុងការអភិវឌ្ឍសាលារៀន សហគមន៍មានតួនាទី និងភារកិច្ចសំខាន់ៗដូចជា៖

---

[16] ឯកសារបណ្តុះបណ្តាលស្តីពីអភិបាលកិច្ចល្អសម្រាប់ពង្រឹងការផ្តល់សេវាអប់រំ ឆ្នាំ២០១២ ទំព័រ៣១

[17] ទំនាក់ទំនងរវាងសាលារៀននិងសហគមន៍ របស់ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ ២០០៩ ទំព័រ១៩-២៣

## ក. ការប្រមូលកុមារឱ្យចូលរៀន

- ឪពុកម្តាយនៅតាមគ្រួសារនីមួយៗ ត្រូវជួយរំលឹកគ្នាដោយឱ្យកូនចៅដែលគ្រប់អាយុសិក្សា ទៅចុះឈ្មោះចូលរៀនឱ្យបានទៀងទាត់ (ថ្នាក់មត្តេយ្យ ឬថ្នាក់ដំបូង បឋមសិក្សា)
- សហគមន៍ប្រមូលកុមារដែលនៅក្រៅសាលារៀន និងជួយទំនាក់ទំនងជាមួយឪពុកម្តាយ ដែលមិនបានឱ្យកូនចៅទៅរៀនដើម្បីឱ្យបានទៅរៀន។
- សហគមន៍ជួយប្រមូលនិងជួយបង្កលក្ខណៈងាយស្រួល ដើម្បីឱ្យកុមារកំព្រាទីទ័លក្រពិការបានរៀន។

## ខ. ការស្វែងរកចំណូល និងថវិកា

សាលារៀនដំណើរការល្អគឺអាស្រ័យដោយមានថវិកាទ្រទ្រង់។ ដូចនេះសហគមន៍ត្រូវចូលរួមយ៉ាងសកម្មក្នុងការស្វែងរកថវិកា សម្រាប់ជួយឧបត្ថម្ភដល់សាលារៀន។ សហគមន៍អាចចូលរួមយ៉ាងសកម្មក្នុងការស្វែងរកថវិកាសម្រាប់ទ្រទ្រង់ឧបត្ថម្ភសាលារៀនឱ្យដំណើរការល្អ តាមរយៈរូបភាពច្រើនយ៉ាង ដូចជាៈ

- បុណ្យទានផ្សេងៗ (បុណ្យផ្កា បុណ្យកឋិនទាន បុណ្យរស្មីសាមគ្គីជាតិ បុណ្យកម្សាន្តផ្សេងៗ បុណ្យអង្គាសបច្ច័យ ។ល។)
- ការស៊ីវិភាគទានជាប្រាក់ ជាស្រូវ ជាអង្ករ សម្ភារផ្សេងៗ
- ការប្រើទុនបង្កើន ឬទុនបង្វិលដោយទំនាក់ទំនងជាមួយសប្បុរសជន (គណៈកម្មការ អាចារ្យវត្តសហគមន៍ មាតាបិតាសិស្ស ក្រុមហ៊ុនផ្សេងៗ អ្នកមានទ្រព្យសម្បត្តិក្នុង និងក្រៅប្រទេស...)
- ការបង្កើតរមណីយដ្ឋានកន្លែងទេសចរធ្វើសិប្បកម្មសកម្មភាពសិល្បៈ និងសកម្មភាពផ្សេងៗទៀត
- ទំនាក់ទំនងជាមួយអង្គការជាតិ អន្តរជាតិ និងក្រៅរដ្ឋាភិបាល។

## គ. ការគ្រប់គ្រងថវិកា

- ថវិកាចំណូលត្រូវមានការកត់បញ្ជីច្បាស់លាស់ ទាំងចំណូល ទាំងចំណាយ ដោយបញ្ជាក់ពីប្រភពនិងកាលបរិច្ឆេទ ចំនួនថវិកា ឈ្មោះអ្នកដឹងឮ ឈ្មោះអ្នកទទួលស្គាល់។
- ថវិកាត្រូវថែរក្សា និងគ្រប់គ្រងដោយបុគ្គលស្មោះត្រង់ ដែលជ្រើសរើសដោយសហគមន៍ និងអ្នក

ដែលមានស្មារតីស្រឡាញ់ការអប់រំ។

- បញ្ជីចំណាយត្រូវមានបញ្ជាក់នូវប្រភេទចំណាយនិងចំនួនទឹកប្រាក់ កាលបរិច្ឆេទនិងភ្ជាប់ជាមួយនូវកំណត់ហេតុដែលអង្គប្រជុំបានសម្រេចឱ្យចំណាយ។
- ចំណូល និងចំណាយត្រូវផ្សព្វផ្សាយឱ្យគណៈកម្មការសហគមន៍ ឬសហគមន៍បានដឹងឮ។

## ឃ. ថែរក្សាទ្រព្យសម្បត្តិសាលារៀន

- សហគមន៍ត្រូវចាត់ទុកសាលារៀនជាទ្រព្យសម្បត្តិរួម ត្រូវចូលរួមការពារ និងយាមកាម។
- សហគមន៍ត្រូវគ្រប់គ្រងសត្វពាហនៈកុំឱ្យចូលក្នុងបរិវេណសាលារៀន។
- សហគមន៍តាមដាន មើលថែរក្សាសម្ភារសិក្សារបស់កូនចៅ ដែលសាលាបានឱ្យខ្ចីសម្រាប់ការរៀនសូត្រដូចជាសៀវភៅសិក្សាជាដើម។
- សហគមន៍ជួយជួសជុល ថែរក្សាទ្រព្យសម្បត្តិដែលសាលារៀនបានឱ្យខ្ចីក្នុងពេលមានរវល់ ដូចជាតុ កៅអី ពេលបុណ្យទានផ្សេងៗ។

## ង. ការចូលរួមក្នុងការសាងសង់ និងជួសជុលសាលារៀន

- សហគមន៍ជាកម្លាំងមិនចេះរីងស្ងួត
- ចូលរួមជួយឧបត្ថម្ភមជ្ឈមណ្ឌលធនធានកម្រងសាលានិងប្រើប្រាស់តាមសេចក្តីត្រូវការដើម្បីពង្រីកចំណេះដឹងរបស់ពួកគេ និងជួយដល់ការរៀនសូត្ររបស់កូនចៅពួកគេ។
- សហគមន៍ចូលរួមតាមកម្លាំងចិត្តនិងកម្លាំងកាយ សម្ភារ ថវិកាដើម្បីឧបត្ថម្ភក្នុងការសាងសង់អគារនិងជួយកែលម្អបរិស្ថានសាលារៀន។
- សហគមន៍ជួយចូលរួមថែរក្សា សម្ភារសំណង់ទាំងអស់ ដែលត្រូវដឹកនាំមកដល់កន្លែងសាងសង់។

## ច. ការបំផុសកូនចៅឱ្យទៅសាលារៀន

- ជួយរំលឹកជាប្រចាំនូវគ្រួសារណាដែលមានកូនដល់អាយុសិក្សាឱ្យទៅសាលារៀន។
- ជួយផ្តល់ព័ត៌មានអំពីកុមារដែលត្រូវចូលរៀន និងចំនួនកុមារដែលនៅក្រៅសាលា ដោយជួយដោះស្រាយតាមគ្រប់មធ្យោបាយ និងគ្រប់រូបភាព ដើម្បីឱ្យគេបានទៅសាលារៀន។

- ជួយផ្សព្វផ្សាយដល់ប្រជាជនឱ្យនាំកូនចៅទៅសាលារៀន តាមមធ្យោបាយផ្សេងៗ និងចូលរួមបើកបវេសនកាលរបស់សហគមន៍ មាតាបិតាសិស្ស។

## ឆ. ការតាមដានការសិក្សារៀនសូត្ររបស់សិស្ស

- ជួយអប់រំកូនបន្ថែម ជំរុញឱ្យខំរៀន បង្កលក្ខណៈទាំងសម្ភារ ថវិកា និងពេលវេលា ពិសេសកូនស្រី។
- ទាក់ទងជាមួយលោកគ្រូ អ្នកគ្រូ និងនាយកសាលា ឱ្យបានញឹកញាប់តាមរយៈលិខិត ឬផ្ទាល់មាត់ដើម្បីកាត់បន្ថយអត្រាត្រួតថ្នាក់ និងករណីសិស្សបោះបង់ការសិក្សា។
- ចូលរួមប្រជុំដើម្បីទទួលបានព័ត៌មានពីការសិក្សារបស់កូនចៅ។
- ជួយផ្តល់មតិយោបល់ដែលមានប្រយោជន៍ដល់សាលារៀនជាពិសេសជាមួយគណៈកម្មការគ្រប់គ្រងសាលារៀន។
- ជួយឧបត្ថម្ភដល់កុមារជួបការលំបាក និងផ្តល់បទពិសោធន៍ដល់ការបង្រៀនសិស្ស
- ជួយអប់រំផ្លូវចិត្ត អាកប្បកិរិយា និងសីលធម៌ សុជីវធម៌ដល់កុមារ យុវជន
- ជួយផ្តល់ជំនាញបច្ចេកទេស ក្នុងការអប់រំវិជ្ជាជីវៈដល់កុមារ និងយុវជន
- តាមដានត្រួតពិនិត្យការសិក្សារបស់កូននៅសាលារៀន និងជួយបង្រៀនកូននៅផ្ទះ
- ជួយឧបត្ថម្ភ និងផ្តល់នូវមូលដ្ឋានសម្ភារដែលមាននៅក្នុងមូលដ្ឋាន ដើម្បីបម្រើដល់សកម្មភាពរៀន និង បង្រៀនដល់កុមារ ដូចជាសម្ភារសម្រាប់ផលិត សម្ភារឧបទេស។

## ជ. ការចូលរួមកសាង អនុវត្តផែនការរបស់សាលារៀន និងការតាមដានត្រួតពិនិត្យ

- ចូលរួមចំណែកអនុវត្តផែនការរបស់សាលារៀនត្រួតពិនិត្យនិងវាយតម្លៃលើសកម្មភាពសាលារៀន
- ស្រង់ស្ថិតិកុមារពីអាយុ០-១៥ឆ្នាំ ពិសេសកុមារដល់វ័យសិក្សា អនក្ខរជន កុមារកំព្រាទីទ័លក្រ និងកុមារពិការ
- ស្រង់ស្ថិតិធនធានសម្ភារដែលបម្រើឱ្យការអប់រំនៅក្នុងមូលដ្ឋានស្រាប់ ដូចជា កន្លែងពិសោធន៍កសិកម្ម សម្បត្តិវប្បធម៌បុរាណ និងរមណីយដ្ឋានធម្មជាតិ។ល។
- ស្រង់ស្ថិតិការដ្ឋាន សិប្បកម្មដ្ឋាន ដូចជាតម្បាញ តុ ទូ ក្បាច់ចម្លាក់ គំនូរជាដើម ដែលជាចំណោះ

ដឹងបម្រើដល់សកម្មភាពរស់នៅប្រចាំថ្ងៃ។

### ឈ. ការពង្រឹង និងពង្រីកសមត្ថភាពយល់ដឹងអំពីការអភិវឌ្ឍសាលារៀន

- អភិវឌ្ឍសហគមន៍ គឺធ្វើឱ្យសហគមន៍រីកចម្រើនទាំងធនធានមនុស្ស និងធនធានសម្ភារ
- កាលណាមនុស្សចូលរួមច្រើន សង្គមដែលគេរស់នៅនេះនឹងសម្បូរទៅដោយអ្នកចេះដឹងអាចកែច្នៃមុខរបររកស៊ីឱ្យទទួលបានជីវភាពធូរធារ។ ប្រសិនបើជីវភាពរស់នៅបានធូរធារ នោះសង្គមនឹងសម្បូរទៅដោយសម្ភារប្រើប្រាស់ និងសម្បូរដោយប្រាក់កាសនោះសង្គមក្លាយទៅជាសង្គមដែលរីកចម្រើន។
- ពង្រីកទំនាក់ទំនងសាលារៀននិងសហគមន៍ពិសេសយកចិត្តទុកដាក់លើការកាត់បន្ថយភាពអនាធិបតេយ្យរបស់សិស្ស។

## ២.៦. ឥទ្ធិពលវិជ្ជមានរបស់មាតាបិតាលើការចូលរួមក្នុងការអប់រំកូន

តាមការស្រាវជ្រាវលើប្រសិទ្ធភាពនៃការចូលរួមរបស់អាណាព្យាបាលលើការអប់រំកូនបានបង្ហាញពីទំនាក់ទំនងវិជ្ជមាន ស្របគ្នារវាងភាពពាក់ព័ន្ធក្នុងការអប់រំកូន និងលទ្ធផលសិក្សារបស់កូន។ តាមការសិក្សាបង្ហាញដែរថា ការចូលរួមរបស់អាណាព្យាបាល គឺពាក់ព័ន្ធដល់លទ្ធផលសិក្សារបស់សិស្ស ដូចជាអត្រាបោះបង់ការសិក្សា និងអត្រាគេចសាលាមិនចូលរៀនមានកម្រិតទាប។ អ្នកស្រាវជ្រាវបានចាប់ផ្តើមផ្តោតលើការចូលរួមរបស់មាតាបិតាមានឥទ្ធិពលលើការសិក្សាក្នុងកម្រិតណានោះ និងមូលហេតុដែលមាតាបិតាមានទំនាក់ទំនង ឬមិនមានទំនាក់ទំនងលើការសិក្សារបស់កូន ហើយសាលារៀន និងគ្រូបានដើរតួយ៉ាងសំខាន់ក្នុងការបង្កើតទំនាក់ទំនងការចូលរួមនេះ[18]។

យោងតាមអត្ថបទរបស់លោកស្រី Wendy S. Grolnick 1994 -1995 ដែលបានបង្កើតទំហំ Three Dimensions នៃការចូលរួម ដោយផ្អែកលើការចូលរួមរបស់មាតាបិតា និងការមានទំនាក់ទំនងរវាងមាតាបិតា និងកូនៗបានធ្វើឱ្យមានឥទ្ធិពលលើការអប់រំ និងការលើកទឹកចិត្ត។ ទំនាក់ទំនងផ្ទាល់ខ្លួនរួមមានការ សហការគ្នារវាងសិស្ស និងមាតាបិតា ដើម្បីបង្កើតឥរិយាបថវិជ្ជមាន និងបានយល់ដឹងអំពី

[18] និក្ខេបបទ ណុប ពិដោរ ឆ្នាំ២០១៧ ទំព័រ ១១

សាលារៀន ព្រមទាំងសារៈសំខាន់នៃការអប់រំផងដែរ។ ការចូលរួមរបស់មាតាបិតាគឺមានភាពសំខាន់ណាស់ដែលបង្ហាញពីភាពជឿជាក់របស់មាតាបិតាអំពីតួនាទី និងការទទួលខុសត្រូវរបស់គាត់ចំពោះកូនៗក្នុងការជួយអប់រំណែនាំកូនបន្ថែម។ នៅពេលដែលមាតាបិតាមានទំនាក់ទំនងជាមួយសាលារៀន គឺជួយបង្កើនស្មារតី ការទទួលខុសត្រូវ ប្រកបដោយទំនុកចិត្ត ដែលពួកគេអាចទទួលបានជោគជ័យក្នុងការសិក្សា។

Joyce L. Epstein 1995 &1991 បានពន្យល់ក្នុងសៀវភៅរបស់គាត់ ដែលមានចំណងជើងថា «សាលារៀន គ្រួសារ ភាពជាដៃគូក្នុងសហគមន៍» ថាសាលារៀន គ្រួសារ និងសហគមន៍ គឺមានសារៈសំខាន់ទៅលើការអភិវឌ្ឍរបស់កូន។ លោក Epstein បានលើកទឹកចិត្តឱ្យសាលារៀនបង្កើតទំនាក់ទំនងរវាងសាលារៀន គ្រួសារ និងសហគមន៍ តាមរយៈការអនុវត្តនូវវិធីទាំងប្រាំមួយ (៦)មានផ្សេងៗគ្នាដូចជា៖ (១)ការអប់រំកូន, (២) ការទាក់ទង, (៣) ការស្ម័គ្រចិត្ត, (៤) ការរៀននៅផ្ទះ, (៥) ការសម្រេចចិត្ត និង (៦) កិច្ចសហការរវាងសហគមន៍។ តាមរយៈការអនុវត្តសកម្មភាពទាំងប្រាំមួយ នៃការចូលរួមនេះអ្នកអប់រំអាចជួយលើកកម្ពស់សមិទ្ធផលសិក្សារបស់សិស្ស និងបទពិសោធន៍នានា ក្នុងសាលារៀន។ ការសិក្សាបង្ហាញថាសិស្ស លក្ខណៈសម្បត្តិរបស់គ្រូ និងស្ថានភាពជីវភាពរបស់គ្រួសារ អាចធ្វើឱ្យប៉ះពាល់ដល់កម្រិតនៃការចូលរួមរបស់ពួកគេ។ លើសពីនេះទៅទៀតស្ថានភាពការងាររបស់គ្រួសារ មុខរបរ កម្រិតចំណេះដឹងនិងគ្រួសារដែលធ្វើការពេញម៉ោង ហើយមានទំនាក់ទំនងបានតិចតួចក្នុងការអប់រំកូនៗរបស់ពួកគាត់[19]។

## ២.៧. បញ្ហាប្រឈមនៃការចូលរួមរបស់សហគមន៍ និងតួនាទីរបស់សាលារៀន[20]

បញ្ហាប្រឈមសំខាន់ៗដែលរារាំង មាតាបិតាមិនសូវបានចូលរួមយ៉ាងសកម្មលើការអប់រំកូន រួមមាន៖ ឥរិយាបថរបស់គ្រូ និងស្ថានភាពគ្រួសារ ជីវភាពគ្រួសារ កម្រិតចំណេះដឹងរបស់មាតាបិតា។ បញ្ហាប្រឈមទាំងអស់នេះត្រូវ បានបកស្រាយដូចខាងក្រោម៖ ឥរិយាបថរបស់គ្រូ អាចជាបញ្ហាប្រឈមជាមួយមាតាបិតា។ តាមរយៈសៀវភៅ Epstein &Dauber(1991)បានរកឃើញថាបើប្រៀបធៀបរវាងគ្រូបង្រៀន

[19] និក្ខេបបទ ណុប ពិដោរ ឆ្នាំ២០១៧ ទំព័រ ១១

[20] និក្ខេបបទ ណុប ពិដោរ ឆ្នាំ២០១៧ ទំព័រ១៤

នៅអនុវិទ្យាល័យ និងគ្រូបង្រៀននៅបឋមសិក្សា បានបញ្ជាក់ថា ការចូលរួមរបស់មាតាបិតាមានសារៈសំខាន់សម្រាប់សិស្ស ផ្តល់ឱកាសច្រើនសម្រាប់ការសិក្សារបស់សិស្ស និងជួយមាតាបិតាក្នុងការចូលរួមលើការអប់រំកូន។ ការចូលរួមរបស់មាតាបិតាមួយចំនួនមានកម្រិតទាប នេះអាចជាលទ្ធផលដែលកើតចេញពីការយល់ដឹងរបស់ពួកគាត់នៅមានកម្រិត។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយគ្រួសារទាំងអស់តែងតែចង់ឱ្យកូនៗរបស់ពួកគេទទួលបានជោគជ័យក្នុងការសិក្សាហើយមិនមែនគ្រប់ក្រុមគ្រួសារទាំងអស់សុទ្ធតែមានធនធាន និងមានឱកាសដូចគ្នាដើម្បីរួមចំណែកក្នុងការអប់រំកូនៗឱ្យបានច្រើននោះទេ។ ជាពិសេសក្រុមគ្រួសារដែល មានជីវភាពខ្វះខាត ធ្វើការពេញម៉ោង ធ្វើការងារច្រើន គ្រួសារដែល មានចំណេះដឹងទាប និងគ្រួសារដែលមានកូនច្រើន។ ដូច្នេះហើយនេះគឺជាបញ្ហាប្រឈមដ៏ចម្បងចំពោះតួនាទី និងភារកិច្ចមាតាបិតាលើការអប់រំកូនចៅ។ វាពិតជាមានសារៈសំខាន់ណាស់ចំពោះសាលារៀនដែលចាំបាច់ ត្រូវស្វែងយល់ពីតម្រូវការរបស់គ្រួសារ ហើយពុះពារខិតខំធ្វើការងារទាំងនេះ។

សាលារៀនចាំបាច់ណាស់ត្រូវជម្នះរាល់បញ្ហាទាំងអស់នេះ ដោយផ្តល់ឱកាសឱ្យមានទំនាក់ទំនងគ្នារវាងសាលារៀនជាមួយនឹងគ្រួសារ ឬរវាងគ្រួសារជាមួយសាលារៀនតាមរយៈមធ្យោបាយគ្រប់បែបយ៉ាងដែលធ្វើឱ្យគ្រួសារសិស្សទាំងឡាយអាចយល់បាន ព្រមទាំងជានាឱ្យបានគ្រប់គ្រាន់ត្រឹមត្រូវ ចំពោះសហគមន៍ មាតាបិតា និងគណៈកម្មការផ្តល់ប្រឹក្សាសាលារៀន ដើម្បីផ្តល់ព័ត៌មានដល់គ្រួសារដែលមិនបានចូលរួមក្នុងការប្រជុំ ឬសិក្ខាសាលាផ្សេងៗ។ ចំណែកឯវិធីសាស្ត្រមួយទៀតដើម្បីជម្នះរាល់បញ្ហាប្រឈមទាំងនោះគឺត្រូវបង្កើនកម្រិតបណ្តុះបណ្តាលគ្រូ ដែលផ្តោតលើប្រធានបទស្តីពី ការចូលរួមរបស់សហគមន៍។

តាមការសិក្សាស្រាវជ្រាវចំនួន៥០ (១៩៩៥-២០០២) ស្តីអំពីការចូលរួមរបស់មាតាបិតា លើការអប់រំកូនបានបង្ហាញថាសិស្សដែលមានទំនាក់ទំនងជាមួយមាតាបិតាឬអាណាព្យាបានទទួលបានលទ្ធផលនៃការសិក្សាដូចជាៈ១)ទទួលបាននិទ្ទេសល្អនិងពិន្ទុល្អ ហើយបានចូលរៀនក្នុងកម្មវិធីសិក្សាកម្រិតខ្ពស់ទៀតផង, ២) បានឡើងថ្នាក់ និងទទួលបានកម្រិតសិក្សាល្អ, ៣) ការចូលរៀនបានទៀងទាត់, ៤) មាន

បំណិនក្នុងសង្គម និងមានអាកប្បកិរិយាល្អប្រសើរ និង ៥)ចេះសម្របខ្លួនក្នុងបរិយាកាសសាលារៀន និងសង្គម។ គ្រប់សិស្សទាំងអស់ដែលមានការចូលរួមពីមាតាបិតា ភាគច្រើនបានប្រឡងជាប់ ហើយព្រមទាំងបានចូលរៀនបន្តនៅក្រោយបញ្ចប់កម្រិតអនុវិទ្យាល័យឬវិទ្យាល័យ។

## ២.៨. យុទ្ធវិធីដើម្បីទាក់ទាញសហគមន៍ឱ្យចូលរួមអភិវឌ្ឍសាលារៀន

### ២.៨.១.យុទ្ធវិធីដើម្បីទាក់ទាញសហគមន៍ឱ្យចូលរួមក្នុងការអភិវឌ្ឍសាលារៀននៅបឋម និងមធ្យមសិក្សា[21]

**ក. ការរៀបចំគណៈកម្មការ និងក្រុមប្រឹក្សានានារបស់សាលារៀន**

នាយកសាលាត្រូវរៀបចំគណៈកម្មការនិងក្រុមប្រឹក្សានានារបស់សាលារៀនហើយអញ្ជើញសហគមន៍ដែលពាក់ព័ន្ធចូលរួមធ្វើជាសមាជិក។ គណៈកម្មការទាំងនោះមានដូចជា៖

- គណៈកម្មការទ្រទ្រង់សាលារៀន
- គណៈកម្មការទ្រទ្រង់ថ្នាក់រៀន
- គណៈកម្មការកម្រងសាលារៀន
- គណៈកម្មការវាយតម្លៃការងារបុគ្គលិក
- គណៈកម្មការទប់ស្កាត់បាតុភាពមិនប្រក្រតី និងអសកម្ម
- ក្រុមប្រឹក្សាបច្ចេកទេស
- ក្រុមប្រឹក្សាយុវជន
- ក្រុមប្រឹក្សាវិន័យ ។ល។

**ខ. ការផ្សព្វផ្សាយ**

ការផ្សព្វផ្សាយស្តីពីការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀន និងសារៈសំខាន់នៃការចូលរួមរបស់សហគមន៍ មានដូចជា៖

[21] ទំនាក់ទំនងរវាងសាលារៀននិងសហគមន៍ របស់ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ ២០០៩ ទំព័រ១៩-២៣

- ❖ **ខ្លឹមសារត្រូវផ្សព្វផ្សាយ**

- សារៈសំខាន់នៃទំនាក់ទំនងរវាងសាលារៀន និងសហគមន៍
- តួនាទី និងភារកិច្ចរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀន
- គោលការណ៍នៃការអភិវឌ្ឍទំនាក់ទំនងសាលារៀន និងសហគមន៍
- តម្រូវការ និងផែនការអភិវឌ្ឍសាលារៀន
- គោលដៅអប់រំជាតិ
- លិខិតណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ពាក់ព័ន្ធនឹងសហគមន៍
- ការទទួល និងការប្រើប្រាស់ថវិកា មានតម្លាភាព ត្រឹមត្រូវ
- លទ្ធផលសិក្សារបស់សិស្សឆ្នាំសិក្សាកន្លងមក( សិស្សប្រឡងជាប់ )
- បទពិសោធន៍របស់សហគមន៍នានាដែលបានចូលរួមអភិវឌ្ឍសាលារៀន។ល។

- ❖ **រូបភាពផ្សព្វផ្សាយ**

- ការប្រជុំ (នៅដើមឆ្នាំសិក្សា ដំណាច់ឆមាសទី១ និងដំណាច់ឆ្នាំ )
- ការចុះសាកសួរផ្ទាល់ដល់គ្រួសារសិស្ស
- ការអញ្ជើញមាតាបិតា សិស្សមកសាលារៀន
- ការបង្កើតសៀវភៅទំនាក់ទំនងជាមួយគ្រួសារសិស្ស( លេខទូរស័ព្ទ ឬសំបុត្រ )
- ការចូលរួមក្នុងកម្មវិធីបុណ្យផ្សេងៗ
- ផ្សព្វផ្សាយតាមបណ្ដាញអង្គភាពព័ត៌មាន បណ្ដាញសង្គម...។

**គ. ការកំណត់ផែនការ និងកម្មវិធីការងារ**

- កំណត់ពេលវេលា កាលបរិច្ឆេទ ប្រជុំជាមួយមាតាបិតាសិស្ស គណៈកម្មការ និងក្រុមប្រឹក្សាផ្សេងៗ

**ឃ. ការចាត់តាំងសកម្មភាពក្នុង និងក្រៅសាលា**

- ក្លឹបសិក្សា (នាយកអញ្ជើញសិស្សពូកែ មាតាបិតា យុវជន ដែលមានសមត្ថភាពចូលរួមចែករំលែក បទពិសោធន៍ល្អៗដល់សិស្សពេលទំនេរ ។

- ក្លឹបវប្បធម៌ (នាយកសាលាសហការជាមួយអាជ្ញាធរដែនដី អង្គការ ដើម្បីបង្រៀនសិស្សនូវ របាំង ភ្លេង តន្ត្រី ទំនៀមទម្លាប់ ប្រពៃណី ការដើរតួសម្តែង ល្បែងសិក្សា ជាដើម។
- ក្លឹបកីឡា(លេងកីឡា ហាត់ប្រាណ ល្បែងប្រជាប្រិយ ដោយមានការចូលរួមបង្រៀនដោយកីឡាករ ចាស់ៗ មានបទពិសោធន៍ )។

**ង. សិក្ខាសាលាការងារសហគមន៍**

- ផ្លាស់ប្តូរបទពិសោធន៍ ចែករំលែកបទពិសោធន៍ទៅវិញទៅមក
- ពង្រឹងឥទ្ធិពលសហគមន៍ឱ្យកាន់តែខ្លាំងក្លាដើម្បីមានការរីកចម្រើនប្រហាក់ប្រហែលគ្នាទូទាំង ប្រទេស
- ជួយផ្តល់យោបល់និងរិះរកគន្លឹះល្អៗដើម្បីពង្រឹងកម្លាំងអប់រំទាំង៣សាលារៀន គ្រួសារ និង សហគមន៍
- លើកកម្ពស់តួនាទី និងភារកិច្ចរបស់សហគមន៍ ក្នុងវិស័យអប់រំឱ្យបានកាន់តែទូលំទូលាយ
- លើកកម្ពស់ការទទួលខុសត្រូវ ក្នុងការអប់រំ មើលថែរក្សា និងបង្ហាត់បង្រៀនកូន នៅសហគមន៍
- បង្កើនតម្លាភាព រវាងសាលារៀន កម្រងសាលា និងសហគមន៍ ជាពិសេស ថវិកា សាលារៀន
- ពង្រីកទស្សនកិច្ចសិក្សា និងសកម្មភាពរបស់សហគមន៍(ការចូលរួមរបស់សហគមន៍)។

**ច. រៀបចំសកម្មភាព ឬព្រឹត្តិការណ៍ផ្សេងៗដើម្បីទាក់ទាញសហគមន៍**

- រៀបចំបុណ្យបវេសនកាល ដោយមានអញ្ជើញមាតាបិតា សហគមន៍ ព្រះសង្ឃ គណៈកម្មការ ទ្រទ្រង់សាលា
- រៀបចំពិធីចែករង្វាន់សិស្សពូកែះ មានអញ្ជើញមាតាបិតាសិស្ស សហគមន៍ចូលរួម ដើម្បីឱ្យដឹងលឺ ពីលទ្ធផលសិក្សារបស់កូនគាត់
- រៀបចំពិធីសម្ពោធអគារសិក្សា
- រៀបចំពិធីបុណ្យទិវាកុមារអន្តរជាតិ (០១ មិថុនា រាល់ឆ្នាំ)
- រៀបចំបុណ្យផ្សេងៗក្នុងសាលារៀន

- រៀបចំពិពណ៌ស្នាដៃសិស្ស
- រៀបចំការសម្ដែងសិល្បៈ
- រៀបចំការប្រកួតកីឡា
- រៀបចំទស្សនកិច្ចសិក្សា
- រៀបចំសកម្មភាព ពលកម្មផលិត និងសកម្មភាពសង្គម។

### ២.៨.២. យុទ្ធវិធីដើម្បីទាក់ទាញសហគមន៍ឱ្យចូលរួមអភិវឌ្ឍសាលារៀន[22]

**ក. ពង្រឹងការគ្រប់គ្រង និងដឹកនាំ នាយកសាលាត្រូវ៖**

- មានផែនការការងារច្បាស់លាស់
- មានការទទួលខុសត្រូវខ្ពស់ក្នុងការងារ
- មានតម្លាភាព (ស្មោះត្រង់)
- មានបំណិនក្នុងការទាក់ទាញកម្លាំងគ្រប់សមាសភាពពាក់ព័ន្ធ (មិនប្រកាន់បក្សពួក)។

**ខ. ផ្ដល់ជំនឿទុកចិត្ត  នាយកសាលាត្រូវផ្ដល់ជំនឿទុកចិត្តខ្ពស់តាមរយៈ**

- បង្កើនសមិទ្ធផលក្នុងសាលារៀនឱ្យបានច្រើន
- ធ្វើឱ្យលទ្ធផលការសិក្សារបស់សិស្សបានសម្រេចតាមចំណុចដៅប្រកបដោយគុណភាពគោរពឆន្ទៈរួម (មិនអត្តនោម័ត) និងមានឆន្ទៈខ្ពស់ក្នុងការសម្រេចចិត្ត
- មានការលះបង់ពេលវេលា និងមិនគិតពីផលប្រយោជន៍
- ផ្ដល់សិទ្ធិក្នុងការទទួលខុសត្រូវជូនអ្នកពាក់ព័ន្ធ
- រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងត្រឹមត្រូវ ពង្រឹងបំណិន ឈ្លាសវៃក្នុងការគ្រប់គ្រង
- មានចក្ខុវិស័យច្បាស់លាស់ និងរៀបចំផែនការអនុវត្តការងារត្រឹមត្រូវ
- ពង្រឹងការដឹកនាំរបស់ខ្លួនប្រកបដោយតម្លាភាព គណនេយ្យភាព និងយុត្តិធម៌

---

[22] ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ របស់ក្រសួងអប់រំ យុវជន និងកីឡា បោះពុម្ពឆ្នាំ ២០១៦ ទំ.១៧៤-១៧៩)

- ជំរុញការចុះពិនិត្យតាមដាន និងអធិការកិច្ចកែលម្អការបង្រៀន និងរៀនរបស់គេ។

**គ. បង្កលក្ខណៈដល់អ្នកពាក់ព័ន្ធចូលរួម នាយកសាលាគប្បី៖**

ផ្តល់ការគាំទ្រដល់សហគមន៍តាមរយៈការចូលរួមគ្រប់ពិធីបុណ្យនានារបស់សហគមន៍ ដើម្បីផ្សព្វផ្សាយ ព័ត៌មាននានា ការចូលរួមការងារសង្គមតាមសំណូមពរ ពីអាជ្ញាធរដែនដី និងការចូលរួមតាមតម្រូវការចាំបាច់ណាមួយរបស់គ្រួសារសិស្ស ឬសង្គម។

- ផ្តល់កិត្តិយសឱ្យសហគមន៍ចូលរួមជាគណៈអធិបតីក្នុងកម្មវិធីនានា ដែលនាយកសាលារៀបចំសកម្មភាព ឬព្រឹត្តិការណ៍ផ្សេងៗដែលជួយជំរុញឱ្យការអប់រំកុមារ និងយុវជនមានឆន្ទៈឆ្ពោះទៅរកការរីកចម្រើន ទាំងផ្លូវកាយ បញ្ញា និងចិត្តគំនិត។
- ផ្តល់ឱកាសឱ្យសហគមន៍ចូលរួមចំណែក ក្នុងការកសាងផែនការអភិវឌ្ឍសាលារៀន ផែនការសកម្មភាពរបស់សាលាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំព្រមទាំងចូលរួមការអប់រំស្តីពីបំណិនជីវិត និងចែករំលែកបទពិសោធន៍ល្អៗ។
- ចូលរួមក្នុងសកម្មភាពក្រៅថ្នាក់ ក្រៅសាលារៀន ដោយធ្វើទំនាក់ទំនងជាមួយឋានានុក្រមការងារគ្រប់លំដាប់ថ្នាក់ដើម្បីផ្តល់ឱកាសឱ្យសហគមន៍បានចូលរួមគ្រប់សកម្មភាព។

**ឃ. ទំនាក់ទំនងល្អជាមួយសហគមន៍**

នាយកសាលាដើរតួយ៉ាងសំខាន់ ដើម្បីធ្វើការទំនាក់ទំនងឱ្យបានល្អជាមួយសហគមន៍ រួមមាន៖ អាចារ្យវត្ត ព្រះសង្ឃ មាតាបិតា អាណាព្យាបាលសិស្ស មន្ត្រីអប់រំចូលនិវត្តន៍ អតីតសិស្សសាលា ក្រុមហ៊ុននានា អាជ្ញាធរដែនដី សហគមន៍ជាតិ និងអន្តរជាតិ។ ទំនាក់ទំនងនេះត្រូវព្យាយាមជួបតាមពេលវេលា សមស្រប ព្យាយាមសម្របសម្រួល ទាក់ទាញ ព្យាយាមបង្ហាញហេតុផល និងអត់ធ្មត់ចំពោះភាពមិនប្រក្រតីដែលកើតមានផ្សេងៗធ្វើយ៉ាងណាឱ្យពួកគាត់បានយល់ពីសារៈសំខាន់នៃការចូលរួមរបស់ពួកគាត់គ្រប់គ្នា ជាពិសេសសហគមន៍ មាតាបិតាឬ អាណាព្យាបាលសិស្សផ្ទាល់។

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវ បែបបរិមាណវិស័យ (Quantitative Research) ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវនៅក្នុងជំពូក១។

## ៣.២. ការជ្រើសរើសភាគសំណាក

ក្នុងការជ្រើសរើសសំណាក អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីគឺ ការជ្រើសរើសដោយមិនចៃដន្យ (Non Probability Sampling)។ ក្នុងការជ្រើសរើសសំណាកនេះដំបូងគឺធ្វើការបែងចែកជាក្រុម ឬការជ្រើសរើសជាក្រុម (Cluster Sampling)ជា៣តំបន់ គឺប្រជុំជនខ្លាំង ០២វិទ្យាល័យ ប្រជុំជនមធ្យមមាន ០៤វិទ្យាល័យ និងជនបទ០៤វិទ្យាល័យក្នុងចំណោម២០វិទ្យាល័យក្នុងខេត្តស្វាយរៀង។ ចំពោះស្រុកនិងសាលាប្រើវិធី Purposive Sampling។ ចំណែកឯមាតាបិតាសិស្ស និងអាជ្ញាធរដែនដី/គណៈកម្មការទ្រទ្រង់សាលាប្រើវិធី Purposive Sampling ដែរ។ ការសិក្សា ស្រាវជ្រាវនេះបានជ្រើសរើសយកខេត្តស្វាយរៀងដើម្បីសិក្សា និងប្រមូលទិន្នន័យ។ នៅក្នុងខេត្តស្វាយរៀងមាន ក្រុង/ស្រុកចំនួន០៨ ហើយមាន៨០ ឃុំ/សង្កាត់ ៦៩០ភូមិ និងមានវិទ្យាល័យចំនួន២០។ ខាងក្រោមនេះគឺជាឈ្មោះវិទ្យាល័យទាំង២០ដែលមាន ទីតាំងនៅក្នុងស្រុក/ក្រុង ក្នុងខេត្តស្វាយរៀង។

*តារាង 1 ៖ ឈ្មោះវិទ្យាល័យក្នុងខេត្តស្វាយរៀង*

| ល.រ | ឈ្មោះស្រុក | ល.រ | ឈ្មោះវិទ្យាល័យ |
|---|---|---|---|
| ១ | ចន្ទ្រា | ១ | ប៊ុន រ៉ានី ហ៊ុនសែន ចន្ទ្រា |
| ២ | កំពង់រោទិ៍ | ២ | ហ៊ុន សែន កំពង់រោទិ៍ |
| | | ៣ | មិត្តភាព កម្ពុជាវៀតណាម ព្រះពន្លា |
| ៣ | រំដួល | ៤ | ហ៊ុន សែន កំពង់ចក |

| | | | |
|---|---|---|---|
| | | ៥ | ហ៊ុន សែន ពងទឹក |
| | | ៦ | កំពង់ សំរោង |
| ៤ | ស្វាយទាប | ៧ | ហ៊ុន សែន ប្រសូតិ៍ |
| | | ៨ | ហ៊ុន សែន ស្វាយរំពារ |
| ៥ | រមាសហែក | ៩ | រមាសហែក |
| | | ១០ | ហ៊ុន សែន ជ្រៃធំ |
| | | ១១ | សម្តេច ជា ស៊ីម អំពិល |
| ៦ | ស្វាយជ្រំ | ១២ | ហ៊ុន សែន ស្វាយជ្រំ |
| | | ១៣ | ហ៊ុន សែន ក្រោលគោ |
| | | ១៤ | ហ៊ុន សែន សាមគ្គីដូនស |
| | | ១៥ | ពោធិ៍ធំ |
| | | ១៦ | គោកព្រីង |
| ៧ | ស្វាយរៀង | ១៧ | ស្វាយរៀង |
| | | ១៨ | ហ៊ុន សែន ចេក |
| ៨ | បាវិត | ១៩ | ជីភូ |
| | | ២០ | ចំណេះទូទៅ និងបច្ចេកទេសបាវិត |

ភាគសំណាកសម្រាប់ការសិក្សាស្រាវជ្រាវនេះរួមមានសិស្សានុសិស្សដែលកំពុងសិក្សាក្នុងឆ្នាំសិក្សា ២០២០-២០២១ ចំនួន៤០០នាក់ លោកគ្រូ អ្នកគ្រូចំនួន១០០នាក់ នាយកសាលាចំនួន២០នាក់ និង សហគមន៍ (មាតាបិតា ១០០នាក់ និងអាជ្ញាធរដែនដី២០នាក់)។ ក្នុងមួយវិទ្យាល័យអ្នកសិក្សា នឹងជ្រើសរើសយក សិស្សានុសិស្សចំនួន៤០នាក់ លោកគ្រូ អ្នកគ្រូចំនួន១០នាក់ និងនាយក/នាយករង ចំនួន០២ នាក់ ចំណែកឯសហគមន៍(មាតាបិតាសិស្ស១០នាក់ និងអាជ្ញាធរ២នាក់) ។ ភាគសំណាកនេះត្រូវបាន

ជ្រើសរើសចេញពីវិទ្យាល័យចំនួន១០ ក្នុងស្រុក/ក្រុងចំនួន០៥ ដែលស្ថិតនៅក្នុងខេត្តស្វាយរៀង។ សូមបញ្ជាក់ថានៅក្នុងខេត្តស្វាយរៀងមានវិទ្យាល័យចំនួន២០ដែលមានទីតាំងក្នុងស្រុក/ក្រុងចំនួន០៨។

❖ ការជ្រើសរើសភាគសំណាកនេះមាននៅក្នុងស្រុក/ក្រុង៖

*តារាង 2 ៖ ការជ្រើសរើសសំណាក*

| ល.រ | ស្រុក/ក្រុង | ឈ្មោះវិទ្យាល័យ | សិស្ស | គ្រូ | នាយក | សហគមន៍ | អាជ្ញាធរ |
|---|---|---|---|---|---|---|---|
| ១ | រំដួល | ហ៊ុន សែន កំពង់ចក | ៤០ | ១០ | ២ | ១០ | ២ |
| ២ | | កំពង់ សំរោង | ៤០ | ១០ | ២ | ១០ | ២ |
| ៣ | ស្វាយជ្រំ | ហ៊ុន សែន ស្វាយជ្រំ | ៤០ | ១០ | ២ | ១០ | ២ |
| ៤ | | ហ៊ុនសែន សាមគ្គីដូនស | ៤០ | ១០ | ២ | ១០ | ២ |
| ៥ | | ហ៊ុន សែន ក្រោលគោ | ៤០ | ១០ | ២ | ១០ | ២ |
| ៦ | ស្វាយរៀង | ស្វាយរៀង | ៤០ | ១០ | ២ | ១០ | ២ |
| ៧ | | ហ៊ុន សែន ចេក | ៤០ | ១០ | ២ | ១០ | ២ |
| ៨ | រមាសហែក | រមាសហែក | ៤០ | ១០ | ២ | ១០ | ២ |
| ៩ | | ជ្រៃធំ | ៤០ | ១០ | ២ | ១០ | ២ |
| ១០ | កំពង់រោទិ៍ | ហ៊ុន សែន កំពង់រោទិ៍ | ៤០ | ១០ | ២ | ១០ | ២ |
| **សរុប** | | | **៤០០** | **១០០** | **២០** | **១០០** | **២០** |

ចំពោះការជ្រើសរើសភាគសំណាក គឺជ្រើសរើសយកវិទ្យាល័យចំនួន១០ ដែលស្ថិតនៅស្រុក/ក្រុង ចំនួន ០៥ក្នុងខេត្តស្វាយរៀង ដែលការជ្រើសរើសនេះ គឺស្របទៅតាមសមត្ថភាព លទ្ធភាពរបស់អ្នកសិក្សា និងជាពិសេសបញ្ហាស្ថានភាព ជំងឺ Covid-19។ ចំពោះការជ្រើសរើសភាគសំណាកនេះដែរ អ្នកសិក្សាមានគោលបំណង សម្រេចចិត្ត ជ្រើសរើសយកវិទ្យាល័យ ដែលស្ថិតនៅក្នុង ស្រុក/ក្រុងដែលមានទីប្រជុំជនខ្លាំង មធ្យម និងជនបទ ដើម្បី សិក្សាពីកម្រិតនៃការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។ ការជ្រើសរើស ស្រុក/ក្រុងចំនួន០៥ ក្នុងចំណោម ស្រុក/ក្រុង០៨ គឺស្មើនឹង ៦២.៥% ការជ្រើសរើសវិទ្យាល័យចំនួន១០ ក្នុងចំណោម២០ គឺស្មើនឹង ៥០%។

## ៣.៣. ឧបករណ៍ស្រាវជ្រាវ

ចំពោះឧបករណ៍ស្រាវជ្រាវគឺកម្រងសំណួរ។ អ្នកស្រាវជ្រាវបានរៀបចំបង្កើតជាកម្រងសំណួរមានលក្ខណៈជាសំណួរជ្រើសរើស (គ្រីស) ដែលមានទម្រង់ជាលក្ខណៈសំណួរបិទ និងសំណួរលក្ខណៈជាទម្រង់បើក ដែលអនុញ្ញាត ឱ្យអ្នកឆ្លើយអាចបញ្ចេញមតិយោបល់បាន។ អ្នកស្រាវជ្រាវបានបែងចែក កម្រងសំណួរជា ០៥ ប្រភេទផ្សេងៗគ្នា គឺសម្រាប់សិស្ស សម្រាប់លោកគ្រូ អ្នកគ្រូ សម្រាប់នាយកសាលា សម្រាប់មាតាបិតាសិស្ស និងសម្រាប់អាជ្ញាធរដែនដី។ កម្រងសំណួរសម្រាប់សិស្សគឺជ្រើសរើសយក ថ្នាក់ទី១០, និងថ្នាក់វិទ្យាសាស្ត្រទី១១,១២ ក្នុងឆ្នាំសិក្សា២០២០-២០២១ លោកគ្រូ អ្នកគ្រូដែលកំពុងបង្រៀននៅមធ្យមសិក្សាទុតិយភូមិក្នុងឆ្នាំសិក្សា២០២០-២០២១ ព្រមទាំងនាយក/នាយករង និងសហគមន៍ (មានមាតាបិតា ឬអាណាព្យាបាល និងអាជ្ញាធរដែនដី)។

ក្នុងការរៀបចំបង្កើតជា កម្រងសំណួរ អ្នកស្រាវជ្រាវបានធ្វើការរៀបចំ និងធ្វើការកែសម្រួលពីកម្រងសំណួរពីរបស់ លោកសុខ ផល្លា, លោកស្រី ណុប ពិដោរ និងលោកក្រូច ពុទ្ធី(ក្រូចពុទ្ធី,2018)។ អ្នកសិក្សាស្រាវជ្រាវ បានធ្វើការកែសម្រួលចំណុចមួយចំនួន ព្រមទាំងបន្ថែមចំណុចខ្លះទៀតដើម្បី ឱ្យស្របទៅនឹងប្រធានបទ របស់អ្នកស្រាវជ្រាវ។

### ៣.៣.១. កម្រងសំណួរសម្រាប់សិស្ស

ចំពោះកម្រងសំណួរដែលបានសួរទៅសិស្សានុសិស្សថ្នាក់ទី១០,និងថ្នាក់ទី១១,១២ វិទ្យាសាស្ត្រដែលបានចែកចេញជា ០៤ផ្នែកធំៗ និងមានសំណួរចំនួន៣០៖

ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន៖ ក្នុងផ្នែកនេះមាន០៨សំណួរហើយអ្នកស្រាវជ្រាវចង់ដឹងពីភេទ, អាយុជាសិស្សថ្នាក់ទីប៉ុន្មាន,កម្រិតការសិក្សារបស់ឪពុកម្ដាយ, និងប្រាក់ចំណូលរបស់ឪពុកម្ដាយ, មុខរបរ, ចំណាយ ពេលក្នុងការសិក្សា របស់សិស្សានុសិស្ស។

ផ្នែកទី២ អំពីការសិក្សាផ្ទាល់ខ្លួន(កត្តាខាងក្នុង/ក្រៅខ្លួន)៖ ផ្នែកនេះមាន១៦សំណួរ ហើយអ្នកសិក្សា ចង់ដឹងពីកម្រិតនៃការចូលចិត្តការសិក្សា កម្រិតនៃការដាក់កិច្ចផ្ទះ និងបានត្រួតពិនិត្យរបស់គ្រូ

កម្រិតនៃការធ្វើកិច្ចការផ្ទះរបស់សិស្ស កម្រិតនៃការរំលឹកមេរៀនឡើងវិញបន្ទាប់ពីរៀនរួច កម្រិតនៃការចូលបណ្ណាល័យទាក់ទងការសិក្សា កម្រិតនៃការខិតខំរៀនសូត្រដើម្បីប្រឡងជាប់របស់សិស្ស កម្រិតនៃការដឹងពីលទ្ធផលសិក្សារបស់សិស្ស កម្រិតនៃការជម្រុញសិស្សឱ្យអនុវត្តមេរៀនរបស់គ្រូ កម្រិតនៃការសរសើររបស់គ្រូនៅពេលសិស្សឆ្លើយត្រូវ កម្រិតនៃការបង្រៀនបន្ថែមនៅពេលសិស្សរៀនយឺត កម្រិតនៃការផ្តល់ពេលវេលារបស់ឪពុកម្តាយឱ្យកូនរៀន កម្រិតនៃការផ្តល់លុយឱ្យកូនក្នុងការសិក្សា កម្រិតនៃការលើកទឹកចិត្តរបស់ឪពុកម្តាយ កម្រិតនៃការពន្យល់មេរៀនរបស់ឪពុកម្តាយ កម្រិតនៃការសួរបងប្អូនសិស្សច្បងកម្រិតនៃការចូលបណ្ណាល័យដើម្បីអានក្នុងការធ្វើកិច្ចការផ្ទះ។

ផ្នែកទី៣ អំពីទំនាក់ទំនង៖ ផ្នែកនេះមាន០៣សំណួរហើយអ្នកសិក្សាចង់ដឹងពីកម្រិតនៃការទំនាក់ទំនងរបស់សិស្សជាមួយ មិត្តភក្តិ លោកគ្រូ អ្នកគ្រូ នាយក, កម្រិតនៃការទំនាក់ទំនងជាមួយមាតាបិតា សហគមន៍ និងកម្រិតនៃការចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយពីការអប់រំផ្សេងៗរបស់សិស្ស។

ផ្នែកទី៤ បញ្ហាប្រឈម និងសំណូមពរ៖ ផ្នែកនេះមាន០៣សំណួរ។ អ្នកសិក្សាចង់ដឹងអំពីកត្តាដែលនាំឱ្យប៉ះពាល់ដល់ការសិក្សា និងសំណួរលក្ខណៈបើកចំនួន២និងសំណូមពរ។

### ៣.៣.២. កម្រងសំណួរសម្រាប់លោកគ្រូ អ្នកគ្រូ

ចំពោះកម្រងសំណួរសម្រាប់លោកគ្រូអ្នកគ្រូ ត្រូវបានចែកចេញជា០៤ផ្នែកធំៗ ដែលមានសំណួរចំនួន២៤៖

ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន៖ នៅក្នុងផ្នែកនេះមានសំណួរចំនួន០៥ ហើយអ្នកស្រាវជ្រាវចង់ដឹងពី ភេទ អាយុ កម្រិតវប្បធម៌ បទពិសោធន៍ការងារ ការចំណាយពេលលើការងារបង្រៀនរបស់ពួកគាត់។

ផ្នែកទី២ អំពីការងារបង្រៀន៖ នៅក្នុងផ្នែកនេះមានសំណួរចំនួន១០ ហើយអ្នកសិក្សាចង់ដឹងអំពីកម្រិតនៃការអនុវត្តជំហានទាំង៥នៃវិធីសាស្រ្តបង្រៀន កម្រិតនៃការរកវិធីសាស្រ្តបង្រៀនដែលល្អ កម្រិតនៃចំណេះដឹងវិជ្ជាជីវៈ កម្រិតនៃការដាក់កិច្ចការផ្ទះនិងការត្រួតពិនិត្យ កម្រិតនៃការចូលបណ្ណាល័យ កម្រិតនៃការដាក់ពិន្ទុ កម្រិតនៃការគោរពវិន័យរបស់លោកគ្រូ អ្នកគ្រូ។

❖ ការលើកទឹកចិត្តចំពោះសិស្ស៖ នៅក្នុងផ្នែកនេះមាន សំណួរចំនួន០៣ ហើយអ្នកសិក្សាចង់ដឹងអំពីកម្រិតនៃការជម្រុញលើកទឹកចិត្តសិស្ស កម្រិតនៃការសរសើរសិស្សនៅពេលសិស្សឆ្លើយត្រូវ កម្រិតនៃការបង្រៀនបន្ថែមនិងលើកទឹកចិត្តដល់សិស្សរៀនយឺត របស់លោកគ្រូ អ្នកគ្រូ។

ផ្នែកទី៣ អំពីការទំនាក់ទំនង៖ នៅក្នុងផ្នែកនេះមានសំណួរចំនួន០៤ អ្នកសិក្សាចង់ដឹងអំពីកម្រិតនៃការទំនាក់ទំនងជាមួយនាយក គ្រូៗ សិស្ស កម្រិតនៃការទំនាក់ទំនងជាមួយមាតាបិតាសិស្ស កម្រិតនៃការផ្តល់ព័ត៌មានដល់មាតាបិតាសិស្ស និងកម្រិតនៃការចូលរួមកម្មវិធីផ្សេងៗទាក់ទងការអប់រំក្នុងសាលា និងសហគមន៍របស់លោកគ្រូ អ្នកគ្រូ។

ផ្នែកទី៤ បញ្ហាប្រឈម និងសំណូមពរ៖ នៅក្នុងផ្នែកនេះមាន សំណួរចំនួន០៥ ហើយអ្នកសិក្សាចង់ដឹងអំពី កត្តាដែលធ្វើឱ្យប៉ះពាល់ដល់ការបង្រៀន របស់លោកគ្រូ អ្នកគ្រូ សំនួរបើក៤ និងសំណូមពរ។

## ៣.៣.៣. កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង

ចំពោះកម្រងសំណួរសម្រាប់គណៈគ្រប់គ្រង ត្រូវបានចែកចេញជា០៤ផ្នែកធំៗ ដែលមានសំណួរចំនួន៣៤៖

ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន៖ ក្នុងផ្នែកនេះមាន០៥សំណួរ ហើយអ្នកសិក្សាស្រាវជ្រាវចង់ដឹងអំពីភេទ អាយុ កម្រិតវប្បធម៌ តួនាទី ការចំណាយពេលលើការងារគ្រប់គ្រង របស់ពួកគាត់។

ផ្នែកទី២ ដំណើរការគ្រប់គ្រងសាលារៀនលើ០៤ផ្នែកគឺ ការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងបច្ចេកទេស ការគ្រប់គ្រងថវិកា ការគ្រប់គ្រងបុគ្គលិក៖ ក្នុងផ្នែកនេះមាន២២សំណួរ ហើយអ្នកសិក្សាស្រាវជ្រាវចង់ដឹងអំពី កម្រិតនៃការលើកទឹកចិត្តបុគ្គលិក សិស្ស ឱ្យអនុវត្តតាមបទបញ្ជា កម្រិតនៃការលើកទឹកចិត្ត គ្រូបង្រៀនឱ្យបំពេញការងារ កម្រិតនៃការបែងចែកសិស្សតាមថ្នាក់នីមួយៗគោរពតាមនិយាម កម្រិតនៃការគោរពលក្ខខណ្ឌការងារ កម្រិតនៃការជម្រុញឱ្យក្រុមបច្ចេកទេសនីមួយៗផលិតសម្ភារឧបទេស កម្រិតនៃការលើកទឹកចិត្តស្រាវជ្រាវរកវិធីសាស្ត្របង្រៀនថ្មីៗ កម្រិតនៃការចុះអធិការកិច្ចគ្រូ កម្រិតនៃការរៀបចំបង្កើតក្លឹបសិក្សា កម្រិតនៃការលើកទឹកចិត្តឱ្យគ្រូស្វ័យសិក្សា កម្រិតនៃការគ្រប់គ្រងថវិកា កម្រិតនៃការប្រើ

ប្រាស់ថវិកា កម្រិតនៃការរាយការណ៍ពីការចាយវាយដល់គណៈកម្មការផ្សេងៗ កម្រិតនៃការលើកទឹកចិត្តបុគ្គលិកជួយស្វែងរកដៃគូអភិវឌ្ឍសាលា កម្រិតនៃការប្រើប្រាស់ថវិកាតាមផែនការប្រចាំឆ្នាំ កម្រិតនៃការប្រើប្រាស់ថវិកាដល់បុគ្គលិក កម្រិតនៃការលើកទឹកចិត្តបុគ្គលិកពេលជួបបញ្ហាផ្សេងៗ កម្រិតនៃការបែងចែកតួនាទីបុគ្គលិក កម្រិតនៃការលើកទឹកចិត្តឱ្យបុគ្គលិកមានទំនាក់ទំនងល្អក្នុងអង្គភាព កម្រិតនៃការជម្រុញលើកទឹកចិត្តបុគ្គលិកឱ្យបំពេញភារកិច្ចប្រកបដោយមនសិការ កម្រិតនៃការចាត់ចែងបែងចែកការងារដល់បុគ្គលិក កម្រិតនៃការតាមដានការបំពេញការងាររបស់បុគ្គលិក កម្រិតនៃការជម្រុញឱ្យគ្រូៗចូលរួមក្នុងការងារសង្គម។

ផ្នែកទី៣ អំពីការទំនាក់ទំនងៈ នៅក្នុងផ្នែកនេះមាន០៤សំណួរ ហើយអ្នកសិក្សាស្រាវជ្រាវចង់ដឹងអំពី កម្រិតនៃការទំនាក់ទំនងជាមួយមាតាបិតា សហគមន៍ កម្រិតនៃភាពងាយស្រួលទំនាក់ទំនងជាមួយសហគមន៍ កម្រិតនៃការទាក់ទាញសហគមន៍ របស់លោកនាយក នាយករង។

ផ្នែកទី៤ បញ្ហាប្រឈម និងសំណូមពរ ៖ក្នុងផ្នែកនេះមាន០៣សំណួរ ហើយអ្នកសិក្សាស្រាវជ្រាវចង់ដឹងអំពីបញ្ហាប្រឈមលើការគ្រប់គ្រង កត្តាដែលនាំឱ្យទំនាក់ទំនងរវាងសហគមន៍ មាតាបិតាសិស្សនិងសាលារៀនមិនសូវបានល្អ វិធីដើម្បីទាក់ទាញសហគមន៍ចូលរួមជាមួយសាលាក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស (សំណួរបើកទាំង៣)។

### ៣.៣.៤. កម្រងសំណួរសម្រាប់មាតាបិតាសិស្ស/អាណាព្យាបាលសិស្ស

ចំពោះកម្រងសំណួរសម្រាប់មាតាបិតា/អាណាព្យាបាលសិស្ស ត្រូវបានចែកចេញជា ០៤ផ្នែកធំៗដែលមានសំណួរចំនួនៈ

ផ្នែកទី១ព័ត៌មានផ្ទាល់ខ្លួនៈក្នុងផ្នែកនេះមាន០៧សំណួរហើយអ្នកសិក្សាស្រាវជ្រាវចង់ដឹងអំពីភេទ អាយុ កូនរៀនថ្នាក់ទី កម្រិតវប្បធម៌ មុខរបរ ប្រាក់ចំណូល ការចំណាយលុយលើការសិក្សាកូនពួកគាត់។

ផ្នែកទី២ អំពីការតាមដានការសិក្សារបស់កូនៈ ក្នុងផ្នែកនេះមាន១០សំណួរ ហើយអ្នកសិក្សាស្រាវជ្រាវចង់ដឹងអំពី កម្រិតនៃការបញ្ជូនកូនទៅរៀន កម្រិតនៃការពិនិត្យតាមដានការរៀននិងកិច្ចការផ្ទះរបស់

កូន កម្រិតនៃការចំណាយពេលវេលាឱ្យកូនរៀន កម្រិតនៃការធ្វើទំនាក់ទំនងជាមួយគ្រូ នាយកកម្រិតនៃការដឹងពីលទ្ធផលសិក្សារបស់កូន កម្រិតនៃការចំណាយថវិកាលើការសិក្សារបស់កូន កម្រិតនៃការជម្រុញឱ្យកូនខំរៀន កម្រិតនៃការសរសើរកូន កម្រិតនៃការបង្រៀនកូនបន្ថែម កម្រិតនៃការជម្រុញកូនឱ្យខំរៀនរបស់ពួកគាត់។

ផ្នែកទី៣ អំពីការទំនាក់ទំនង៖ នៅក្នុងផ្នែកនេះមាន សំណួរចំនួន០៤ អ្នកសិក្សាចង់ដឹងអំពីកម្រិតនៃការមានទំនាក់ទំនងជាមួយកូន កម្រិតនៃការមានទំនាក់ទំនងជាមួយលោកគ្រូ អ្នកគ្រូ នាយកសាលា កម្រិតនៃការចូលរួមកម្មវិធីផ្សេងៗទាក់ទងការអប់រំ កម្រិតនៃការធ្វើផែនការអភិវឌ្ឍសាលារបស់មាតាបិតាសិស្ស ។

ផ្នែកទី៤ បញ្ហាប្រឈម និងសំណូមពរ៖ នៅក្នុងផ្នែកនេះមានសំណួរចំនួន ០៤អ្នកសិក្សាស្រាវជ្រាវចង់ដឹងអំពី បញ្ហាប្រឈមរបស់មាតាបិតាសិស្ស សំណួរបើកចំនួន០៣ (កត្តាដែលនាំឱ្យប៉ះពាល់ដល់លទ្ធផលសិក្សារបស់សិស្ស ចង់ដឹងពីការចូលរួមរបស់មាតាបិតាដើម្បីឱ្យលទ្ធផលសិក្សារបស់សិស្សប្រសើរឡើង វិធីដែលសាលាអាចទាក់ទាញឱ្យមាតាបិតាសិស្សចូលរួមជាមួយសាលាក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់កូនពួកគាត់) និងសំណូមពរ។

### ៣.៣.៥. កម្រងសំណួរសម្រាប់អាជ្ញាធរ

ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន៖ ក្នុងផ្នែកនេះមាន០៥សំណួរ ហើយអ្នកសិក្សាស្រាវជ្រាវចង់ដឹងអំពី ភេទ អាយុ កម្រិតវប្បធម៌ មុខងារ បទពិសោធន៍ការងារ របស់ពួកគាត់។

ផ្នែកទី២ អំពីការចូលរួមអភិវឌ្ឍសាលារៀន៖ នៅក្នុងផ្នែកនេះមាន ១០សំណួរ ហើយអ្នកសិក្សាស្រាវជ្រាវចង់ដឹងអំពី កម្រិតនៃការចូលរួមធ្វើផែនការអភិវឌ្ឍសាលា កម្រិតនៃការតាមដានការបំពេញការងាររបស់គ្រូ កម្រិតនៃការចូលរួមកម្មវិធីផ្សេងៗក្នុងសាលា កម្រិតនៃការយកបញ្ហានៃការអប់រំទៅពិភាក្សានៅអង្គភាពប្រជុំ កម្រិតនៃការចូលរួមលុបបំបាត់បាតុភាពមិនល្អជុំវិញសាលា កម្រិតនៃការចូលរួមផ្សព្វផ្សាយដល់សហគមន៍ឱ្យបញ្ជូនកូនទៅរៀន កម្រិតនៃការសហការជាមួយអង្គការជាតិ អន្តរជាតិដើម្បី

អភិវឌ្ឍសាលា កម្រិតនៃសហការជាមួយក្រសួង ស្ថាប័នផ្សេងដើម្បីការអប់រំ កម្រិតនៃការចូលរួមអភិវឌ្ឍសាលា កម្រិតនៃការលើកផែនការនៅអង្គភាពរបស់លោក លោកស្រីទាក់ទងការអប់រំ។

ផ្នែកទី៣ អំពីការទំនាក់ទំនង៖ នៅក្នុងផ្នែកនេះមាន ០៣សំណួរ ហើយអ្នកសិក្សាស្រាវជ្រាវចង់ដឹងអំពី កម្រិតនៃការទំនាក់ទំនងជាមួយគ្រូនិងនាយក កម្រិតនៃការទទួលបានព័ត៌មានផ្សេងៗទាក់ទងកូន កម្រិតនៃការដឹងពីលទ្ធផលសិក្សារបស់សិស្ស ប្រចាំខែ ឆមាស ឆ្នាំ របស់ពួកគាត់។

ផ្នែកទី៤ បញ្ហាប្រឈម និងសំណូមពរ៖ នៅក្នុងផ្នែកនេះមានសំណួរចំនួន០៣ អ្នកសិក្សាស្រាវជ្រាវចង់ដឹងអំពី បញ្ហាប្រឈមដែលមាតាបិតាមិនសូវបានចូលរួមក្នុងការសិក្សារបស់កូន កត្តាដែលនាំឱ្យប៉ះពាល់ដល់ការសិក្សារបស់សិស្ស បញ្ហាប្រឈមរបស់អាជ្ញាធរ ការចូលរួមរបស់អាជ្ញាធរក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស (សំណួរទាំង០២នេះជាសំណួរបើក)និងសំណូមពរ។

ក្រោយពីកម្រងសំណួរត្រូវបានបង្កើតរួចរាល់និងត្រូវបានត្រួតពិនិត្យពីសាស្ត្រាចារ្យណែនាំរួចហើយ អ្នកសិក្សាស្រាវជ្រាវបានយកកម្រងសំណួរទាំងប្រាំប្រភេទ យកទៅធ្វើការសាកល្បងនៅវិទ្យាល័យ ហ៊ុន សែន កំពង់ចក ដែលស្ថិតនៅក្នុងស្រុករំដួលក្នុងខេត្តស្វាយរៀង។ ការសាកល្បងកម្រងសំណួរនេះ គឺបានសួរទៅលើសិស្សានុសិស្សថ្នាក់ទី១២ ផ្នែកវិទ្យាសាស្ត្រចំនួន១០នាក់ លោកគ្រូអ្នកគ្រូចំនួន០៤នាក់ និង នាយកសាលាចំនួន០១នាក់ មាតាបិតាសិស្ស០៤នាក់ និងអាជ្ញាធរ០១។ កម្រងសំណួរទាំងប្រាំប្រភេទនេះត្រូវបានតេស្តសាកល្បងតាម Online ក្នុងកម្មវិធី Google Forms។ បន្ទាប់មកយកកម្រងសំណួរទាំងប្រាំប្រភេទនេះ ទៅពិភាក្សាជាមួយសាស្ត្រាចារ្យដឹកនាំ និងសាស្ត្រាចារ្យដឹកនាំរង ម្តងទៀតដើម្បីធ្វើការកែលម្អចំណុចខ្វះខាត និងយកទៅប្រមូលទិន្នន័យតែម្តង។

## ៣.៤. ដំណើរការនៃការប្រមូលទិន្នន័យ

ក្រោយពីកម្រងសំណួរត្រូវបានបង្កើតរួចរាល់ហើយ និងបានត្រួតពិនិត្យពីសាស្ត្រាចារ្យណែនាំរួចស្របពេលដែល អ្នកស្រាវជ្រាវទទួលបានលិខិតឧទ្ទេសនាម ឱ្យចុះប្រមូលទិន្នន័យពីវិទ្យាស្ថានជាតិអប់រំ ដែលចេញដោយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីចុះទៅប្រមូលនៅតាមសាលារៀននីមួយៗដូចដែល

បានកំណត់។

ក្រោយពីទទួលបានលិខិតពីវិទ្យាស្ថានជាតិអប់រំ ដំបូងអ្នកស្រាវជ្រាវបានទៅជួបថ្នាក់ដឹកនាំនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង ដើម្បីសុំការសហការលើការងារដែលពាក់ព័ន្ធនឹងការស្រាវជ្រាវនេះ។ បន្ទាប់ពីបានទៅសុំការសហការពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀងរួចហើយ អ្នកស្រាវជ្រាវបានចុះទៅវិទ្យាល័យនានា តាមគោលដៅដែលបានកំណត់ (ដោយផ្ទាល់និងតាម online ខ្លះដោយសារស្ថានភាពជំងឺកូវីដ១៩នៅតែបន្តកើតមាន)។ពេលទៅដល់សាលានីមួយៗអ្នកស្រាវជ្រាវបានទៅសុំ ការសហការពីគណៈគ្រប់គ្រង និងលោកគ្រូ អ្នកគ្រូ។ ហើយក្រោយពី មានការយល់ព្រមពីគណៈគ្រប់គ្រង អ្នកស្រាវជ្រាវបានផ្ញើ កម្រងសំណួរជូនទៅគណៈគ្រប់គ្រង ដើម្បីជួយបំពេញ។ ដោយមានការយោគយល់និងជួយពីគណៈគ្រប់គ្រង គាត់បានផ្ញើតំណរ Link របស់ Google Forms សម្រាប់កម្រងសំណួរគ្រូចូលទៅក្នុងគ្រុបតេលេក្រាមសាលាគាត់នីមួយៗដើម្បីឱ្យលោកគ្រូ អ្នកគ្រូជួយបំពេញឱ្យ។ ចំណែកឯកម្រងសំណួរសិស្សគណៈគ្រប់គ្រង គាត់ក៏បានផ្ញើតំណរ Link របស់ Google Forms សម្រាប់កម្រងសំណួរសិស្ស ទៅក្នុងគ្រុបសិស្សតាមថ្នាក់ទី១០,១១និង១២ តាមសាលានីមួយៗទាំង១០វិទ្យាល័យដែលសាលាបានបង្កើតសម្រាប់ការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ។ ចំណែកឯអាជ្ញាធរ/គណៈកម្មការទ្រទ្រង់សាលា ការប្រមូលព័ត៌មានដោយផ្ទាល់និងតាមរយៈ Online (Google Forms) ដោយផ្ញើតំណរ Link របស់ Google Forms ជូនគាត់។ ក្រោយពីការបំពេញ ចម្លើយរបស់សិស្សានុសិស្ស លោកគ្រូអ្នកគ្រូ គណៈគ្រប់គ្រងសាលានិងអាជ្ញាធរ តាមរយៈការបំពេញដោយផ្ទាល់ និង Online (Google Forms) បានគ្រប់ចំនួនដែលបានកំណត់រួចរាល់ហើយអ្នកស្រាវជ្រាវក៏បានយកទិន្នន័យទាំងនេះមកធ្វើការវិភាគ។

### ៣.៥. ការវិភាគទិន្នន័យ

ទិន្នន័យដែលបានមកពីការបំពេញកម្រងសំណួរ តាមរយៈការបំពេញដោយផ្ទាល់ និងតាមរយៈការបំពេញតាម Online (Google Forms) ត្រូវបានអ្នកស្រាវជ្រាវប្រើប្រាស់កម្មវិធី Google Forms ដើម្បីបញ្ចូល រួចទាញទិន្នន័យយកមកជា Excel និងប្រើប្រាស់កម្មវិធី Microsoft Excel សម្រាប់វិភាគទិន្នន័យ

បែបបរិមាណវិស័យ ដែលបង្ហាញពីកម្រិតនៃការចូលរួមរបស់ គណៈគ្រប់គ្រង(លោកនាយក/នាយិកា) លោកគ្រូ អ្នកគ្រូ មាតាបិតាសិស្ស អាជ្ញាធរនិងសិស្សផ្ទាល់ ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ព្រមទាំងប្រើប្រាស់កម្មវិធីនេះ សម្រាប់ការបង្កើត ជាក្រាប (ក្រាហ្វិក) និងតារាងផងដែរ។ រាល់ទិន្នន័យ ដែលប្រមូលបានទាំងអស់ នឹងត្រូវបានយក មកធ្វើការវិភាគ ជាចំនួនភាគរយ(%) តម្លៃមធ្យមភាគ (Mean) គម្លាតស្តង់ដា(SD) កម្រិត និងលំដាប់។ ក្នុងការវិភាគចម្លើយ រាល់សំណួរទាំងអស់ត្រូវបានធ្វើការវិភាគ អាស្រ័យទៅលើប្រភេទនៃសំណួរ ថាតើជាប្រភេទសំណួរបើកឬសំណួរបិទ។ ចំពោះការវិភាគនេះ អ្នកសិក្សាស្រាវជ្រាវបានវិភាគលើចំណុចសំខាន់មួយចំនួនទៅតាមកម្រងសំណួរនីមួយៗ ។

## ៣.៦. កម្រិតចង្អុលបង្ហាញ

កម្រិតចង្អុលបង្ហាញគឺប្រើប្រាស់ក្នុងទម្រង់កម្រងសំណួរ ដើម្បីប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធទៅតាមការឆ្លើយតបក្នុងកម្រិតតួលេខជាក់លាក់។ ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ គឺមានកម្រិតចង្អុលបង្ហាញចំនួន៥កម្រិត។

- ដោយយោងតាមលំនាំកម្រិតពិន្ទុរបស់ Wannatawee, Worakham, & Panya (2017)[23] ដោយបង្ហាញលទ្ធផល តម្លៃមធ្យម (Mean) ដូចខាងក្រោម៖
  - តម្លៃមធ្យមពី ១.00 ដល់១.៥0 កំណត់ថាកម្រិតទាបបំផុត ស្មើនឹងតម្លៃពី 0% ដល់៣0% ។
  - តម្លៃមធ្យមពី ១.៥១ ដល់២.៥0 កំណត់ថាកម្រិតទាប ស្មើនឹងតម្លៃពី ៣0.0១% ដល់៥0%។
  - តម្លៃមធ្យមពី ២.៥១ ដល់៣.៥0 កំណត់ថាកម្រិតមធ្យម ស្មើនឹងតម្លៃពី ៥0,0១% ដល់៧0%។
  - តម្លៃមធ្យមពី ៣.៥១ ដល់៤.៥0 កំណត់ថាកម្រិតខ្ពស់ ស្មើនឹងតម្លៃពី ៧0,0១% ដល់៩0%។
  - តម្លៃមធ្យមពី ៤.៥១ ដល់៥.0 កំណត់ថាកម្រិតខ្ពស់បំផុត ស្មើនឹងតម្លៃពី ៩0,0១% ដល់១00%។
  - Mean៖ តាងឱ្យតម្លៃមធ្យមក្នុងការវាយតម្លៃកម្រិតនៃការចូលរួមរបស់សហគមន៍ ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀង។

[23] DEVELOPMENT OF AN ASSESSMENT MODEL ON PARALLEL EDUCATIONAL MANAGEMENT IN THE ACADEMY SCHOOLS UNDER OFFICE OF THE BASIC EDUCATION COMMISSION

- SD៖ គាងឱ្យគម្លាតស្តង់ដា។

## ៣.៧. ក្រមសីលធម៌នៃការស្រាវជ្រាវ

ដើម្បីរក្សាបាននូវក្រមសីលធម៌ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានរៀបចំលិខិតបទដ្ឋានបែបរដ្ឋបាលពីថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង ដើម្បីផ្តល់ដំណឹងបន្តទៅមូលដ្ឋានក្នុងការសុំឱ្យគណៈគ្រប់គ្រងសាលា(នាយក/នាយករង) លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សា មាតាបិតាសិស្ស និងអាជ្ញាធរដែនដី ដើម្បីឱ្យពួកគាត់ជួយបំពេញកម្រងសំណួរឱ្យតាមរយៈ Online (Google Forms)។ នៅគ្រប់ការបំពេញ កម្រងសំណួរឱ្យតាមរយៈ Online (Google Forms) ដែលមានគណៈគ្រប់គ្រងសាលា (នាយក/ នាយករង) លោកគ្រូ អ្នកគ្រ សិស្សានុសិស្ស មាតាបិតាសិស្ស និងអាជ្ញាធរដែនដី អ្នកស្រាវជ្រាវតែងតែជំរាបប្រាប់ពួកគាត់អំពីក្រមសីលធម៌អ្នកស្រាវជ្រាវ ដែលរក្សានូវការសម្ងាត់នូវរាល់ចម្លើយរបស់ពួកគាត់ និងមិនបង្ហាញនូវឈ្មោះ អត្តសញ្ញាណណាមួយរបស់ពួកគាត់ឡើយដើម្បីធ្វើឱ្យពួកគាត់មានភាពកក់ក្តៅក្នុងការផ្តល់ចម្លើយពិតប្រាកដ។

# ជំពូក៤

# លទ្ធផល និងការពិភាក្សា

នៅក្នុងជំពូក៤ នេះអ្នកស្រាវជ្រាវនឹងបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យ ធ្វើការបកស្រាយ និងពិភាក្សានូវអ្វីដែលត្រូវបានរកឃើញតាមរយៈកម្រងសំណួរដែលបានបំពេញដោយ សិស្សានុសិស្ស មាតាបិតា ឬអាណាព្យាបាលសិស្ស លោកគ្រូ អ្នកគ្រូ គណៈគ្រប់គ្រងសាលា និងអាជ្ញាធរដែនដី ឬគណៈកម្មការទ្រទ្រង់សាលារៀន។ ចំណុចសំខាន់មួយចំនួនដែលពាក់ព័ន្ធ ការចូលរួមរបស់សហគមន៍ ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស នៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀង នឹងត្រូវយកមកវិភាគបកស្រាយ និងពិភាក្សាផងដែរ រួមទាំងបញ្ហាប្រឈមដែលនាំឱ្យសហគមន៍មិនសូវបានចូលរួមក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។

## ៤.១. ឧបករណ៍វិភាគទិន្នន័យ

ដើម្បីវិភាគទិន្នន័យ អ្នកស្រាវជ្រាវបានប្រើកម្មវិធីMicrosoft Excel ។ កម្មវិធី Microsoft Excel ត្រូវបានប្រើប្រាស់ដើម្បីស្វែងរកកម្រិតនៃការចូលរួមរបស់ គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស មាតាបិតាសិស្ស និងអាជ្ញាធរដែនដី តាមរយៈកម្រងសំណួរ ដោយគិតជាភាគរយ(%) តម្លៃមធ្យម (Mean) គម្លាតស្តង់ដា(SD) កម្រិត លំដាប់ សង់តារាង និងក្រាបផ្សេងៗ។

## ៤.២. ដំណាក់កាលនៃការវិភាគទិន្នន័យ

នៅក្នុងដំណាក់កាលនៃការវិភាគទិន្នន័យ អ្នកស្រាវជ្រាវធ្វើការវិភាគទិន្នន័យដែលប្រមូលបានតាមរយៈការបំពេញកម្រងសំណួរ។ ការវិភាគកម្រងសំណួរសម្រាប់គណៈគ្រប់គ្រង សម្រាប់លោកគ្រូអ្នកគ្រូ សម្រាប់សិស្ស សម្រាប់មាតាបិតាសិស្ស និងសម្រាប់អាជ្ញាធរដែនដីឬគណៈកម្មការទ្រទ្រង់សាលារៀន មានគោលបំណងស្វែងរកឱ្យឃើញពីកម្រិតនៃការចូលរួមរបស់ពួកគាត់ ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សថាតើពួកគាត់បានចូលរួមក្នុងកម្រិតណា និងមានបញ្ហាប្រឈមអ្វីខ្លះក្នុងការចូលរួមរបស់ពួកគាត់ព្រមទាំងមានទស្សនៈ និងសំណូមពរបែបណាចំពោះការអប់រំ។

## ៤.៣. លទ្ធផលនៃការវិភាគទិន្នន័យ

ទិន្នន័យដែលបានវិភាគលើកម្រងសំណួរសម្រាប់អ្នកពាក់ព័ន្ធ ដូចមានបង្ហាញខាងលើគឺ គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស មាតាបិតាសិស្ស និងអាជ្ញាធរដែនដី ឬគណៈកម្មការទ្រទ្រង់សាលា នឹងត្រូវ បានលើកយកមកធ្វើការវិភាគម្តងមួយៗទៅតាមលំដាប់។ ដំបូងគឺអ្នកសិក្សាស្រាវជ្រាវវិភាគលើ កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលា លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស មាតាបិតាសិស្ស និងចុងក្រោយគឺកម្រងសំណួរសម្រាប់អាជ្ញាធរដែនដី ឬគណៈកម្មការទ្រទ្រង់សាលា។

### ៤.៣.១. ការវិភាគទិន្នន័យលើកម្រងសំណួរគណៈគ្រប់គ្រងសាលា

#### ផ្នែកទី១៖ ព័ត៌មានទូទៅ

*តារាង 3 ៖ ព័ត៌មានទូទៅគណៈគ្រប់គ្រង*

| ព័ត៌មានទូទៅគណៈគ្រប់គ្រង | | | | |
|---|---|---|---|---|
| ល.រ | បរិយាកាស | | ចំនួន | ភាគរយ |
| ១ | ភេទ | ប្រុស | 18 | 90% |
| | | ស្រី | 2 | 10% |
| | | **សរុប** | **20** | **100%** |
| ២ | អាយុ | ២០ ទៅ៣០ឆ្នាំ | 1 | 5% |
| | | ៣១ទៅ៤០ឆ្នាំ | 2 | 10% |
| | | ៤១ទៅ៥០ឆ្នាំ | 9 | 45% |
| | | លើស៥១ឆ្នាំ | 8 | 40% |
| | | **សរុប** | **20** | **100%** |
| ៣ | កម្រិតវប្បធម៌ | បរិញ្ញាបត្រ | 17 | 85% |
| | | បរិញ្ញាបត្រជាន់ខ្ពស់ | 3 | 15% |

| | | | | |
|---|---|---|---|---|
| | | **សរុប** | **20** | **100%** |
| ៤ | តួនាទី | នាយក/នាយិកា | 10 | 50% |
| | | នាយករង/នាយិការង | 10 | 50% |
| | | **សរុប** | **20** | **100%** |
| ៥ | ម៉ោងបំពេញការងារ | ពី២-៦ម៉ោង | 1 | 5% |
| | | ពី៦-៨ម៉ោង | 3 | 15% |
| | | ពី៨-១០ម៉ោង | 11 | 55% |
| | | ពី១០-១២ម៉ោង | 3 | 15% |
| | | លើស១២ម៉ោង | 2 | 10% |
| | | **សរុប** | **20** | **100%** |

តាមរយៈតារាង ៣ គណៈគ្រប់គ្រងដែលបានចូលរួមជួយបំពេញកម្រងសំណួរទាំងអស់ មានចំនួន ២០នាក់។ គណៈគ្រប់គ្រងដែលមានភេទប្រុសមានភាគរយៈខ្ពស់ជាងរហូតដល់៩០% ចំណែកឯគណៈគ្រប់គ្រងភេទស្រីមានតែ១០%ប៉ុណ្ណោះ។ តាមរយៈតារាងខាងលើ យើងអាចសន្និដ្ឋានបានថាគណៈគ្រប់គ្រងសាលាភាគច្រើនជាមនុស្សប្រុស។ អាយុគណៈគ្រប់គ្រងគឺ មានកម្រិតអាយុផ្សេងៗគ្នា។ គណៈគ្រប់គ្រងដែលមានអាយុចន្លោះពី២០ទៅ៣០ឆ្នាំ ភេទស្រី មានចំនួន៥%។ ចំណែកឯគណៈគ្រប់គ្រងអាយុចន្លោះពី៣១ទៅ៤០ឆ្នាំភេទប្រុស មានចំនួន១០%។ គណៈគ្រប់គ្រងអាយុចន្លោះ ពី៤១ទៅ៥០ឆ្នាំភេទប្រុស មានចំនួន៤៥%។ គណៈគ្រប់គ្រងអាយុលើស៥១ ឆ្នាំភេទប្រុស មានចំនួន ៤០%។ យោងតាមតារាងខាងលើ យើងអាចសន្និដ្ឋានបានថាគណៈគ្រប់គ្រងភាគច្រើនជាមនុស្សប្រុស ដែលមានអាយុចន្លោះពី៤១ទៅ៥០ ឆ្នាំ គឺជាវ័យដែលមានសក្តានុពលល្អសម្រាប់ចូលរួមធ្វើការអភិវឌ្ឍវិស័យអប់រំ។ គណៈគ្រប់គ្រងមានកម្រិតវប្បធម៌ផ្សេងៗគ្នា។ គណៈគ្រប់គ្រងដែលមានកម្រិតវប្បធម៌ បរិញ្ញាបត្រមានភេទប្រុស ១៦នាក់និងស្រី១នាក់ស្មើ៨៥%។ ចំណែកឯគណៈគ្រប់គ្រង មានកម្រិតវប្បធម៌ បរិញ្ញាបត្រជាន់ខ្ពស់ប្រុស

មាន២នាក់និងស្រី១នាក់ស្មើ១៥%។ តាមរយៈតារាងខាងលើយើងអាចសន្និដ្ឋានបានថា គណៈគ្រប់គ្រងភាគច្រើនមានកម្រិតវប្បធម៌បរិញ្ញាបត្រ។ គណៈគ្រប់គ្រង មានតួនាទីជានាយកមានចំនួន៥០% ហើយគណៈគ្រប់គ្រងមានតួនាទីជានាយករង/នាយិការង មានចំនួន៥០%។

គណៈគ្រប់គ្រងដែលបានបំពេញកម្រងសំណួរទាំងអស់ មានការចំណាយពេលវេលាខុសៗគ្នា ក្នុងការបំពេញការងារ។ គណៈគ្រប់គ្រងបានចំណាយពេលៈ

- ពី២ទៅ៦ម៉ោង លើការងារគ្រប់គ្រងសាលារៀនមានចំនួន ៥%។
- ពី៦ទៅ៨ម៉ោង លើការងារគ្រប់គ្រងសាលារៀនមានចំនួន ១៥%។
- ពី៨ទៅ១០ម៉ោង លើការងារគ្រប់គ្រងសាលារៀនមានចំនួន៥៥%។
- ពី១០ទៅ១២ម៉ោងលើការងារគ្រប់គ្រងសាលារៀនមានចំនួន១៥។
- លើស១២ម៉ោង លើការងារគ្រប់គ្រងសាលារៀនមានចំនួន១០%។

យោងតាមតារាងខាងលើយើងអាចសន្និដ្ឋានបានថាគណៈគ្រប់គ្រង បានចំណាយពេលវេលាលើការគ្រប់គ្រងសាលារៀនចន្លោះ ពី៨ ទៅ១០ម៉ោង ក្នុង១ថ្ងៃមានភាគរយខ្ពស់ជាងគេ ស្របទៅតាមការកំណត់របស់ក្រសួង គឺ៨ម៉ោង ក្នុង១ថ្ងៃ។

## ផ្នែកទី២៖ ដំណើរការគ្រប់គ្រងសាលារៀន (មាន៤ផ្នែក)

### ក.ការគ្រប់គ្រងផ្នែករដ្ឋបាល

*តារាង 4 ៖ ការគ្រប់គ្រងផ្នែករដ្ឋបាល*

| ការគ្រប់គ្រងផ្នែករដ្ឋបាល | | | | | |
|---|---|---|---|---|---|
| ល.រ | បរិយាកាស | Mean | SD | កម្រិត | លំដាប់ |
| 6 | លើកទឹកចិត្តឱ្យបុគ្គលិក សិស្សអនុវត្តបទបញ្ជា និងលិខិតគតិយុត្តិដែលក្រសួងបានដាក់ចេញឱ្យអនុវត្ត | 4.20 | 0.41 | ខ្ពស់ | 3 |
| 7 | ជំរុញនិងលើកទឹកចិត្តឱ្យបុគ្គលិកគោរពវិន័យ | 4.35 | 0.48 | ខ្ពស់ | 1 |
| 8 | ចាត់ចែងបែងចែកសិស្សតាមថ្នាក់នីមួយៗគោរពតាមនិយាមដែលក្រសួងបានកំណត់ | 4.15 | 0.58 | ខ្ពស់ | 4 |

| | | | | | |
|---|---|---|---|---|---|
| 9 | លោកគ្រូ អ្នកគ្រូ គោរពលក្ខខណ្ឌការងារ (វត្តមាន ការចូលរួម អនុវត្តការងារ...) | 4.35 | 0.48 | ខ្ពស់ | 1 |
| **សរុប** | | **4.26** | **0.10** | **ខ្ពស់** | |

តាមរយៈតារាងបានបង្ហាញថា ការគ្រប់គ្រងផ្នែករដ្ឋបាលរបស់នាយកសាលាឃើញថានាយកលើកទឹកចិត្តឱ្យបុគ្គលិក សិស្ស អនុវត្តបទបញ្ញា និងលិខិតគតិយុត្តិដែលក្រសួងបានដាក់ចេញឱ្យអនុវត្តមានតម្លៃមធ្យម (Mean)=4.20, SD=0.41 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ3។ នាយកជំរុញ និងលើកទឹកចិត្តឱ្យបុគ្គលិកគោរពវិន័យមានតម្លៃមធ្យម (Mean)=4.35, SD=0.48 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ1។ នាយកចាត់ចែងបែងចែក សិស្សតាមថ្នាក់នីមួយៗគោរពតាមនិយាមដែលក្រសួងបានកំណត់មានតម្លៃមធ្យម (Mean)=4.15, SD=0.58 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ4។ នាយកលោកគ្រូ អ្នកគ្រូ គោរពលក្ខខណ្ឌការងារ (វត្តមាន ការចូលរួម អនុវត្តការងារ...) មានតម្លៃមធ្យម (Mean) = 4.35, SD=0.48 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ1។ សរុបមកការគ្រប់គ្រងផ្នែករដ្ឋបាលរបស់នាយក ស្ថិតនៅក្នុងកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)=4.26 និងគម្លាតស្តង់ដា(SD)=0.10 ។

## ខ. ការគ្រប់គ្រងផ្នែកបច្ចេកទេស

*តារាង 5 ៖ ការគ្រប់គ្រងផ្នែកបច្ចេកទេស*

| ការគ្រប់គ្រងផ្នែកបច្ចេកទេស | | | | | |
|---|---|---|---|---|---|
| **ល.រ** | **បរិយាកាស** | **Mean** | **SD** | **កម្រិត** | **លំដាប់** |
| 10 | នាយកជំរុញឱ្យក្រុមបច្ចេកទេសនីមួយៗផលិតសម្ភារឧបទេសសម្រាប់បង្រៀន | 3.90 | 0.55 | ខ្ពស់ | 4 |
| 11 | នាយកលើកទឹកចិត្តបុគ្គលិកឱ្យស្រាវជ្រាវរកវិធីសាស្រ្តបង្រៀនថ្មីៗដើម្បីឱ្យការសិក្សារបស់សិស្សមានគុណភាព | 4.00 | 0.56 | ខ្ពស់ | 3 |
| 12 | នាយកចុះអធិការកិច្ច ការបង្រៀនរបស់គ្រូនិងបានពិនិត្យកិច្ចតែងការបង្រៀនរបស់គ្រូ | 3.70 | 0.57 | ខ្ពស់ | 6 |
| 13 | នាយកជំរុញឱ្យលោកគ្រូ អ្នកគ្រូ ធ្វើកិច្ចតែងការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល | 3.75 | 0.55 | ខ្ពស់ | 5 |

| | | | | | |
|---|---|---|---|---|---|
| 14 | នាយកចាត់ចែងរៀបចំបង្កើតក្លឹបសិក្សាក្រៅម៉ោងដើម្បីជួយបង្កើនសមត្ថភាពសិស្សបន្ថែម | 4.15 | 0.48 | ខ្ពស់ | 1 |
| 15 | នាយកជំរុញគ្រូៗឱ្យស្វ័យសិក្សាស្រាវជ្រាវដោយខ្លួនឯងបន្ថែមក្នុងការបង្កើនចំណេះដឹងសមត្ថភាព ជំនាញ ។ | 4.15 | 0.48 | ខ្ពស់ | 1 |
| **សរុប** | | **3.94** | **0.19** | **ខ្ពស់** | |

តាមរយៈតារាងបានបង្ហាញថា ការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់នាយកសាលា ឃើញថានាយកជំរុញឱ្យក្រុមបច្ចេកទេសនីមួយៗផលិតសម្ភារឧបទេសសម្រាប់បង្រៀន មានតម្លៃមធ្យម (Mean)= 3.90, SD=0.55 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ4។ នាយកលើកទឹកចិត្តបុគ្គលិកឱ្យស្រាវជ្រាវរកវិធីសាស្រ្តបង្រៀនថ្មីៗដើម្បីឱ្យការសិក្សារបស់សិស្សមានគុណភាព មានតម្លៃមធ្យម (Mean)= 4.00, SD=0.56 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ3។ នាយកចុះអធិការកិច្ចការបង្រៀនរបស់គ្រូ និងបានពិនិត្យកិច្ចតែងការបង្រៀនរបស់គ្រូ មានតម្លៃមធ្យម (Mean)= 3.70 , SD=0.57 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ6 ។ នាយកជំរុញឱ្យលោកគ្រូ អ្នកគ្រូធ្វើកិច្ចតែងការបង្រៀន តាមគោលវិធីសិស្សមជ្ឈមណ្ឌលមានតម្លៃ មធ្យម (Mean)= 3.75, SD=0.55 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ5។ នាយកចាត់ចែងរៀបចំបង្កើតក្លឹបសិក្សាក្រៅម៉ោងដើម្បីជួយបង្កើនសមត្ថភាពសិស្សបន្ថែម មានតម្លៃមធ្យម (Mean)=4.15, SD=0.48 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ1។ នាយកជំរុញគ្រូៗឱ្យស្វ័យសិក្សាស្រាវជ្រាវ ដោយខ្លួនឯងបន្ថែមក្នុងការបង្កើនចំណេះដឹង សមត្ថភាព ជំនាញ មានតម្លៃមធ្យម (Mean)=4.15, SD=0.48 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ1។ សរុបមកការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់នាយកសាលា ស្ថិតនៅក្នុងកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)= 3.94 និងគម្លាតស្តង់ដា(SD)=0.19 ។

យោងតាមតារាងខាងលើបានបង្ហាញថា ក្នុងចំណោមសូចនាករទាំង៦ មានសូចនាករទី៥ នាយកចាត់ចែងរៀបចំបង្កើតក្លឹបសិក្សាក្រៅម៉ោងដើម្បីជួយបង្កើនសមត្ថភាពសិស្សបន្ថែម លើចំណុចខ្វះខាតរបស់ពួកគេដើម្បីឱ្យពួកគេទទួលបានចំណេះដឹងហើយអាចប្រឡងជាប់បាននិទ្ទេសល្អទៀតផង។ ចំណែកឯសូចនាករទី៦ នាយកជំរុញគ្រូៗឱ្យស្វ័យសិក្សាស្រាវជ្រាវដោយខ្លួនឯងបន្ថែមក្នុងការបង្កើនចំណេះដឹង

សមត្ថភាព ជំនាញមានតម្លៃមធ្យម (Mean)= 4.15 , SD=0.48 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ1 ពីព្រោះគ្រូបង្រៀនគឺជាមនុស្សដ៏សំខាន់ដែលបង្រៀនសិស្សផ្ទាល់ ហើយត្រូវមានចំណេះដឹង ជំនាញ និងវិធីសាស្ត្របង្រៀនល្អៗដល់សិស្សធ្វើឱ្យសិស្សឆាប់យល់មានចំណេះដឹងអាចប្រឡងជាប់បាននិទ្ទេសល្អគ្រប់ៗគ្នា។ ក្នុងនោះសូចនាករទី៣ នាយកចុះអធិការកិច្ចការបង្រៀនរបស់គ្រូ និងបានពិនិត្យកិច្ចតែងការបង្រៀនរបស់គ្រូ មានតម្លៃមធ្យម (Mean)=3.70, SD=0.57 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ6។ សរុបមកការគ្រប់គ្រងផ្នែករដ្ឋបាលរបស់នាយកសាលាគឺស្ថិតនៅក្នុងកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)= 3.94 និងគម្លាតស្តង់ដា(SD)=0.19 ។

### គ. ការគ្រប់គ្រងផ្នែកថវិកា

*តារាង 6 ៖ ការគ្រប់គ្រងផ្នែកថវិកា*

| ការគ្រប់គ្រងផ្នែកថវិកា | | | | | |
|---|---|---|---|---|---|
| ល.រ | **បរិយាកាស** | **Mean** | **SD** | **កម្រិត** | **លំដាប់** |
| 16 | នាយករៀបចំដំណើរការគ្រប់គ្រងថវិកាសាលារៀន ដោយមានរបៀបរៀបរយតាមច្បាប់កំណត់ | 4.20 | 0.52 | ខ្ពស់ | 4 |
| 17 | នាយកប្រើប្រាស់ថវិកាសាលារៀនបានត្រឹមត្រូវតាមតម្រូវការជាក់ស្តែងចាំបាច់របស់សាលារៀន | 4.30 | 0.57 | ខ្ពស់ | 2 |
| 18 | នាយករាយការណ៍ការចាយវាយថវិកាដល់គ្រូៗ និង គណៈកម្មការផ្សេងៗ ដោយតម្លាភាព | 4.25 | 0.57 | ខ្ពស់ | 3 |
| 19 | នាយកជំរុញលើកទឹកចិត្តបុគ្គលិកឱ្យជួយស្វែងរកដៃគូអភិវឌ្ឍសាលារៀនដើម្បីយកមកអភិវឌ្ឍសាលារៀន | 4.20 | 0.52 | ខ្ពស់ | 4 |
| 20 | នាយករៀបចំប្រើប្រាស់ថវិកាទៅតាមផែនការប្រចាំឆ្នាំដើម្បីដំណើរការសាលារៀនឆ្លើយតបតាមគោលដៅ | 4.15 | 0.52 | ខ្ពស់ | 6 |
| 21 | ប្រជុំប្រចាំខែនាយកតែងលើកយកការប្រើប្រាស់ថវិកាមកប្រាប់ដល់បុគ្គលិកដើម្បីឱ្យមានតម្លាភាព | 4.35 | 0.67 | ខ្ពស់ | 1 |
| **សរុប** | | **4.24** | **0.07** | **ខ្ពស់** | |

តាមរយៈតារាងបានបង្ហាញថា ការគ្រប់គ្រងផ្នែកថវិការបស់នាយកសាលា ឃើញថានាយករៀបចំ

ដំណើរការគ្រប់គ្រងថវិកាសាលារៀនដោយមានរបៀបរៀបរយតាមច្បាប់កំណត់មានតម្លៃមធ្យម(Mean) =4.20, SD=0.52 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ 4។ នាយកប្រើប្រាស់ថវិកាសាលារៀន បានត្រឹមត្រូវតាមតម្រូវការជាក់ស្តែងចាំបាច់របស់សាលារៀនមានតម្លៃមធ្យម (Mean)=4.30, SD=0.57 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ2។ នាយករាយការណ៍ការចាយវាយថវិកាដល់គ្រូៗ និងគណៈកម្មការផ្សេងៗនៅពេលចាយវាយដោយតម្លាភាពមានតម្លៃមធ្យម (Mean)=4.25, SD=0.57 ស្ថិតនៅកម្រិត ខ្ពស់ និងលំដាប់លេខ3។ នាយកជំរុញលើកទឹកចិត្ត បុគ្គលិកឱ្យជួយស្វែងរកដៃគូអភិវឌ្ឍសាលារៀន ដើម្បីយកមកអភិវឌ្ឍសាលារៀនមានតម្លៃមធ្យម (Mean)=4.20, SD=0.52 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ4។ នាយករៀបចំប្រើប្រាស់ថវិកាគោរពទៅតាមផែនការប្រចាំឆ្នាំ ដើម្បីដំណើរការសាលារៀន ឆ្លើយតបតាមគោលដៅ មានតម្លៃមធ្យម (Mean)=4.15 , SD=0.52 ស្ថិតនៅកម្រិតខ្ពស់ និលំដាប់លេខ6។ ពេលប្រជុំប្រចាំខែនាយកតែងលើកយកការប្រើប្រាស់ថវិកាមកប្រាប់ដល់បុគ្គលិក ដើម្បីឱ្យមានតម្លាភាព មានតម្លៃមធ្យម (Mean)=4.35, SD=0.67 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ1។ សរុបមក ការគ្រប់គ្រងផ្នែកថវិការបស់នាយកសាលា ស្ថិតនៅកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)=4.24, SD=0.07 ។

សរុបមកតាមរយៈតារាងខាងលើបានបង្ហាញថា ក្នុងចំណោមសូចនាករទាំង៦ មានសូចនាករទី៦ ពេលប្រជុំប្រចាំខែ នាយកតែងលើកយកការប្រើប្រាស់ថវិកាមកប្រាប់ដល់បុគ្គលិកដើម្បីឱ្យមាន តម្លាភាព មានតម្លៃមធ្យម (Mean)=4.35, SD=0.67 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ1 ពីព្រោះដើម្បីឱ្យ មានភាពជឿទុកចិត្តគ្នាទៅវិញទៅមករវាង នាយកសាលា លោកគ្រូអ្នកគ្រូ និងគណកម្មការទ្រទ្រង់សាលា ជាដើម។ នាយកជំរុញលើកទឹកចិត្ត បុគ្គលិកឱ្យជួយស្វែងរកដៃគូអភិវឌ្ឍសាលារៀនដើម្បីយកមកអភិវឌ្ឍសាលារៀនមានតម្លៃមធ្យម (Mean)=4.20, SD=0.52 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ4 ពីព្រោះថាសាលារៀនជាអង្គភាពការងាររួម ដែលត្រូវការចូលរួមសហការគ្នាក្នុងការអភិវឌ្ឍ ទាំងនាយក លោកគ្រូអ្នកគ្រូ និងសហគមន៍គ្រប់មជ្ឈដ្ឋានដើម្បីឱ្យសាលាមានសោភ័ណភាពល្អ បរិស្ថានស្អាត អាចទាក់ទាញចំណាប់អារម្មណ៍សិស្សឱ្យចូលចិត្តរៀនផងដែរ។ ចំណែកឯសូចនាករទី៥ នាយករៀបចំប្រើប្រាស់ថវិកា

គោរពទៅតាមផែនការប្រចាំឆ្នាំ ដើម្បីឱ្យដំណើរការសាលារៀនឆ្លើយតបតាមគោលដៅ មានតម្លៃមធ្យម (Mean)=4.15, SD=0.52 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ៦។ ដូច្នេះការគ្រប់គ្រងផ្នែកថវិការបស់នាយកសាលាស្ថិតនៅកម្រិតខ្ពស់ដែលមានតម្លៃមធ្យម (Mean)= 4.24 និងគម្លាតស្តង់ដា(SD)=0.07 ។

## ឃ. ការគ្រប់គ្រងផ្នែកបុគ្គលិក

*តារាង 7 ៖ ការគ្រប់គ្រងផ្នែកបុគ្គលិក*

| ការគ្រប់គ្រងផ្នែកបុគ្គលិក | | | | | |
|---|---|---|---|---|---|
| ល.រ | បរិយាកាស | Mean | SD | កម្រិត | លំដាប់ |
| 22 | ការលើកទឹកចិត្តដល់បុគ្គលិកនៅពេលបុគ្គលិកមានបញ្ហាផ្សេងៗ(ទាំងពាក្យសម្ដី និងសម្ភារ) | 4.30 | 0.57 | ខ្ពស់ | 3 |
| 23 | ការរៀបចំបែងចែកតួនាទីភារកិច្ចដល់បុគ្គលិកប្រកបដោយយុត្តិធម៌ និងតម្លាភាព | 4.40 | 0.50 | ខ្ពស់ | 1 |
| 24 | ការជំរុញលើកទឹកចិត្តដល់បុគ្គលិកឱ្យមានទំនាក់ទំនងល្អនៅក្នុងអង្គភាព និងជាមួយខាងក្រៅ | 4.35 | 0.48 | ខ្ពស់ | 2 |
| 25 | ការជំរុញឱ្យលោកគ្រូ អ្នកគ្រូបំពេញការងារប្រកបដោយ មនសិការវិជ្ជាជីវៈ និងទំនួលខុសត្រូវខ្ពស់ | 4.30 | 0.57 | ខ្ពស់ | 3 |
| 26 | ការបែងចែកការងារឱ្យបុគ្គលិកត្រូវតាមជំនាញឯកទេស | 4.30 | 0.58 | ខ្ពស់ | 3 |
| 27 | ការត្រួតពិនិត្យការបំពេញការងារបុគ្គលិកជាប្រចាំ | 4.10 | 0.44 | ខ្ពស់ | 6 |
| **សរុប** | | **4.30** | **0.10** | **ខ្ពស់** | |

តាមរយៈតារាងខាងលើ បានបង្ហាញឱ្យឃើញថាការគ្រប់គ្រងផ្នែកបុគ្គលិករបស់នាយកសាលាតាមសូចនាករនីមួយៗមានដូចជា ការលើកទឹកចិត្តដល់បុគ្គលិកនៅពេលបុគ្គលិកមានបញ្ហាផ្សេងៗ (ទាំងពាក្យសម្ដី និងសម្ភារ) មានតម្លៃមធ្យម (Mean)=4.30, SD=0.57 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ3។ ការរៀបចំបែងចែកតួនាទីភារកិច្ចដល់បុគ្គលិកប្រកបដោយយុត្តិធម៌និងតម្លាភាព មានតម្លៃមធ្យម (Mean)=4.40, SD=0.50 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ1។ ការជំរុញលើកទឹកចិត្តដល់បុគ្គលិកឱ្យមានការប្រាស្រ័យ ទំនាក់ទំនងល្អនៅក្នុងអង្គភាពនិងខាងក្រៅ មានតម្លៃមធ្យម (Mean)=4.35, SD=0.48 ស្ថិត

នៅកម្រិតខ្ពស់ និងលំដាប់លេខ២។ ការជំរុញឱ្យលោកគ្រូ អ្នកគ្រូបំពេញការងារប្រកបដោយមនសិការវិជ្ជាជីវៈ និងទំនួលខុសត្រូវខ្ពស់ មានតម្លៃមធ្យម (Mean)=4.30, SD=0.57 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ៣។ ការបែងចែកការងារឱ្យបុគ្គលិកត្រូវតាមជំនាញឯកទេស មានតម្លៃមធ្យម (Mean) =4.30, SD=0.57 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ៣។ ការត្រួតពិនិត្យការបំពេញ ការងារបុគ្គលិក ជាប្រចាំមានតម្លៃមធ្យម (Mean)=4.10, SD=0.44 ស្ថិតនៅកម្រិតខ្ពស់និងលំដាប់លេខ៦។ សរុបមកការគ្រប់គ្រងផ្នែកបុគ្គលិករបស់នាយកសាលា ស្ថិតនៅកម្រិតខ្ពស់ មានតម្លៃមធ្យម (Mean)=4.30, SD=0.10។

## ផ្នែកទី៣៖ អំពីទំនាក់ទំនង

*តារាង ៨ ៖ ការទំនាក់ទំនងរបស់នាយកសាលា*

| ការទំនាក់ទំនងរបស់នាយកសាលា | | | | | |
|---|---|---|---|---|---|
| **ល.រ** | **បរិយាកាស** | **Mean** | **SD** | **កម្រិត** | **លំដាប់** |
| 28 | ការជំរុញឱ្យលោកគ្រូអ្នកគ្រូសិស្ស ចូលរួមធ្វើសកម្មភាពការងារសង្គម | 4.05 | 0.22 | ខ្ពស់ | 1 |
| 29 | ទំនាក់ទំនងជាមួយមាតាបិតាសិស្ស សហគមន៍ | 3.80 | 0.41 | ខ្ពស់ | 2 |
| 30 | មានភាពងាយស្រួលក្នុងការទាក់ទងជាមួយសហគមន៍ | 3.70 | 0.47 | ខ្ពស់ | 4 |
| 31 | បានទាក់ទាញសហគមន៍ មាតាបិតាសិស្ស ចូលរួមជាមួយសាលារៀន | 3.80 | 0.52 | ខ្ពស់ | 2 |
| **សរុប** | | **3.84** | **0.14** | **ខ្ពស់** | |

តាមរយៈតារាង បង្ហាញពីការទំនាក់ទំនងរបស់នាយកសាលាតាមសូចនាករនីមួយៗឃើញថា ការជំរុញឱ្យលោកគ្រូ អ្នកគ្រូ សិស្សចូលរួមធ្វើសកម្មភាពការងារសង្គមមានតម្លៃមធ្យម(Mean)=4.05, SD=0.22 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ១។ ទំនាក់ទំនងជាមួយមាតាបិតាសិស្ស សហគមន៍ មានតម្លៃមធ្យម(Mean)=3.80, SD=0.41 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ២។ មានភាពងាយស្រួលក្នុងការទំនាក់ទំនងជាមួយសហគមន៍ មានតម្លៃមធ្យម(Mean)=3.70, SD=0.47 ស្ថិតនៅកម្រិតខ្ពស់ និង

លំដាប់លេខ4។ បានទាក់ទាញសហគមន៍ មាតាបិតាសិស្សចូលរួមជាមួយសាលារៀន មានតម្លៃ មធ្យម (Mean)=3.80, SD=0.52 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ2។ សរុបមកការទំនាក់ទំនង របស់នាយកសាលា ស្ថិតនៅកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)= 3.84, SD=0.14 ។

*តារាង 9 ៖ ការចូលរួមរបស់នាយកសាលាក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស*

| ការចូលរួមរបស់នាយកសាលាក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស | | | | | |
|---|---|---|---|---|---|
| ល.រ | បរិយាកាស | Mean | SD | កម្រិត | លំដាប់ |
| 1 | ការគ្រប់គ្រងផ្នែករដ្ឋបាល | 4.26 | 0.10 | ខ្ពស់ | 2 |
| 2 | ការគ្រប់គ្រងផ្នែកបុគ្គលិក | 4.30 | 0.10 | ខ្ពស់ | 1 |
| 3 | ការគ្រប់គ្រងផ្នែកបច្ចេកទេស | 3.94 | 0.19 | ខ្ពស់ | 4 |
| 4 | ការគ្រប់គ្រងផ្នែកថវិកា | 4.24 | 0.07 | ខ្ពស់ | 3 |
| 5 | ការទំនាក់ទំនង | 3.84 | 0.14 | ខ្ពស់ | 5 |
| សរុប | | 4.12 | 0.21 | ខ្ពស់ | |

តាមរយៈតារាងបានបង្ហាញថា ការចូលរួមរបស់នាយកសាលាក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សឃើញថា ការគ្រប់គ្រងផ្នែករដ្ឋបាលមានតម្លៃមធ្យម (Mean)=4.26, SD=0.10 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ2។ ការគ្រប់គ្រងផ្នែកបុគ្គលិកមានតម្លៃមធ្យម (Mean)=4.30, SD=0.10 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ1។ ការគ្រប់គ្រងផ្នែកបច្ចេកទេស មានតម្លៃមធ្យម (Mean)=3.94, SD=0.19 ស្ថិតនៅកម្រិតខ្ពស់និងលំដាប់លេខ4។ការគ្រប់គ្រងផ្នែកថវិកាមានតម្លៃមធ្យម(Mean)= 4.24, SD=0.07 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ3។ ការទំនាក់ទំនងមានតម្លៃមធ្យម (Mean)= 3.84, SD=0.14 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ5។ សរុបមកការចូលរួមរបស់នាយកសាលា ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សស្ថិតនៅកម្រិតខ្ពស់ដែលមានតម្លៃមធ្យម (Mean)=4.12, SD= 0.21។

យោងតារាងខាងលើបានបង្ហាញថាក្នុងចំណោមទាំង៥ផ្នែកធំៗនៃការចូលរួមរបស់នាយកស្ថិតនៅកម្រិតខ្ពស់ទាំងអស់ ដែលមានតម្លៃមធ្យម (Mean) ចន្លោះចាប់ពី 3.84 ដល់ 4.30។ បើគិតតាមលំដាប់

ការគ្រប់គ្រងផ្នែកបុគ្គលិកស្ថិតនៅលំដាប់លេខ1 ដែលមានតម្លៃមធ្យម (Mean)=4.30។ ការគ្រប់គ្រងផ្នែករដ្ឋបាលស្ថិតនៅលំដាប់លេខ២ ដែលមានតម្លៃមធ្យម (Mean)=4.26។ ការគ្រប់គ្រងផ្នែកថវិកា ស្ថិតនៅលំដាប់លេខ3 ដែលមានតម្លៃមធ្យម (Mean)=4.24។ ការគ្រប់គ្រងផ្នែកបច្ចេកទេសស្ថិតនៅលំដាប់លេខ4 ដែលមានតម្លៃមធ្យម (Mean)=3.94។ ការទំនាក់ទំនងស្ថិតនៅលំដាប់លេខ5 ដែលមានតម្លៃមធ្យម (Mean)=3.84។ សរុបមកការចូលរួមរបស់នាយកសាលាក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ស្ថិតនៅកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)=4.12 និងគម្លាតស្តង់ដា(SD)=0.21។

### ៤.៣.២. ការវិភាគទិន្នន័យលើកម្រងសំណួរសម្រាប់លោកគ្រូ អ្នកគ្រូ

### ផ្នែកទី១៖ ព័ត៌មានទូទៅ

*តារាង 10 ៖ ព័ត៌មានទូទៅរបស់លោកគ្រូ អ្នកគ្រូ*

| ព័ត៌មានទូទៅរបស់លោកគ្រូ អ្នកគ្រូ | | | | |
|---|---|---|---|---|
| ល.រ | បរិយាកាស | | ចំនួន | ភាគរយ |
| ១ | ភេទ | ប្រុស | 70 | 70% |
| | | ស្រី | 30 | 30% |
| | | **សរុប** | **100** | **100%** |
| ២ | អាយុ | ២០ ទៅ៣០ឆ្នាំ | 24 | 24% |
| | | ៣១ទៅ៤០ឆ្នាំ | 61 | 61% |
| | | ៤១ទៅ៥០ឆ្នាំ | 8 | 8% |
| | | លើស៥០ឆ្នាំ | 7 | 7% |
| | | **សរុប** | **100** | **100%** |
| ៣ | កម្រិតវប្បធម៌ | ក្រោមបរិញ្ញាបត្រ | 1 | 1% |
| | | បរិញ្ញាបត្រ | 86 | 86% |
| | | បរិញ្ញាបត្រជាន់ខ្ពស់ | 13 | 13% |
| | | **សរុប** | **100** | **100%** |
| | | ក្រោម៥ឆ្នាំ | 11 | 11% |

| | | | | |
|---|---|---|---|---|
| ៤ | បទពិសោធន៍ការងារ | ៥ទៅ៩ឆ្នាំ | 21 | 21% |
| | | ១០ទៅ១៤ឆ្នាំ | 44 | 44% |
| | | ១៥ទៅ១៩ឆ្នាំ | 17 | 17% |
| | | លើស២០ឆ្នាំ | 7 | 7% |
| | | **សរុប** | **100** | **100%** |
| ៥ | ការចំណាយពេលវេលាការងារបង្រៀនរបស់គ្រូ | ពី២-៦ម៉ោង | 44 | 44% |
| | | ពី៦-៨ម៉ោង | 34 | 34% |
| | | ពី៨-១០ម៉ោង | 17 | 17% |
| | | ពី១០-១២ម៉ោង | 3 | 3% |
| | | លើស១២ម៉ោង | 2 | 2% |
| | | **សរុប** | **100** | **100%** |

តាមរយៈតារាងទាក់ទងភេទ លោកគ្រូ អ្នកគ្រូ ដែលចូលរួមបំពេញកម្រងសំណួរគឺភេទស្រី មានចំនួន៣០នាក់ ស្មើ៣០% និងភេទប្រុសមានចំនួន៧០នាក់ ស្មើ៧០%។ ដូចនេះគ្រូបង្រៀននៅវិទ្យាល័យក្នុងខេត្តស្វាយរៀង ភាគច្រើនជាលោកគ្រូ (ភេទប្រុស)។ អាយុលោកគ្រូ អ្នកគ្រូគឺ អាយុ ២០ទៅ ៣០ឆ្នាំ មានចំនួន២៤នាក់ ស្មើ២៤%។ ៣១ទៅ៤០ឆ្នាំមានចំនួន៦១នាក់ ស្មើ៦១%។ ៤១ទៅ៥០ឆ្នាំ មានចំនួន ៨នាក់ ស្មើ៨%។ ៤១ទៅ៥០ឆ្នាំមានចំនួន៧នាក់ ស្មើ៧%។ តាមរយៈតារាងទាក់ទងកម្រិតវប្បធម៌ លោកគ្រូ អ្នកគ្រូ ដែលបានចូលរួមបំពេញកម្រងសំណួរគឺ ក្រោមបរិញ្ញាបត្រ មានចំនួន១នាក់ ស្មើ១%។ បរិញ្ញាបត្រ មានចំនួន៨៦នាក់ ស្មើ៨៦% បរិញ្ញាបត្រជាន់ ខ្ពស់មានចំនួន១៣នាក់ ស្មើ១៣%។ ដូចនេះ លោកគ្រូ អ្នកគ្រូ បង្រៀននៅវិទ្យាល័យក្នុងខេត្តស្វាយរៀង ភាគច្រើនមានកម្រិតវប្បធម៌បរិញ្ញាបត្រ។

លោកគ្រូ អ្នកគ្រូ មានបទពិសោធន៍ការងាលើការបង្រៀនគឺ ក្រោម៥ឆ្នាំមានចំនួន១១នាក់ ស្មើ១១%។ ៥ទៅ៩ឆ្នាំមានចំនួន២១នាក់ ស្មើ២១%។ ១០ទៅ១៤ឆ្នាំ មាន ចំនួន៤៤នាក់ ស្មើ៤៤%។ ១៥ទៅ១៩ឆ្នាំ មានចំនួន១៧នាក់ ស្មើ១៧% និងលើស២០ឆ្នាំ មានចំនួន ៧នាក់ ស្មើ៧%។ ការចំណាយពេលវេលាលើការងារបង្រៀនរបស់លោកគ្រូអ្នកគ្រូដែលចូល រួមបំពេញកម្រងសំណួរគឺ ពី២-៦ម៉ោងមានចំនួន៤៤នាក់

ស្មើ៤៤%។ ពី៦-៨ម៉ោងមានចំនួន៣៤នាក់ ស្មើ៣៤%។ ពី៨-១០ម៉ោងមានចំនួន១៧នាក់ ស្មើ១៧%។ ពី១០-១២ម៉ោងមានចំនួន៣នាក់ ស្មើ៣% និងលើស១២ម៉ោងមានចំនួន២នាក់ ស្មើ២%។

**ផ្នែកទី២៖ អំពីការខារបង្រៀន , ក. ការបង្រៀន**

*តារាង 11 ៖ ការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ*

| ការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ | | | | | |
|---|---|---|---|---|---|
| ល.រ | បរិយាកាស | Mean | SD | កម្រិត | លំដាប់ |
| 6 | អនុវត្តការបង្រៀនតាមគ្រប់ជំហានទាំង៥នៃវិធីសាស្ត្របង្រៀន | 3.88 | 0.53 | ខ្ពស់ | 4 |
| 7 | មានវិធីសាស្ត្របង្រៀនល្អធ្វើឱ្យសិស្សងាយយល់ខ្លឹមសារមេរៀន | 3.86 | 0.55 | ខ្ពស់ | 5 |
| 8 | មានចំណេះដឹងនិងជំនាញវិជ្ជាជីវៈពិតប្រាកដក្នុងការបង្រៀនសិស្ស | 3.98 | 0.47 | ខ្ពស់ | 3 |
| 9 | បានដាក់កិច្ចការផ្ទះ(សំណួរឬលំហាត់)និងត្រួតពិនិត្យកែតម្រូវឱ្យសិស្ស | 3.75 | 0.57 | ខ្ពស់ | 6 |
| 10 | ចូលបណ្ណាល័យ ស្វែងរកឯកសារបន្ថែម ទាក់ទងការបង្រៀន | 3.46 | 0.61 | មធ្យម | 7 |
| 11 | ដាក់ពិន្ទុប្រកបដោយ យុត្តិធម៌ និងតម្លាភាព | 4.54 | 0.52 | ខ្ពស់បំផុត | 1 |
| 12 | គោរពវិន័យ (ម៉ោងចេញចូលបង្រៀន) មានសីលធម៌ល្អ | 4.33 | 0.53 | ខ្ពស់ | 2 |
| **សរុប** | | **3.97** | **0.36** | **ខ្ពស់** | |

តាមរយៈតារាង បានបង្ហាញថា ការបង្រៀនរបស់លោកគ្រូអ្នកគ្រូតាមសូចនាករនីមួយៗ ឃើញថា អនុវត្តការបង្រៀនតាមគ្រប់ជំហានទាំង៥នៃវិធីសាស្ត្របង្រៀនមានតម្លៃមធ្យម(Mean)=3.88,SD=0.53 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ4។ មានវិធីសាស្ត្របង្រៀនល្អធ្វើឱ្យសិស្សងាយយល់ខ្លឹមសារមេរៀន មានតម្លៃមធ្យម (Mean)=3.86, SD=0.55 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ5។ មានចំណេះដឹងនិងជំនាញវិជ្ជាជីវៈពិតប្រាកដក្នុងការបង្រៀនសិស្សមានតម្លៃមធ្យម (Mean)=3.98, SD= 0.47 ស្ថិតនៅ

កម្រិតខ្ពស់ និងលំដាប់លេខ3។ បានដាក់កិច្ចការផ្ទះ (សំណួរឬលំហាត់) និងត្រួតពិនិត្យកែតម្រូវឱ្យសិស្ស មានតម្លៃមធ្យម (Mean)=3.75, SD=0.57 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ6។ ចូលបណ្ណាល័យស្វែងរកឯកសារបន្ថែមទាក់ទងការបង្រៀន មានតម្លៃមធ្យម (Mean)=3.46, SD=0.61 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ7។ ដាក់ពិន្ទុប្រកបដោយយុត្តិធម៌ និងតម្លាភាព មានតម្លៃមធ្យម (Mean) =4.54 , SD=0.52 ស្ថិតនៅកម្រិតខ្ពស់បំផុត និងលំដាប់លេខ1។ គោរពវិន័យ (ម៉ោងចេញ ចូលបង្រៀន) មានសីលធម៌ល្អមានតម្លៃមធ្យម (Mean)=4.33, SD=0.53 ស្ថិតនៅកម្រិតខ្ពស់និង លំដាប់លេខ2។ សរុបមកការបង្រៀនរបស់លោកគ្រូអ្នកគ្រូ ស្ថិតនៅក្នុងកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម(Mean)=3.97, SD=0.36។

តាមរយៈតារាងខាងលើបានបង្ហាញថា ក្នុងចំណោមសូចនាករទាំង៧ មានសូចនាករទី៦ ដាក់ពិន្ទុប្រកបដោយ យុត្តិធម៌ និងតម្លាភាព មានតម្លៃមធ្យម (Mean)=4.54, SD=0.52 ស្ថិតនៅកម្រិតខ្ពស់បំផុត និងលំដាប់លេខ1។ សូចនាករផ្សេងទៀតស្ថិតនៅកម្រិតខ្ពស់ដែលមានតម្លៃមធ្យម (Mean) ចាប់ពី 3.75ដល់4.33មាន៥សូចនាករ។ ចំណែកឯសូចនាករដែលនិយាយពីការចូលបណ្ណាល័យស្វែងរកឯកសារបន្ថែមទាក់ទងការបង្រៀន ស្ថិតនៅកម្រិតមធ្យម ដែលមានតម្លៃមធ្យម (Mean)=3.46។ សរុបមកការបង្រៀនរបស់លោកគ្រូអ្នកគ្រូ ស្ថិតនៅក្នុងកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម(Mean)=3.97, SD= 0.36។

## ខ. ការលើកទឹកចិត្តរបស់គ្រូ ចំពោះសិស្ស

*តារាង 12 ៖ ការលើកទឹកចិត្តរបស់គ្រូ ចំពោះសិស្ស*

| ការលើកទឹកចិត្តរបស់គ្រូចំពោះសិស្ស | | | | | |
|---|---|---|---|---|---|
| ល.រ | បរិយាកាស | Mean | SD | កម្រិត | លំដាប់ |
| 13 | បានជម្រុញសិស្សឱ្យប្រតិបត្តិ ឬអនុវត្តមេរៀន ស្វ័យសិក្សានៅផ្ទះ | 4.22 | 0.53 | ខ្ពស់ | 1 |
| 14 | បានសរសើរឬឱ្យជារង្វាន់សិស្សនៅពេលសិស្សឆ្លើយសំណួរត្រូវ | 3.82 | 0.55 | ខ្ពស់ | 2 |
| 15 | បានជួយបង្រៀនបន្ថែមនិងលើកទឹកចិត្តដល់សិស្សដែលរៀនយឺត | 3.74 | 0.57 | ខ្ពស់ | 3 |

| | | | | |
|---|---|---|---|---|
| **សរុប** | **3.92** | **0.24** | **ខ្ពស់** | |

តាមរយៈតារាងបានបង្ហាញថា ការលើកទឹកចិត្តរបស់គ្រូ ចំពោះសិស្សតាមសូចនាករនីមួយៗ ឃើញថា បានជម្រុញសិស្សឱ្យប្រតិបត្តិឬអនុវត្តមេរៀនស្វ័យសិក្សានៅផ្ទះមានតម្លៃមធ្យម (Mean)=4.22, SD=0.53 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ១។ បានសរសើរ ឬឱ្យជារង្វាន់សិស្សនៅពេលសិស្សឆ្លើយសំណួរត្រូវមានតម្លៃមធ្យម (Mean)=3.82, SD=0.55 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ២។ បានជួយបង្រៀនបន្ថែម និងលើកទឹកចិត្តដល់សិស្សដែលរៀនយឺតមានតម្លៃមធ្យម (Mean)=3.74, SD=0.57 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ៣។ សរុបមកការលើកទឹកចិត្តរបស់គ្រូចំពោះសិស្ស ស្ថិតនៅកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)=3.92, SD=0.24 ។

## ផ្នែកទី៣៖ អំពីការទំនាក់ទំនង

*តារាង 13 ៖ ការទំនាក់ទំនងរបស់លោកគ្រូ អ្នកគ្រូ*

| **ការទំនាក់ទំនងរបស់លោកគ្រូ អ្នកគ្រូ** | | | | | |
|---|---|---|---|---|---|
| **ល.រ** | **បរិយាកាស** | **Mean** | **SD** | **កម្រិត** | **លំដាប់** |
| 16 | ទំនាក់ទំនងល្អជាមួយ នាយកសាលា គ្រូៗ និងសិស្ស | 4.28 | 0.53 | ខ្ពស់ | 1 |
| 17 | ទំនាក់ទំនងល្អជាមួយមាតាបិតា អាណាព្យាបាល និងសហគមន៍ | 3.59 | 0.62 | ខ្ពស់ | 2 |
| 18 | ផ្តល់ព័ត៌មានផ្សេងៗទាក់ទងការសិក្សារបស់សិស្សដល់មាតាបិតាសិស្ស | 3.56 | 0.59 | ខ្ពស់ | 3 |
| 19 | ចូលរួមកម្មវិធីផ្សេងៗទាក់ទងការអប់រំនៅក្នុងសាលារៀន និងសហគមន៍ | 3.52 | 0.64 | ខ្ពស់ | 4 |
| **សរុប** | | **3.73** | **0.36** | **ខ្ពស់** | |

តាមរយៈតារាងបានបង្ហាញថា ការទំនាក់ទំនងរបស់លោកគ្រូ អ្នកគ្រូតាមសូចនាករនីមួយៗ ឃើញថា ទំនាក់ទំនងល្អជាមួយនាយកសាលា គ្រូៗនិងសិស្សមានតម្លៃមធ្យម (Mean)=4.28, SD=0.53 ស្ថិត

នៅកម្រិតខ្ពស់ និងលំដាប់លេខ1។ ទំនាក់ទំនងល្អជាមួយមាតាបិតា អាណាព្យាបាល និងសហគមន៍ មានតម្លៃមធ្យម(Mean)=3.59, SD=0.62ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ2។ ផ្តល់ព័ត៌មានផ្សេងៗទាក់ទងការសិក្សារបស់សិស្សដល់មាតាបិតាសិស្ស មានតម្លៃមធ្យម (Mean)=3.56, SD=0.59 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ3។ ចូលរួមកម្មវិធីផ្សេងៗទាក់ទងការអប់រំនៅក្នុងសាលារៀន និងសហគមន៍ មានតម្លៃមធ្យម (Mean)=3.52, SD=0.60 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ4។ សរុបមកការ ទំនាក់ទំនងរបស់លោកគ្រូ អ្នកគ្រូ ស្ថិតនៅក្នុងកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)=3.73, SD=0.36។

*តារាង 14 ៖ ការចូលរួមរបស់លោកគ្រូ អ្នកគ្រូក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស*

| ការចូលរួមរបស់លោកគ្រូ អ្នកគ្រូក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស | | | | | |
|---|---|---|---|---|---|
| ល.រ | បរិយាកាស | Mean | SD | កម្រិត | លំដាប់ |
| 1 | ការបង្រៀន | 3.97 | 0.36 | ខ្ពស់ | 2 |
| 2 | ការលើកទឹកចិត្តសិស្ស | 3.99 | 0.24 | ខ្ពស់ | 1 |
| 3 | ការទំនាក់ទំនង | 3.74 | 0.36 | ខ្ពស់ | 3 |
| សរុប | | 3.90 | 0.13 | ខ្ពស់ | |

តាមរយៈតារាង បានបង្ហាញឱ្យឃើញថា កម្រិតនៃការចូលរួមរបស់លោកគ្រូ អ្នកគ្រូក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សតាមសូចនាករនីមួយៗឃើញថា ការបង្រៀនមានតម្លៃមធ្យម (Mean)= 3.97, SD=0.36 ស្ថិតនៅក្នុងកម្រិតខ្ពស់ និងលំដាប់លេខ២។ ការលើកទឹកចិត្តសិស្ស មានតម្លៃមធ្យម (Mean) =3.99, SD=0.24 ស្ថិតនៅកម្រិតខ្ពស់និងលំដាប់លេខ១។ ការទំនាក់ទំនងមានតម្លៃមធ្យម (Mean) =3.74, SD=0.36 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ3។ សរុបមកការចូលរួមរបស់លោកគ្រូ អ្នកគ្រូក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ស្ថិតនៅកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម(Mean) =3.90, SD=0.13 ។

## ផ្នែកទី៤៖ បញ្ហាប្រឈមរបស់គ្រូ

*តារាង 15 ៖ បញ្ហាប្រឈមរបស់លោកគ្រូ អ្នកគ្រូ*

| ល.រ | បញ្ហាប្រឈមរបស់លោកគ្រូ អ្នកគ្រូ | ចំនួន | ភាគរយ |
|---|---|---|---|
| 1 | មិនសូវមានទំនាក់ទំនងល្អជាមួយគ្រប់គ្រងសាលា | 7 | 1.91% |
| 2 | មិនសូវមានភាពស្និទ្ធស្នាលនៅក្នុងអង្គភាព | 8 | 2.19% |
| 3 | រវល់ធ្វើការក្រៅម៉ោងច្រើន | 11 | 3.01% |
| 4 | មេរៀនច្រើន ខ្លឹមសារជ្រៅ បង្រៀនសិស្សមិនចប់កម្មវិធី | 50 | 13.69% |
| 5 | គ្មានការលើកទឹកចិត្តពីថ្នាក់ដឹកនាំ( នាយក មន្ទីរ ក្រសួង ) | 39 | 10.68% |
| 6 | ពិបាកគ្រប់គ្រងសិស្ស( បង្រៀនតាម Online )បើផ្ទាល់មិនពិបាកទេ | 80 | 21.91% |
| 7 | គ្រួសារមានជីវភាពខ្វះខាត | 50 | 13.69% |
| 8 | ខ្វះខាតសម្ភារឧបទេស ឯកសារស្រាវជ្រាវ | 90 | 24.65% |
| 9 | ផ្សេងៗ | 30 | 8.21% |

តាមរយៈតារាងទាក់ទង បញ្ហាប្រឈមរបស់លោកគ្រូ អ្នកគ្រូដែលបានចូលរួមបំពេញកម្រងសំណួរ គឺមិនសូវមានទំនាក់ទំនងល្អជាមួយគ្រប់គ្រងសាលា ចំនួន១.៩១%។ មិនសូវមានភាពស្និទ្ធស្នាលនៅក្នុងអង្គភាព មានចំនួន២.២៩%។ រវល់ធ្វើការក្រៅម៉ោងច្រើនមានចំនួន៣.០១%។ មេរៀនច្រើន ខ្លឹមសារជ្រៅ បង្រៀនសិស្សមិនចប់កម្មវិធី មានចំនួន១៣.៦៩%។ គ្មានការលើកទឹកចិត្តពីថ្នាក់ដឹកនាំ( នាយក មន្ទីរ ក្រសួង )មានចំនួន១០.៦៨%។ ពិបាកគ្រប់គ្រងសិស្ស( បង្រៀនតាមOnline) មានចំនួន២១.៩១%។ គ្រួសារមានជីវភាពខ្វះខាតមានចំនួន១៣.៦៩%។ ខ្វះខាតសម្ភារឧបទេស ឯកសារស្រាវជ្រាវ មានចំនួន ២៤.៦៥% និងផ្សេងៗ មានចំនួន៨.២១%។ តារាងខាងលើបានបង្ហាញថាក្នុងចំណោមបញ្ហាប្រឈមទាំងអស់ មានបញ្ហាប្រឈមដែលមានភាគរយខ្ពស់នោះគឺខ្វះខាតសម្ភារឧបទេស និងឯកសារស្រាវជ្រាវ មានចំនួន ២៤.៦៥%មានន័យថា សាលារៀនភាគច្រើនមិនទាន់មានបណ្ណាល័យដែលមានលក្ខណៈស្តង់ដា (យកបន្ទប់រៀនធ្វើបណ្ណាល័យ) ខ្វះសម្ភារឧបទេសបម្រើឱ្យការបង្រៀន និងរៀន ហើយថែមទាំងខ្វះ

ឯកសារសម្រាប់អានស្រាវជ្រាវបន្ថែម។ ចំណែកឯការគ្រប់គ្រងសិស្ស ដែលបង្រៀនតាមប្រព័ន្ធOnline មានបញ្ហាច្រើនមិនដូចបង្រៀនផ្ទាល់ទេ ដោយសិស្សខ្លះនិយាយថាគ្មានសេវាអ៊ីនធើណែត គ្មានទូរស័ព្ទឬកុំព្យូទ័រទំនើបអាចរៀនបានជាដើម ធ្វើឱ្យការចូលរៀនរបស់សិស្ស មិនបានទៀងទាត់ មិនសូវធ្វើកិច្ចការដែលគ្រូដាក់ឱ្យបានគ្រប់គ្នា។ ម្យ៉ាងទៀត មេរៀននៅសៀវភៅសិក្សាគោល មានចំនួនច្រើនហើយវែងៗ ជាហេតុធ្វើឱ្យការបង្រៀនមិនបានចប់តាមកម្មវិធី។

## ៤.៣.៣. ការវិភាគទិន្នន័យលើក្រុមសម្រាប់សិស្ស

### ផ្នែកទី១៖ ព័ត៌មានទូទៅ

*តារាង 16 ៖ ព័ត៌មានទូទៅរបស់សិស្ស*

| ព័ត៌មានទូទៅរបស់សិស្ស | | | | |
|---|---|---|---|---|
| ល.រ | បរិយាកាស | | ចំនួន | ភាគរយ |
| ១ | ភេទ | ប្រុស | 190 | 47% |
| | | ស្រី | 210 | 53% |
| | | **សរុប** | **400** | **100%** |
| ២ | អាយុ | ១១ទៅ១៥ឆ្នាំ | 25 | 6% |
| | | ១៦ទៅ២០ឆ្នាំ | 367 | 92% |
| | | ២០ឆ្នាំឡើងទៅ | 8 | 2% |
| | | **សរុប** | **400** | **100%** |
| ៣ | ជាសិស្សរៀនថ្នាក់ទី | ថ្នាក់ទី១០ | 90 | 22.50% |
| | | ថ្នាក់ទី១១ | 110 | 27.50% |
| | | ថ្នាក់ទី១២ | 200 | 50% |
| | | **សរុប** | **400** | **100%** |
| ៤ | កម្រិតវប្បធម៌ម្តាយ | បឋមសិក្សា | 141 | 35.25% |
| | | អនុវិទ្យាល័យ | 89 | 22.25% |
| | | វិទ្យាល័យ | 159 | 37.75% |
| | | មហាវិទ្យាល័យ | 10 | 2.50% |

| | | | | |
|---|---|---|---|---|
| | | ផ្សេងៗ | 1 | 0.25% |
| | | **សរុប** | **400** | **100%** |
| ៥ | កម្រិតវប្បធម៌ឪពុក | បឋមសិក្សា | 95 | 23.75% |
| | | អនុវិទ្យាល័យ | 103 | 25.75% |
| | | វិទ្យាល័យ | 138 | 34.50% |
| | | មហាវិទ្យាល័យ | 60 | 15.00% |
| | | ផ្សេងៗ | 4 | 1.00% |
| | | **សរុប** | **400** | **100%** |
| ៦ | ប្រាក់ចំណូលឪពុកម្ដាយ | ច្រើនជាង ៤០០ដុល្លារ | 59 | 14.75% |
| | | ២០០ដុល្លារ ដល់៤០០ដុល្លារ | 142 | 12.00% |
| | | ក្រោម ២០០ ដុល្លារ | 159 | 39.75% |
| | | មិនមានប្រាក់ចំណូល | 40 | 10.00% |
| | | **សរុប** | **400** | **100%** |
| ៧ | មុខរបរឪពុកម្ដាយ | ផ្សេងៗ | 37 | 9.25% |
| | | កម្មករ | 49 | 12.25% |
| | | អាជីវករ | 58 | 14.50% |
| | | មន្ត្រីរាជការ | 66 | 16.50% |
| | | កសិករ | 190 | 47.50% |
| | | **សរុប** | **400** | **100%** |
| ៨ | ការចំណាយពេលរៀនក្នុង១ថ្ងៃរបស់សិស្ស | ពី២-៦ម៉ោង | 83 | 20.75% |
| | | ពី៦-៨ម៉ោង | 88 | 22.00% |
| | | ពី៨-១០ម៉ោង | 124 | 31.00% |
| | | ពី១០-១២ម៉ោង | 69 | 17.25% |
| | | លើស១២ម៉ោង | 36 | 9.00% |
| | | **សរុប** | **400** | **100%** |

តាមរយៈតារាងទាក់ទងភេទគឺសិស្សស្រីមានចំនួន២១០នាក់ស្មើ៥៣% និងប្រុសមានចំនួន១៩០

នាក់ ស្មើ៤៧%។ ដូចនេះសិស្សស្រីមានចំនួនច្រើនជាង សិស្សប្រុសនៅតាមវិទ្យាល័យនានានៃខេត្ត ស្វាយរៀង។ ចំណែកឯអាយុសិស្ស គឺអាយុពី១១ទៅ១៥ឆ្នាំមានចំនួន២៥នាក់ស្មើ៦.២៥%។ អាយុ១៦ ទៅ២០ឆ្នាំមានចំនួន៣៦៧នាក់ ស្មើ៩១.៧៥%។ អាយុ២០ឆ្នាំ ឡើងមានចំនួន៨នាក់ស្មើ២%។ដូចនេះ សិស្សដែលចូលរៀនត្រូវតាមអាយុរហូតដល់៩១.៧៥%។ សិស្សចូលរៀនលឿនមាន៦.២៥%និងសិស្ស ចូលរៀនយឺតមាន២%នៅតាមវិទ្យាល័យនានានៃខេត្តស្វាយរៀង។ ហើយសិស្សដែលរៀន ថ្នាក់ទី១០ មាន ចំនួន ៩០ នាក់ស្មើ២២.៥០%។ ថ្នាក់ទី១១មានចំនួន១១០នាក់ ស្មើ២៧.៥០%។ ថ្នាក់ទី១២ មានចំនួន ២០០នាក់ ស្មើ៥០%។ ចំណែកឯកម្រិតវប្បធម៌ម្តាយរបស់សិស្សគឺផ្សេងៗមានចំនួន១នាក់ស្មើ0.២៥%។ បឋមសិក្សាមានចំនួន១៤១នាក់ ស្មើ៣៥.២៥%។ អនុវិទ្យាល័យ មានចំនួន ៨៩នាក់ស្មើ២២.២៥%។ វិទ្យាល័យមានចំនួន១៥៩នាក់ស្មើ៣៧.៧៥% និងបរិញ្ញាបត្រមានចំនួន១០ នាក់ស្មើ២.៥០%។តាមរយៈ តារាងអាចសន្និដ្ឋានបានថា កម្រិតវប្បធម៌របស់ម្តាយសិស្ស ភាគច្រើន មានកម្រិតវប្បធម៌ត្រឹមវិទ្យាល័យ និងបឋមសិក្សា ក្នុងខេត្តស្វាយរៀង។ ហើយកម្រិតវប្បធម៌ឪពុករបស់សិស្សគឺ ផ្សេងៗ មានចំនួន៤នាក់ ស្មើ១%។ បឋមសិក្សាមានចំនួន៩៥នាក់ ស្មើ២៣.៧៥%។ អនុវិទ្យាល័យមាន ចំនួន១០៣នាក់ ស្មើ ២៥.៧៥%។ វិទ្យាល័យមានចំនួន១៣៨នាក់ ស្មើ៣៤.៥០% និងបរិញ្ញាបត្រមាន ចំនួន ៦០នាក់ស្មើ ១៥%។ តាមរយៈតារាងអាចសន្និដ្ឋានបានថា កម្រិតវប្បធម៌របស់ឪពុកសិស្ស ភាគច្រើន មានកម្រិត វប្បធម៌ត្រឹមវិទ្យាល័យ និងអនុវិទ្យាល័យ ក្នុងខេត្តស្វាយរៀង។ តាមរយៈតារាងប្រាក់ចំណូលរបស់ឪពុក ម្តាយសិស្សដែលចូលរួមបំពេញកម្រងសំណួរ គឺមិនមានប្រាក់ចំណូល មានចំនួន៤០នាក់ស្មើ១០%។ ក្រោម២០០ដុល្លារ មានចំនួន១៥៩នាក់ ស្មើ ៣៩.៧៥% ២០០ដុល្លារដល់៤០០ដុល្លារមានចំនួន១៤២ នាក់ ស្មើ៣៥.៥០%។ ច្រើនជាង៤០០ដុល្លារ មានចំនួន៥៩នាក់ ស្មើ១៤.៧៥%។ មុខរបរឪពុកម្តាយ សិស្សដែលចូលរួមបំពេញកម្រងសំណួរគឺ ផ្សេងៗមានចំនួន៣៧នាក់ ស្មើ៩.២៥%។ កម្មករមានចំនួន៤៩ នាក់ ស្មើ១២.២៥%។ អាជីករមានចំនួន៥៨នាក់ ស្មើ ១៤.៥០%។ មន្ត្រីរាជការមានចំនួន៦៦នាក់ស្មើ ១៦.៥០%។ កសិករមានចំនួន១៩០នាក់ស្មើ៤៧.៥០% ។ យោងតាមតារាងអាចសន្និដ្ឋានបានថាឪពុក

ម្តាយសិស្សភាគច្រើនជាកសិករ ដែលមានចំនួនរហូតដល់ ៤៧.៥០%។ ការចំណាយពេលក្នុងការសិក្សាក្នុង១ថ្ងៃរបស់សិស្ស គឺពី២-៦ម៉ោងមានចំនួន៨៣នាក់ស្មើ២០.៧៥% ពី៦-៨ម៉ោង មានចំនួន៨៨នាក់ស្មើ២២% ពី៨-១០ម៉ោងមានចំនួន១២៤នាក់ស្មើ៣១% ពី១០-១២ម៉ោងមានចំនួន៦៩នាក់ស្មើ១៧.៥៥% និងលើស១២ម៉ោងមានចំនួន៣៦នាក់ ស្មើ៩%។

**ផ្នែកទី២៖ អំពីការសិក្សាផ្ទាល់ខ្លួន**

*តារាង 17 ៖ ការសិក្សាផ្ទាល់ខ្លួនរបស់សិស្ស*

| **ការសិក្សាផ្ទាល់ខ្លួន** | | | | | |
|---|---|---|---|---|---|
| **ក. កត្តាក្នុងខ្លួន** | | | | | |
| ល.រ | បរិយាកាស | Mean | SD | កម្រិត | លំដាប់ |
| ៩ | ការចូលចិត្តរៀនរបស់សិស្ស | 3.77 | 0.77 | ខ្ពស់ | 2 |
| ១០ | គ្រូបានដាក់កិច្ចការផ្ទះនិងត្រួតពិនិត្យកែកិច្ចការនោះ | 3.60 | 0.62 | ខ្ពស់ | 3 |
| ១១ | កិច្ចការផ្ទះដែលគ្រូដាក់ឱ្យសិស្សធ្វើវាដោយខ្លួនឯង | 3.52 | 0.61 | ខ្ពស់ | 4 |
| ១២ | រំលឹកមេរៀនឡើងវិញបន្ទាប់ពីរៀនរួចពេលមកដល់ផ្ទះ និងមុនពេលទៅរៀន | 3.31 | 0.60 | មធ្យម | 6 |
| ១៣ | ចូលបណ្ណាល័យស្វែងរកឯកសារសម្រាប់រៀនបន្ថែម | 2.87 | 0.32 | មធ្យម | 7 |
| ១៤ | ការខិតខំរៀនរបស់សិស្សដើម្បីប្រឡងជាប់ និងទទួលបានលទ្ធផលសិក្សាល្អ | 4.04 | 0.73 | ខ្ពស់ | 1 |
| ១៥ | ដឹងពីលទ្ធផលសិក្សារបស់ខ្លួន ប្រចាំខែ ឆមាស និងឆ្នាំ | 3.46 | 0.61 | មធ្យម | 5 |
| **សរុប** | | **3.51** | **0.36** | **ខ្ពស់** | |

តាមរយៈតារាងបានបង្ហាញថា ការសិក្សាផ្ទាល់ខ្លួនរបស់សិស្សតាមសូចនាករនីមួយៗ ឃើញថា ការចូលចិត្តរៀនរបស់សិស្ស មានតម្លៃមធ្យម (Mean)=3.77, SD=0.77 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ2។ គ្រូបានដាក់កិច្ចការផ្ទះ និងត្រួតពិនិត្យកែកិច្ចការនោះ មានតម្លៃមធ្យម(Mean)=3.60,SD=0.62 ស្ថិតនៅកម្រិតខ្ពស់និងលំដាប់លេខ3។ កិច្ចការផ្ទះដែលគ្រូដាក់ឱ្យសិស្សធ្វើវាដោយខ្លួនឯង មានតម្លៃមធ្យម

(Mean)=3.52, SD=0.61 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ4។ រំលឹកមេរៀនឡើង វិញបន្ទាប់ពីរៀនរួចពេលមកដល់ផ្ទះ និងមុនពេលទៅរៀន មានតម្លៃមធ្យម (Mean)=3.31, SD=0.60 ស្ថិតនៅកម្រិតមធ្យមនិងលំដាប់លេខ6។ ចូលបណ្ណាល័យស្វែងរកឯកសារសម្រាប់រៀនបន្ថែម មានតម្លៃមធ្យម (Mean) =2.87, SD=0.32 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ7។ ការខិតខំរៀនរបស់សិស្ស ដើម្បីប្រឡងជាប់ និងទទួលបានលទ្ធផលសិក្សាល្អ មានតម្លៃមធ្យម (Mean)=4.04, SD=0.73 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ1។ ដឹងពីលទ្ធផលសិក្សារបស់ខ្លួន ប្រចាំខែ ឆមាស និងឆ្នាំ មានតម្លៃ មធ្យម (Mean)=3.46, SD=0.61 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ5។ សរុបមកការសិក្សាផ្ទាល់ខ្លួន (កត្តាខាងក្នុងខ្លួន) របស់សិស្ស ស្ថិតនៅក្នុងកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)=3.51 និង SD=0.36។

### ខ. **កត្តាខាងក្រៅ** (**ការលើកទឹកចិត្តរបស់គ្រូ**)

*តារាង 18 ៖ កត្តាខាងក្រៅ (ការលើកទឹកចិត្តរបស់គ្រូ)*

| ខ. កត្តាខាងក្រៅ (ការលើកទឹកចិត្តរបស់គ្រូ) | | | | | |
|---|---|---|---|---|---|
| ល.រ | បរិយាកាស | Mean | SD | កម្រិត | លំដាប់ |
| ១៦ | គ្រូបានជម្រុញឱ្យអនុវត្តមេរៀន ស្វ័យសិក្សាបន្ថែម | 4.07 | 0.72 | ខ្ពស់ | 1 |
| ១៧ | គ្រូសរសើរ ឬឱ្យជារង្វាន់ពេលសិស្សឆ្លើយត្រូវ | 3.32 | 0.66 | មធ្យម | 3 |
| ១៨ | គ្រូបានជួយបង្រៀនបន្ថែមពេលសិស្សរៀនយឺត | 3.76 | 0.70 | ខ្ពស់ | 2 |
| **សរុប** | | **3.71** | **0.37** | **ខ្ពស់** | |

តាមរយៈតារាងបានបង្ហាញថា កត្តាខាងក្រៅ (ការលើកទឹកចិត្តរបស់គ្រូ) តាមសូចនាករនីមួយៗ ឃើញថា គ្រូបានជម្រុញឱ្យអនុវត្តមេរៀនស្វ័យសិក្សាបន្ថែមមានតម្លៃមធ្យម (Mean)=4.07, SD=0.72 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ1។ គ្រូសរសើរឬឱ្យជារង្វាន់ពេលសិស្សឆ្លើយត្រូវ មានតម្លៃមធ្យម (Mean)=3.32, SD=0.66 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ3។ គ្រូបានជួយបង្រៀនបន្ថែមពេលសិស្សរៀនយឺត មានតម្លៃមធ្យម (Mean)=3.76, SD=0.70 ស្ថិតនៅក្នុងកម្រិតខ្ពស់ និងលំដាប់លេខ2។ សរុបមកកត្តាខាងក្រៅ (ការលើកទឹកចិត្តរបស់គ្រូ) ស្ថិតនៅក្នុងកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម

(Mean)=3.71 និង SD=0.36 ។

## ខ. កត្តាខាងក្រៅ (ការលើកទឹកចិត្តរបស់មាតាបិតា និងបងប្អូន មិត្តភក្តិ)

*តារាង 19 ៖ កត្តាខាងក្រៅ(ការលើកទឹកចិត្តរបស់មាតាបិតា និងបងប្អូន មិត្តភក្តិ)*

| ខ.កត្តាខាងក្រៅ (ការលើកទឹកចិត្តរបស់មាតាបិតា និងបងប្អូន មិត្តភក្តិ) | | | | | |
|---|---|---|---|---|---|
| ល.រ | បរិយាកាស | Mean | SD | កម្រិត | លំដាប់ |
| ១៩ | មាតាបិតាផ្តល់ពេលវេលាឱ្យកូនរៀន(ទាំងនៅសាលា និងស្វ័យសិក្សានៅផ្ទះ) | 4.11 | 0.81 | ខ្ពស់ | 2 |
| ២០ | មាតាបិតាផ្តល់លុយសម្រាប់សិក្សា | 3.09 | 0.52 | មធ្យម | 5 |
| ២១ | មាតាបិតាលើកទឹកចិត្តនិងដាស់តឿនកូនឱ្យខំរៀន | 4.28 | 0.75 | ខ្ពស់ | 1 |
| ២២ | មាតាបិតាបានពន្យល់និងណែនាំកូនធ្វើកិច្ចការផ្ទះគ្រូ ដាក់ឱ្យ | 3.73 | 0.87 | ខ្ពស់ | 3 |
| ២៣ | ពេលមានចម្ងល់មេរៀនសិស្សសួរសិស្សច្បង មិត្តភក្តិ បងប្អូនបង្កើត | 3.32 | 0.68 | មធ្យម | 4 |
| ២៤ | ចូលបណ្ណាល័យជាមួយមិត្តភក្តិដើម្បីអានសៀវភៅ | 2.88 | 0.31 | មធ្យម | 6 |
| **សរុប** | | **3.56** | **0.56** | **ខ្ពស់** | |

តាមរយៈតារាងបានបង្ហាញថាកត្តាខាងក្រៅ(ការលើកទឹកចិត្តរបស់មាតាបិតា និងបងប្អូនមិត្តភក្តិ) តាមសូចនាករនីមួយៗឃើញថា មាតាបិតាផ្តល់ពេលវេលាឱ្យកូនរៀន(នៅសាលា និងស្វ័យសិក្សានៅផ្ទះ) មានតម្លៃមធ្យម (Mean)=4.11, SD=0.81 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ2។ មាតាបិតា ផ្តល់លុយសម្រាប់សិក្សាមានតម្លៃមធ្យម (Mean)=3.09, SD=0.52 ស្ថិតនៅកម្រិតមធ្យម និងលំដាប់ លេខ5។ មាតាបិតាលើកទឹកចិត្តនិងដាស់តឿនកូនឱ្យខំរៀន មានតម្លៃមធ្យម (Mean)=4.28, SD=0.75 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ1។ មាតាបិតាបានពន្យល់និងណែនាំកូនធ្វើកិច្ចការផ្ទះគ្រូដាក់ឱ្យ មានតម្លៃមធ្យម (Mean)=3.75, SD=0.87 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ3។ ពេលមានចម្ងល់មេរៀនសិស្សសួរសិស្សច្បង មិត្តភក្តិ បងប្អូនបង្កើតមានតម្លៃមធ្យម (Mean)=3.32, SD=0.68 ស្ថិតនៅកម្រិត

មធ្យម និងលំដាប់លេខ4។ ចូលបណ្ណាល័យជាមួយមិត្តភក្តិដើម្បីអានសៀវភៅ មានតម្លៃមធ្យម (Mean) =2.88, SD=0.31 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ6។ សរុបមកកត្តាខាងក្រៅ (ការលើកទឹកចិត្តរបស់មាតាបិតា បងប្អូន និងមិត្តភក្តិ)របស់សិស្សស្ថិតនៅក្នុងកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean) = 3.56 និងSD=0.56។

## ផ្នែកទី៣៖ អំពីការទំនាក់ទំនរបស់សិស្ស

*តារាង 20 ៖ ការទំនាក់ទំនរបស់សិស្ស*

| **គ. ការទំនាក់ទំនរបស់សិស្ស** | | | | | | |
|---|---|---|---|---|---|---|
| ល.រ | បរិយាកាស | Mean | SD | កម្រិត | លំដាប់ |
| ២៥ | មានទំនាក់ទំនងល្អជាមួយមិត្តភក្តិ លោកគ្រូ អ្នកគ្រូ និងនាយកសាលា | 3.75 | 0.73 | ខ្ពស់ | 2 |
| ២៦ | មានទំនាក់ទំនងល្អជាមួយមាតាបិតា និងសហគមន៍ | 4.09 | 0.70 | ខ្ពស់ | 1 |
| ២៧ | ចូលរួមកម្មវិធីផ្សព្វផ្សាយការអប់រំផ្សេងៗ( អេដស៍ គ្រឿងញៀន យុវជន ) | 2.96 | 0.79 | មធ្យម | 3 |
| **សរុប** | | **3.60** | **0.57** | **ខ្ពស់** | |

តាមរយៈតារាងបានបង្ហាញថា ការទំនាក់ទំនរបស់សិស្សតាមសូចនាករនីមួយៗឃើញថាមានទំនាក់ទំនងល្អជាមួយមិត្តភក្តិ លោកគ្រូ អ្នកគ្រូ និងនាយកសាលាមានតម្លៃមធ្យម (Mean)=3.75, SD=0.73 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ2។ មានទំនាក់ទំនងល្អជាមួយមាតាបិតា និងសហគមន៍ មានតម្លៃមធ្យម (Mean)=4.09, SD=0.70 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ1។ មាតាបិតាលើកទឹកចិត្ត និងដាស់តឿនកូនឱ្យខំរៀន មានតម្លៃមធ្យម(Mean)=4.28, SD=0.75 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ1។ ចូលរួមកម្មវិធីផ្សព្វផ្សាយការអប់រំផ្សេងៗ (អេដស៍ គ្រឿងញៀន យុវជន) មានតម្លៃមធ្យម (Mean)=2.96, SD=0.79 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ3។ សរុបមកការទំនាក់ទំនងរបស់សិស្សស្ថិតនៅក្នុងកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)=3.60, SD=0.57។

*តារាង 21 ៖ សរុបមកការខិតខំរៀនរបស់សិស្សដើម្បីទទួលបានលទ្ធផលល្អ*

| ការខិតខំរៀនរបស់សិស្សដើម្បីទទួលបានលទ្ធផលល្អ | | | | | |
|---|---|---|---|---|---|
| **ល.រ** | **បរិយាកាស** | **Mean** | **SD** | **កម្រិត** | **លំដាប់** |
| ១ | កត្តាក្នុងខ្លួន | 3.51 | 0.36 | ខ្ពស់ | 4 |
| ២ | កត្តាក្រៅខ្លួន(ការលើកទឹកចិត្តរបស់គ្រូ) | 3.71 | 0.37 | ខ្ពស់ | 1 |
| ៣ | កត្តាក្រៅខ្លួន(ការលើកទឹកចិត្តរបស់ មាតាបិតា បងប្អូន និងមិត្តភក្តិ) | 3.56 | 0.56 | ខ្ពស់ | 3 |
| ៤ | ការទំនាក់ទំនងរបស់សិស្ស | 3.60 | 0.57 | ខ្ពស់ | 2 |
| **សរុប** | | **3.59** | **0.08** | **ខ្ពស់** | |

តាមរយៈតារាងបានបង្ហាញថា ការខិតខំរៀនសូត្ររបស់សិស្សដើម្បីទទួលបានលទ្ធផលល្អ តាមសូចនាករនីមួយៗឃើញថាកត្តាក្នុងខ្លួន មានតម្លៃមធ្យម (Mean)=3.51, SD=0.36 ស្ថិតនៅ កម្រិតខ្ពស់ និងលំដាប់លេខ4។ កត្តាក្រៅខ្លួន(ការលើកទឹកចិត្តរបស់គ្រូ)មានតម្លៃមធ្យម(Mean)=3.71, SD=0.37 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ1។ កត្តាក្រៅខ្លួន(ការលើកទឹកចិត្តរបស់ មាតាបិតា បងប្អូន និងមិត្តភក្តិ) មានតម្លៃមធ្យម (Mean)=3.56, SD=0.56 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់ លេខ3។ ការទំនាក់ទំនងរបស់សិស្ស មានតម្លៃមធ្យម (Mean)=3.60, SD=0.57 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ2។ សរុបមកការខិតខំរៀនសូត្ររបស់សិស្សដើម្បីទទួលបានលទ្ធផលល្អ គឺស្ថិតនៅកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)=3.59 និងSD=0.08

## ផ្នែកទី៤៖ បញ្ហាប្រឈមរបស់សិស្ស




*ក្រាប 1 ៖ បញ្ហាប្រឈមរបស់សិស្ស*

តាមរយៈរូបភាពបញ្ហាប្រឈមរបស់សិស្សដែលសិស្សចូលរួមបំពេញកម្រងសំណួរគឺជីវភាពគ្រួសារខ្វះខាតមានចំនួន៣០៣ស្មើ២៣.២១%។ សមត្ថភាពរៀននៅមានកម្រិតមានចំនួន២៤៣ ស្មើ១៦.៦៦% ។ គ្មានគោលដៅច្បាស់លាស់មានចំនួន១៩៤ ស្មើ១៤.៩០%។ សាលារៀននៅឆ្ងាយផ្ទះ ខ្វះមធ្យោបាយ ធ្វើដំណើរ មានចំនួន១១៦ ស្មើ៨.៩០%។ គ្មានការលើកទឹកចិត្តពីគ្រួសារ បងប្អូន មាន១០០ ស្មើ៧.៦៨% ។ មានស្នេហានិងមិត្តភក្តិនាំដើរលេង មានចំនួន១១៥ ស្មើ៨.៨៣%។ គ្រួសារមិនផ្ដល់ពេលវេលាឱ្យរៀនគ្រប់គ្រាន់ មានចំនួន១០៩ ស្មើ៨.៣១%។ ផ្សេងៗ មាន១២២ ស្មើ៩.៣៧%។

បញ្ហាប្រឈមចំបងៗដែលសិស្សជួបប្រទះមានដូចជា៖ ជីវភាពគ្រួសារខ្វះខាត ដោយសារគ្រួសាររបស់សិស្សភាគច្រើនមានឪពុកម្ដាយជាកសិករមានចំនួន៤៧% ហេតុនេះហើយទើបធ្វើឱ្យជីវភាព មានការខ្វះខាត។ ចំណែកឯសមត្ថភាពរៀនរបស់សិស្សម្នាក់ៗ ក៏ជាបញ្ហាដែរដោយសារសិស្សម្នាក់ៗ មានការ

យល់ដឹង និងការខិតខំរៀនខុសៗគ្នាធ្វើឱ្យពួកគេទទួលបានចំណេះដឹង និងលទ្ធផលខុសគ្នាដែរ។ ម្យ៉ាងទៀតបញ្ហាប្រឈមមួយទៀតនោះគឺ គ្មានការលើកទឹកចិត្តពីគ្រួសារ (មាតាបិតា បងប្អូន) ពីព្រោះពួកគាត់រវល់ធ្វើការរកស៊ី មិនសូវបានចូលរួមលើកទឹកចិត្តកូនឱ្យបានច្រើន ណាមួយកូនរៀនតាម Online នៅផ្ទះធ្វើឱ្យឪពុកម្តាយមួយចំនួនឱ្យកូនជួយធ្វើការងារផ្ទះ ដាំស្លថែមទៀតផង ជាហេតុធ្វើឱ្យសិស្សរៀន មិនសូវបានដិតដល់ដូចនៅសាលា។

## ៤.៣.៤. ការវិភាគទិន្នន័យលើក្រុមសំណួរមាតាបិតា/អាណាព្យាបាលសិស្ស

## ផ្នែកទី១៖ ព័ត៌មានទូទៅ

*តារាង 22 ៖ ព័ត៌មានទូទៅរបស់មាតាបិតាសិស្ស*

| ព័ត៌មានទូទៅរបស់មាតាបិតាសិស្ស | | | | |
|---|---|---|---|---|
| ល.រ | បរិយាកាស | | ចំនួន | ភាគរយ |
| ១ | ភេទ | ប្រុស | 50 | 50% |
| | | ស្រី | 50 | 50% |
| | | **សរុប** | **100** | **100%** |
| ២ | អាយុ | ៣១ទៅ៤០ឆ្នាំ | 14 | 14% |
| | | ៤១ទៅ៥០ឆ្នាំ | 56 | 56% |
| | | លើស៥០ឆ្នាំ | 30 | 30% |
| | | **សរុប** | **100** | **100%** |
| ៣ | កូនរៀនថ្នាក់ទី | ថ្នាក់ទី១០ | 20 | 20% |
| | | ថ្នាក់ទី១១ | 20 | 20% |
| | | ថ្នាក់ទី១២ | 60 | 60% |
| | | **សរុប** | **100** | **100%** |
| ៤ | កម្រិតវប្បធម៌ | បឋមសិក្សា | 28 | 28% |
| | | អនុវិទ្យាល័យ | 37 | 37% |
| | | វិទ្យាល័យ | 37 | 37% |
| | | មហាវិទ្យាល័យ | 12 | 12% |

| | | | | |
|---|---|---|---|---|
| | | **សរុប** | **100** | **100%** |
| ៥ | មុខរបរមាតាបិតាសិស្ស | ផ្សេងៗ | 8 | 8% |
| | | កម្មករ | 12 | 12% |
| | | អាជីវករ | 15 | 15% |
| | | មន្ត្រីរាជការ | 18 | 18% |
| | | កសិករ | 47 | 47% |
| | | **សរុប** | **100** | **100%** |
| ៦ | ប្រាក់ចំណូលមាតាបិតា | ច្រើនជាង ៤០០ដុល្លារ | 5 | 5% |
| | | ២០០ដុល្លារ ដល់៤០០ដុល្លារ | 47 | 47% |
| | | ក្រោម ២០០ ដុល្លារ | 38 | 38% |
| | | មិនមានប្រាក់ចំណូល | 10 | 10% |
| | | **សរុប** | **100** | **100%** |
| ៧ | ចំណាយឱ្យកូនរៀន ១នាក់១ថ្ងៃ | លើសពី១០,០០០៛ | 21 | 21% |
| | | ៥,០០០៛ ទៅ ៩,០០០៛ | 53 | 53% |
| | | ១,០០០៛ ទៅ ៤,០០០៛ | 25 | 25% |
| | | អត់សោះ | 1 | 1% |
| | | **សរុប** | **100** | **100%** |

តាមរយៈតារាងទាក់ទងភេទរបស់មាតាបិតាសិស្ស គឺភេទប្រុស មានចំនួន៥០នាក់ ស្មើ៥០% និងភេទស្រីមានចំនួន៥០នាក់ ស្មើ៥០%។ អាយុរបស់មាតាបិតាសិស្ស គឺអាយុ ចន្លោះពី 31-40ឆ្នាំ មានចំនួន ១៤នាក់ ស្មើ១៤%។ អាយុចន្លោះពី 41-50ឆ្នាំ មានចំនួន56នាក់ ស្មើ56%។ អាយុលើសពី ៥០ឆ្នាំ មានចំនួន ៣០នាក់ ស្មើ៣០%។ ថ្នាក់រៀនរបស់កូនគឺ មានកូនរៀនថ្នាក់ទី១០ មានចំនួន២០នាក់ ស្មើ២០% ថ្នាក់ទី១១មានចំនួន២០នាក់ ស្មើ២០% និងថ្នាក់ ទី១២ មានចំនួន៦០នាក់ ស្មើ៦០%។ ចំណែកឯកម្រិតវប្បធម៌របស់មាតាបិតាសិស្ស គឺបឋមសិក្សាមានចំនួន២៨នាក់ ស្មើ២៨%។ អនុវិទ្យាល័យមានចំនួន៣៧នាក់ ស្មើ៣៧%។ វិទ្យាល័យមានចំនួន៣៧នាក់ ស្មើ៣៧% និងមហាវិទ្យាល័យមានចំនួន១២នាក់ ស្មើ

១២%។ ដូចនេះកម្រិតវប្បធម៌ របស់មាតាបិតាសិស្សភាគច្រើនត្រឹម អនុវិទ្យាល័យ និងវិទ្យាល័យ។ មុខរបររបស់មាតាបិតាសិស្ស គឺមានមុខរបរផ្សេងៗគ្នាដូចជា ផ្សេងៗមានចំនួន៨នាក់ស្មើ៨%។កម្មករមានចំនួន១២នាក់ ស្មើ១២%។ អាជីវករមានចំនួន១៥នាក់ ស្មើ១៥% មន្ត្រីរាជការមានចំនួន១៨នាក់ ស្មើ១៨% និងកសិករមាន៤៧នាក់ ស្មើ ៤៧%។ តាមរយៈតារាងអាចសន្និដ្ឋានបានថា មាតាបិតាសិស្សភាគច្រើន ជាកសិករដែល មានរហូតដល់៤៧%។ ប្រាក់ចំណូលរបស់មាតាបិតាសិស្ស គឺមិនមានប្រាក់ចំណូលចំនួន១០នាក់ ស្មើ១០%។ ក្រោម២០០ដុល្លារ មានចំនួន៣៨នាក់ ស្មើ៣៨%។ ២០០ដុល្លារដល់៤០០ដុល្លារ មានចំនួន៤៧នាក់ ស្មើ៤៧% និងច្រើនជាង៤០០ដុល្លារ មានចំនួន៥នាក់ ស្មើ៥%។ ដូចនេះប្រាក់ចំណូលរបស់មាតាបិតាសិស្សភាគច្រើន២០០ដុល្លារដល់៤០០ដុល្លារក្នុងមួយខែ។ ការចំណាយលុយឱ្យកូនរៀន១នាក់ក្នុង១ថ្ងៃ របស់មាតាបិតាសិស្សគឺ អត់សោះមានចំនួន១នាក់ ស្មើ១%។ ១,០០០៛ទៅ៤,០០០៛ មានចំនួន ២៥នាក់ស្មើ២៥%។៥,០០០៛ទៅ៩,០០០៛ មានចំនួន៥៣នាក់ ស្មើ៥៣% និងលើសពី១០,០០០៛ មានចំនួន២១នាក់ ស្មើ២១%។ ដូចនេះការចំណាយលុយឱ្យកូនរៀន១នាក់ក្នុង១ថ្ងៃរបស់មាតាបិតា សិស្ស ភាគច្រើន៥,០០០៛ទៅ៩,០០០៛។

## ផ្នែកទី២៖ ការតាមដានការសិក្សារបស់កូន

### ក. ការតាមដានការសិក្សាកូន

*តារាង 23 ៖ មាតាបិតាតាមដានការសិក្សាកូន*

| | ក. មាតាបិតាតាមដានការសិក្សាកូន | | | | |
|---|---|---|---|---|---|
| ល.រ | បរិយាកាស | Mean | SD | កម្រិត | លំដាប់ |
| 8 | ការបញ្ជូនកូនទៅរៀនឱ្យបានទៀងទាត់ជាភារកិច្ចសំខាន់របស់មាតាបិតាសិស្ស | 4.63 | 0.54 | ខ្ពស់ | 1 |
| 9 | បានពិនិត្យតាមដានលើកិច្ចការរៀនសូត្រនិងកិច្ចការផ្ទះរបស់កូន | 3.56 | 0.67 | ខ្ពស់ | 3 |
| 10 | បានផ្តល់ពេលវេលាឱ្យកូនសិក្សាគ្រប់គ្រាន់ទាំងនៅសាលានិងស្វ័យសិក្សានៅផ្ទះ | 3.89 | 0.65 | ខ្ពស់ | 2 |

| | | | | | |
|---|---|---|---|---|---|
| 11 | មានទំនាក់ទំនងជាមួយ លោកគ្រូ អ្នកគ្រូ និងនាយកសាលាដើម្បីសួរនាំអំពីការសិក្សាកូន | 3.00 | 0.81 | មធ្យម | 5 |
| 12 | បានដឹងពីលទ្ធផលនៃការសិក្សារបស់កូន ប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំ | 3.48 | 0.79 | មធ្យម | 4 |
| **សរុប** | | **3.71** | **0.60** | **ខ្ពស់** | |

តាមរយៈតារាងបានបង្ហាញថា មាតាបិតាតាមដានការសិក្សាកូន តាមសូចនាករនីមួយៗឃើញថា ការបញ្ជូនកូនទៅរៀនឱ្យបានទៀងទាត់ជាភារកិច្ចសំខាន់របស់មាតាបិតាសិស្ស មានតម្លៃមធ្យម (Mean) =4.63, SD=0.54 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ1។ បានពិនិត្យតាមដានលើកិច្ចការរៀនសូត្រ និងកិច្ចការផ្ទះរបស់កូន មានតម្លៃមធ្យម (Mean)=3.56, SD=0.67 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ 3។ បានផ្តល់ពេលវេលាឱ្យកូនសិក្សាគ្រប់គ្រាន់ទាំងនៅសាលានិងស្វ័យសិក្សានៅផ្ទះមានតម្លៃមធ្យម (Mean) =3.89, SD=0.65 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ2។ មានទំនាក់ទំនងជាមួយ លោកគ្រូ អ្នកគ្រូ និងនាយកសាលាដើម្បីសួរនាំអំពីការសិក្សាកូន មានតម្លៃមធ្យម (Mean)=3.00, SD=0.81 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ៥។ បានដឹងពីលទ្ធផលនៃការសិក្សារបស់កូន ប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំ មានតម្លៃមធ្យម(Mean)=3.48, SD=0.79ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ៤។ សរុបមកមាតាបិតាតាមដានការសិក្សាកូន ស្ថិតនៅក្នុងកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)=3.71, SD=0.60។

យោងតាមរយៈតារាងខាងលើ បានបង្ហាញថា ក្នុងចំណោមសូចនាករទាំង៥ មានសូចនាករទី១ ការបញ្ជូនកូនទៅរៀនឱ្យបានទៀងទាត់ជាភារកិច្ចសំខាន់របស់មាតាបិតាសិស្ស មានតម្លៃមធ្យម (Mean) =4.63 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ1 ពីព្រោះមាតាបិតាទាំងអស់គាត់គិតថាការអប់រំមានសារៈសំខាន់សម្រាប់កូនៗ ដូច្នេះហើយគាត់ត្រូវតែបញ្ជូនកូនឱ្យទៅសាលារៀនឱ្យបានទៀតទាត់ ក៏ដូចជាគោរព តាមការណែនាំរបស់រាជរដ្ឋាភិបាលដែលតម្រូវឱ្យ មាតាបិតាទាំងអស់នាំកូនដែលមានអាយុ៦ឆ្នាំ ឬ ៧០ខែ ឡើង ទៅចុះឈ្មោះចូលរៀនឱ្យបានគ្រប់ៗគ្នា។ ក្នុងនោះសូចនាករទី៥ មានទំនាក់ទំនងជាមួយ លោកគ្រូ អ្នកគ្រូ និងនាយកសាលាដើម្បីសួរនាំអំពីការសិក្សាកូនស្ថិតនៅកម្រិតមធ្យមដែលមានតម្លៃមធ្យម

(Mean) =3.00 និង SD=0.81 ពីព្រោះថាមាតាបិតាសិស្ស ពួកគាត់រវល់ធ្វើការរកស៊ីតាមមុខរបរផ្សេងៗគ្នា មិនសូវមានទំនាក់ទំនងជាមួយគ្រូ និងនាយកសាលាក៏ដូចជាមិនសូវបានចូលរួមកម្មវិធីផ្សេងៗ ដែលសាលាបានរៀបចំ ពេលសាលាធ្វើបុណ្យផ្កា ឬថ្ងៃបើកបវេសនកាលជាដើម។ សរុបមកមាតាបិតាសិស្សតាមដានការសិក្សា របស់កូន ស្ថិតនៅកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)=3.71 និងSD=0.60។

### ខ&គ. ការផ្តល់ថវិកា និងការលើកទឹកចិត្តកូនរបស់មាតាបិតា

*តារាង 24 ៖ ការផ្តល់ថវិកា និងការលើកទឹកចិត្តកូនរបស់មាតាបិតា*

| ខ&គ.ការផ្តល់ថវិកា និងការលើកទឹកចិត្តកូនរបស់មាតាបិតា | | | | | |
|---|---|---|---|---|---|
| ល.រ | បរិយាកាស | Mean | SD | កម្រិត | លំដាប់ |
| 13 | បានផ្តល់ថវិកាសម្រាប់ការសិក្សារៀនសូត្រកូនទាំងថ្លៃសម្ភារសិក្សា ចាយវាយ រៀនគួរ | 3.31 | 0.59 | មធ្យម | 4 |
| 14 | បានជំរុញកូនឱ្យខំរៀន ធ្វើលំហាត់ឬកិច្ចការគ្រូដាក់ឱ្យ និងស្វ័យសិក្សានៅផ្ទះ | 3.97 | 0.77 | ខ្ពស់ | 2 |
| 15 | បានសរសើរ ឬឱ្យជារង្វាន់កូននៅពេលកូនរៀនពូកែ បានលេខល្អ | 3.50 | 0.71 | មធ្យម | 3 |
| 16 | បានជួយបង្រៀនកូនបន្ថែមពេលទំនេរពីការងាររកស៊ី | 3.24 | 0.80 | មធ្យម | 5 |
| 17 | បានកើនរំលឹកដល់កូនជាប្រចាំឱ្យខំរៀនដើម្បីមានចំណេះដឹង ប្រឡងជាប់ មានការងារល្អធ្វើ | 4.21 | 0.59 | ខ្ពស់ | 1 |
| **សរុប** | | **3.65** | **0.42** | **ខ្ពស់** | |

តាមរយៈតារាងបានបង្ហាញថាការផ្តល់ថវិកានិងការលើកទឹកចិត្តកូនរបស់មាតាបិតាតាមសូចនាករនីមួយៗឃើញថា បានផ្តល់ថវិកាសម្រាប់ការសិក្សារៀនសូត្រកូនទាំងថ្លៃសម្ភារសិក្សា ចាយវាយ រៀនគួរមានតម្លៃមធ្យម (Mean)=3.31, SD=0.59 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ៤។ បានជំរុញកូនឱ្យខំរៀន ធ្វើលំហាត់ឬកិច្ចការគ្រូដាក់ឱ្យ និងស្វ័យសិក្សានៅផ្ទះ មានតម្លៃមធ្យម (Mean)=3.97, SD=0.77 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ2។ បានសរសើរ ឬឱ្យជារង្វាន់កូននៅពេលកូនរៀនពូកែ បានលេខល្អ មានតម្លៃមធ្យម (Mean)=3.50, SD=0.71 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ3។ បានជួយបង្រៀន

កូនបន្ថែមពេលទំនេរពីការងាររកស៊ី មានតម្លៃមធ្យម (Mean)=3.24, SD=0.80 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ៥។ បានកើនរំលឹកដល់កូនជាប្រចាំឱ្យខំរៀនដើម្បីមានចំណេះដឹង ប្រឡងជាប់ មានការងារល្អធ្វើ មានតម្លៃមធ្យម (Mean)=4.21, SD=0.59 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ១។ សរុបមកការផ្តល់ថវិកា និងការលើកទឹកចិត្តកូនរបស់មាតាបិតា ស្ថិតនៅក្នុងកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)=3.65 និងSD=0.42។

យោងតាមរយៈតារាងខាងលើបានបង្ហាញថា ក្នុងចំណោមសូចនាករទាំង៥ មានសូចនាករទី៥ បានកើនរំលឹកដល់កូនជាប្រចាំឱ្យខំរៀនដើម្បីមានចំណេះដឹងប្រឡងជាប់ មានការងារល្អធ្វើ ស្ថិតនៅកម្រិតខ្ពស់ ពីព្រោះថាមាតាបិតាគ្រប់រូបជាអ្នកនៅជាមួយកូនផ្ទាល់ហើយចង់ឃើញកូនទទួលបាជោគជ័យពេលបញ្ចប់ការសិក្សាដោយមានការងារធ្វើល្អនៅក្នុងសង្គម។ ក្នុងនោះសូចនាករទី៤បានជួយបង្រៀនកូនបន្ថែមពេល ទំនេរពីការងាររកស៊ី ស្ថិតនៅកម្រិតមធ្យម ពីព្រោះថាមាតាបិតាមួយចំនួនគាត់រវល់ធ្វើការច្រើន អ្នកខ្លះមានចំណេះដឹងទាប មិនអាចជួយបង្រៀនកូនពេលដែលកូនរៀនថ្នាក់ខ្ពស់ជាងខ្លួន ជាហេតុធ្វើឱ្យពួកគាត់ចូលរួមបានខ្លះស្ថិតនៅកម្រិតមធ្យមនេះឯង។ ចំណែកឯការផ្តល់ថវិកាសម្រាប់ការសិក្សារៀនសូត្រកូន ទាំងថ្លៃសម្ភារសិក្សា ចាយវាយ រៀនគួរ ស្ថិតនៅកម្រិតមធ្យម ព្រោះថាមាតាបិតាសិស្សភាគច្រើនជាកសិករ កម្មករដែលមានចំណូលមធ្យម ជាហេតុធ្វើឱ្យការចំណាយលើកូនរៀនស្ថិតនៅកម្រិតមធ្យមនេះ។ សរុបមកការផ្តល់ថវិកា និងការលើកទឹកចិត្តកូនរបស់មាតាបិតា ស្ថិតនៅក្នុងកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)=3.65 និងSD=0.42។

## ផ្នែកទី៣៖ អំពីការទំនាក់ទំនង

*តារាង 25 ៖ ការទំនាក់ទំនងរបស់មាតាបិតា*

| ការទំនាក់ទំនងរបស់មាតាបិតា | | | | | |
|---|---|---|---|---|---|
| ល.រ | បរិយាកាស | Mean | SD | កម្រិត | លំដាប់ |
| 18 | ទំនាក់ទំនងល្អជាមួយកូន ផ្តល់ភាពកក់ក្តៅ ភាពស្និទ្ធស្នាលក្នុងគ្រួសារ | 4.37 | 0.69 | ខ្ពស់ | 1 |

| | | | | | |
|---|---|---|---|---|---|
| 19 | មានទំនាក់ទំនងល្អជាមួយ លោកគ្រូ អ្នកគ្រូ និងនាយក | 3.17 | 0.77 | មធ្យម | 2 |
| 20 | បានចូលរួមកម្មវិធីផ្សេងៗទាក់ទងការអប់រំនៅក្នុងសាលារៀន និងសហគមន៍ | 2.73 | 0.86 | មធ្យម | 3 |
| 21 | បានចូលរួមធ្វើផែនការអភិវឌ្ឍសាលាជាគណៈកម្មការផ្សេងៗ | 2.17 | 0.85 | ទាប | 4 |
| **សរុប** | | **3.11** | **0.93** | **មធ្យម** | |

តាមរយៈតារាងបានបង្ហាញថា ការទំនាក់ទំនងរបស់មាតាបិតាសិស្សតាមសូចនាករនីមួយៗឃើញថា ទំនាក់ទំនងល្អជាមួយកូន ផ្ដល់ភាពកក់ក្ដៅភាពស្និទ្ធស្នាលក្នុងគ្រួសារ មានតម្លៃមធ្យម (Mean)=4.37 , SD=0.69 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ1។ មានទំនាក់ទំនងល្អជាមួយ លោកគ្រូ អ្នកគ្រូ និងនាយក មានតម្លៃមធ្យម(Mean)=3.17, SD=0.77 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ2។ បានចូលរួមកម្មវិធីផ្សេងៗទាក់ទងការអប់រំនៅក្នុងសាលារៀន និងសហគមន៍ មានតម្លៃមធ្យម (Mean)=2.73 និង SD=0.86ស្ថិតនៅកម្រិតមធ្យមនិងលំដាប់លេខ3។ បានចូលរួមធ្វើផែនការអភិវឌ្ឍសាលាជាគណៈកម្មការផ្សេងៗ មានតម្លៃមធ្យម (Mean)=2.17, SD=0.85 ស្ថិតនៅកម្រិតទាប និងលំដាប់លេខ៤។ សរុបមកការទំនាក់ទំនងរបស់មាតាបិតាសិស្ស ស្ថិតនៅក្នុងកម្រិតមធ្យម ដែលមានតម្លៃមធ្យម (Mean) =3.11 និង SD=0.93 ។ តាមរយៈតារាងខាងលើបានបង្ហាញថា ក្នុងចំណោមសូចនាករទាំង៤ មានសូចនាករទី១ ទំនាក់ ទំនងល្អជាមួយកូន ផ្ដល់ភាពកក់ក្ដៅ ភាពស្និទ្ធស្នាលក្នុងគ្រួសារ ស្ថិតនៅកម្រិតខ្ពស់ ពីព្រោះថាមាតាបិតា គ្រប់រូបតែងតែស្រឡាញ់ មើលថែថ្នាក់ថ្នម ផ្ដល់ភាពកក់ក្ដៅ ភាពស្និទ្ធស្នាលក្នុងគ្រួសារដើម្បីបង្កើតសុភមង្គលក្នុងគ្រួសាររៀងៗខ្លួន។ មានទំនាក់ទំនងល្អជាមួយ លោកគ្រូ អ្នកគ្រូ និងនាយក ស្ថិននៅកម្រិតមធ្យម ពីព្រោះថាមាតាបិតាសិស្សរវល់ធ្វើការរកស៊ីរៀងៗខ្លួន។ បានចូលរួមកម្មវិធីផ្សេងៗទាក់ទងការអប់រំនៅក្នុងសាលារៀន និងសហគមន៍ ស្ថិតនៅកម្រិតមធ្យម។ បានចូលរួមធ្វើផែនការអភិវឌ្ឍសាលា ជាគណៈកម្មការផ្សេងៗ ស្ថិតនៅកម្រិតទាប។ សរុបមកការទំនាក់ទំនងរបស់មាតាបិតាសិស្ស ស្ថិតនៅកម្រិតមធ្យម ដែលមានតម្លៃមធ្យម (Mean)=3.11 និងSD=0.93។

***តារាង 26 ៖ ការចូលរួមរបស់មាតាបិតាក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស***

| ការចូលរួមរបស់មាតាបិតាក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស(កូន) | | | | | |
|---|---|---|---|---|---|
| ល.រ | បរិយាកាស | Mean | SD | កម្រិត | លំដាប់ |
| ១ | ការតាមដានការសិក្សាកូន | 3.71 | 0.60 | ខ្ពស់ | 1 |
| ២ | ការផ្តល់ថវិកានិងការលើកទឹកចិត្តកូនរបស់មាតាបិតា | 3.65 | 0.42 | ខ្ពស់ | 2 |
| ៣ | ការទំនាក់ទំនង (ជាមួយកូន លោកគ្រូ អ្នកគ្រូ នាយកសាលា និងសហគមន៍) | 3.11 | 0.93 | មធ្យម | 3 |
| **សរុប** | | **3.49** | **0.33** | **មធ្យម** | |

តាមរយៈតារាងបានបង្ហាញថា ការចូលរួមរបស់មាតាបិតាក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស(កូន) តាមសូចនាករនីមួយៗឃើញថា ការតាមដានការសិក្សាកូន មានតម្លៃមធ្យម (Mean)=3.71 និងSD=0.60 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ1។ ការផ្តល់ថវិកានិងការលើកទឹកចិត្តកូន របស់មាតាបិតា មានតម្លៃមធ្យម (Mean)=3.65 និងSD=0.42 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ2។ ការទំនាក់ទំនង (ជាមួយកូន លោកគ្រូ អ្នកគ្រូ នាយកសាលា និងសហគមន៍) មានតម្លៃមធ្យម (Mean)=3.11 និង SD=0.93 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ3។ សរុបមកការចូលរួមរបស់មាតាបិតា ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស (កូន) ស្ថិតនៅក្នុងកម្រិតមធ្យម ដែលមានតម្លៃមធ្យម (Mean) = 3.49 និងSD=0.33។

យោងតាមរយៈតារាងខាងលើបានបង្ហាញថា ក្នុងចំណោមសូចនាករទាំង3 មានសូចនាករទី១ ការតាមដានការសិក្សាកូន ស្ថិតនៅកម្រិតខ្ពស់ ដោយសារមាតាបិតា បានយកចិត្តទុកដាក់លើការសិក្សារបស់កូន ដោយបញ្ជូនកូនទៅរៀនឱ្យបានទៀងទាត់ ហើយទំនាក់ទំនងទៅគ្រូ និងនាយកសាលាដើម្បីដឹងពីការសិក្សារបស់កូនដូចជា ចំណាត់ថ្នាក់ប្រចាំខែ ឆមាស និងប្រចាំឆ្នាំជាដើម។ ចំណែកឯសូចនាករទី២ និយាយពីការផ្តល់ថវិកានិងការលើកទឹកចិត្តកូនរបស់មាតាបិតា ស្ថិតនៅកម្រិតខ្ពស់ ត្រង់ចំណុចថវិកាមានន័យថាមាតាបិតាតែងតែផ្តល់ថវិកាដល់កូនរបស់ពួកគាត់តាមលទ្ធភាពដែលពួកគាត់អាចរកបាន អាចថា

មានកម្រិតទាប មធ្យម និងច្រើនអាស្រ័យលើជីវភាពគ្រួសារ។ ចំណែកឯការលើកទឹកចិត្តកូនរបស់មាតាបិតាគឺពួកគាត់បាន ជំរុញលើកទឹកចិត្តកូនឱ្យខិតខំរៀន ផ្តល់ពេលវេលាស្វ័យសិក្សានៅផ្ទះ ផ្តល់ជារង្វាន់ ឬសរសើរពេលកូនរៀនពូកែ បានចំណាត់ថ្នាក់ល្អ ជួយពន្យល់និងបង្រៀនបន្ថែមពេលទំនេរពីការងារ ដើម្បីគាំទ្រដល់ការសិក្សារបស់កូនថែមទៀតផង។ ការទំនាក់ទំនង (ជាមួយកូន លោកគ្រូ អ្នកគ្រូ នាយកសាលា និងសហគមន៍) ស្ថិតនៅកម្រិតមធ្យម ពីព្រោះមាតាបិតាសិស្សរវល់ធ្វើការរៀងៗខ្លួនទើបធ្វើឱ្យពួកគាត់ មិនសូវមានទំនាក់ទំនងល្អជាមួយលោកគ្រូ អ្នកគ្រូ និងនាយកសាលាជាដើម។ សរុបមកការចូលរួម របស់មាតាបិតា ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស(កូន)ស្ថិតនៅកម្រិតមធ្យម ដែលមានតម្លៃមធ្យម (Mean)=3.49 និងគម្លាតស្តង់ដា (SD)=0.33។

## ផ្នែកទី៤៖ បញ្ហាប្រឈមរបស់មាតាបិតា




*ក្រាប 2 ៖ បញ្ហាប្រឈមរបស់មាតាបិតាសិស្សមិនសូវបានចូលរួមក្នុងការសិក្សារបស់កូន*

តាមរយៈរូបភាពទាក់ទង បញ្ហាប្រឈមរបស់មាតាបិតាសិស្សមិនសូវបានចូលរួមក្នុងការសិក្សារបស់កូន ដែលបានចូលរួមបំពេញកម្រងសំណួរគឺ មិនសូវមានទាក់ទងជាមួយលោកគ្រូ អ្នកគ្រូ និងនាយកមានចំនួន១១.៦៦%, ជីវភាពខ្វះខាតមានចំនួន១១.៦៦%, រវល់ធ្វើការរកស៊ី មានចំនួន២២.៣៣%,

មានចំណេះដឹងទាបមានចំនួន១៥.៣៣%, គ្មានជំនាញក្នុងការអប់រំ បង្រៀនកូនមានចំនួន១០%, គិតថា ឱ្យកូនទៅរៀននៅសាលាគ្រប់គ្រាន់ហើយមានចំនួន១១.៣៣%, ឱ្យកូនជួយធ្វើការងារផ្ទះនិងការងាររក លុយ មានចំនួន៣.៣៣%, មិនមានពេលវេលាបង្រៀនកូនចំនួន៩.៣៣%, និងមិនបានតាមដានការ សិក្សាកូន មានចំនួន៥%។ សរុបមកបញ្ហាប្រឈមដែលមាតាបិតាសិស្សមិនសូវបាន ចូលរួមការសិក្សា របស់កូនសំខាន់ៗ មានដូចជា មានជីវភាពខ្វះខាតដោយសារមាតាបិតាសិស្សភាគច្រើនមានមុខរបរជា កសិករ រហូតដល់៤៧%, រវល់ធ្វើការរកស៊ីមានចំនួន២២.៣៣% ពីព្រោះពួកគាត់ខិតខំធ្វើការរកលុយ សម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ ទើបមិនសូវបានចូលរួមបង្រៀនកូន, មានចំណេះដឹងទាប ដោយសារមាតា បិតាសិស្សខ្លះមានចំណេះដឹងទាបគឺមានចំនួន២៨%រៀនត្រឹមកម្រិតបឋមសិក្សា និង៣៧%រៀនត្រឹម កម្រិតអនុវិទ្យាល័យដែលជាឧបសគ្គក្នុងការផ្សព្វផ្សាយពីកម្មវិធីអប់រំផ្សេងៗ និងពួកគាត់មិនអាចជួយ បង្រៀន ណែនាំកូនដែលសិក្សា នៅថ្នាក់ខ្ពស់ជាខ្លួនបាន។ ម្យ៉ាងទៀតមាតាបិតាខ្លះគាត់គិតថា ឱ្យកូនទៅ រៀននៅសាលារៀន គឺគ្រប់គ្រាន់ហើយ ពួកគាត់មិនបាច់បង្រៀនទៀតក៏បាន ដោយគាត់គ្រាន់តែផ្តល់លុយ ពេលវេលា និងលើកទឹកចិត្តកូនបានហើយណាមួយពួកគាត់គ្មានជំនាញ និងវិធីសាស្ត្រអប់រំផងដែរ។

### ៤.៣.៥. ការវិភាគទិន្នន័យលើកម្រងសម្រាប់អាជ្ញាធរដែនដី

### ផ្នែកទី១៖ ព័ត៌មានទូទៅ

*តារាង 27 ៖ ព័ត៌មានទូទៅរបស់អាជ្ញាធរ*

| ព័ត៌មានទូទៅរបស់អាជ្ញាធរ | | | | |
|---|---|---|---|---|
| **ល.រ** | **បរិយាកាស** | | **ចំនួន** | **ភាគរយ** |
| ១ | ភេទ | ប្រុស | 18 | 90% |
| | | ស្រី | 2 | 10% |
| | | **សរុប** | **20** | **100%** |
| ២ | អាយុ | 41-50 | 8 | 40% |
| | | លើស50 | 12 | 60% |

| | | | | |
|---|---|---|---|---|
| | | **សរុប** | **20** | **100%** |
| ៣ | កម្រិតវប្បធម៌ | បរិញ្ញាបត្រ | 1 | 5% |
| | | វិទ្យាល័យ | 13 | 65% |
| | | អនុវិទ្យាល័យ | 6 | 30% |
| | | **សរុប** | **20** | **100%** |
| ៤ | មុខតំណែងបច្ចុប្បន្ន | មេភូមិ | 5 | 25% |
| | | មេឃុំ/ចៅសង្កាត់ | 6 | 30% |
| | | ក្រុមប្រឹក្សាឃុំ | 4 | 20% |
| | | ក្រុមប្រឹក្សាស្រុក | 3 | 15% |
| | | គណៈកម្មការទ្រទ្រង់សាលា | 2 | 10% |
| | | **សរុប** | **20** | **100%** |
| ៥ | បទពិសោធន៍ការងារ | ក្រោម៥ឆ្នាំ | 4 | 20% |
| | | ៥ទៅ៩ឆ្នាំ | 3 | 15% |
| | | ១០ទៅ១៤ឆ្នាំ | 6 | 30% |
| | | ១៥ទៅ១៩ឆ្នាំ | 4 | 20% |
| | | លើស២០ឆ្នាំ | 3 | 15% |
| | | **សរុប** | **20** | **100%** |

តាមរយៈតារាងទាក់ទងភេទរបស់អាជ្ញាធរ គឺភេទប្រុសមាន ចំនួន១៨នាក់ ស្មើ៩០%។ ស្រីមាន ចំនួន២នាក់ ស្មើ១០%។ តាមរយៈចម្លើយខាងលើយើងអាចសន្និដ្ឋាន អាជ្ញាធរដែនដីឬគណៈកម្មការទ្រទ្រង់សាលាភាគច្រើនជាមនុស្សប្រុស។ អាយុរបស់អាជ្ញាធរ គឺអាយុពី៤១-៥០ ឆ្នាំមានចំនួន៨នាក់ ស្មើ ៤០%។ អាយុលើសពី៥០ឆ្នាំ មានចំនួន១២នាក់ ស្មើ៦០%។ តាមរយៈចម្លើយខាងលើអាចសន្និដ្ឋាន អាជ្ញាធរ/ដែនដីគណកម្មការទ្រទ្រង់សាលាភាគច្រើនមានអាយុលើស៥០ឆ្នាំ។ កម្រិតវប្បធម៌របស់អាជ្ញាធរ

គឺ បរិញ្ញាបត្រមានចំនួន១នាក់ ស្មើ៥%។ វិទ្យាល័យមានចំនួន១២នាក់ ស្មើ៦៥%។ អនុវិទ្យាល័យមានចំនួន៦នាក់ ស្មើ៣០%។ តាមរយៈចម្លើយខាងលើអាចសន្និដ្ឋានបានថា អាជ្ញាធរដែនដីឬគណៈកម្មការទ្រទ្រង់សាលាភាគច្រើនមាន មានកម្រិតវប្បធម៌ត្រឹមវិទ្យាល័យ។ មុខតំណែងបច្ចុប្បន្នរបស់អាជ្ញាធរ គឺក្រុមប្រឹក្សាស្រុកមានចំនួន៣នាក់ ស្មើ១៥%។ ក្រុមប្រឹក្សាឃុំមានចំនួន៤នាក់ ស្មើ២០%។ គណៈកម្មការទ្រទ្រង់សាលា មានចំនួន២នាក់ ស្មើ១០%។ មេឃុំ ចៅសង្កាត់មានចំនួន៨នាក់ ស្មើ៣០%។ មេភូមិ មានចំនួន៥នាក់ ស្មើ២៥%។ បទពិសោធន៍ការងារក្នុងមុខតំណែងរបស់អាជ្ញាធរ គឺក្រោម៥ឆ្នាំ មានចំនួន៤នាក់ ស្មើ២០%។ ៥ទៅ៩ឆ្នាំ មានចំនួន៣នាក់ ស្មើ១៥%។ ១០ទៅ១៤ឆ្នាំ មានចំនួន៦នាក់ ស្មើ៣០%។ ១៥ទៅ១៩ឆ្នាំ មានចំនួន៤នាក់ ស្មើ២០%។ លើសពី២០ ឆ្នាំមាន៣នាក់ ស្មើ១៥%។

## ផ្នែកទី២៖ អំពីការចូលរួមអភិវឌ្ឍសាលារៀន

### ក. ការចូលរួមធ្វើផែនការអភិវឌ្ឍសាលា

*តារាង 28 ៖ ការចូលរួមធ្វើផែនការអភិវឌ្ឍសាលារបស់អាជ្ញាធរដែនដី គណៈកម្មការទ្រទ្រង់សាលា*

| ក. ការចូលរួមធ្វើផែនការអភិវឌ្ឍសាលារបស់អាជ្ញាធរដែនដី/គណៈកម្មការទ្រទ្រង់សាលា | | | | | |
|---|---|---|---|---|---|
| ល.រ | បរិយាកាស | Mean | SD | កម្រិត | លំដាប់ |
| 6 | ចូលរួមធ្វើផែនការអភិវឌ្ឍសាលា | 3.25 | 0.55 | មធ្យម | 4 |
| 7 | តាមដានការបំពេញការងាររបស់គ្រូបង្រៀន | 2.90 | 0.44 | មធ្យម | 6 |
| 8 | ចូលរួមកម្មវិធីផ្សេងៗនៅសាលាទាក់ទងការអប់រំ | 3.50 | 0.51 | មធ្យម | 3 |
| 9 | លើកយកបញ្ហាអប់រំទៅពិភាក្សាពេលប្រជុំក្នុងអង្គភាព | 2.85 | 0.36 | មធ្យម | 7 |
| 10 | ចូលរួមលុបបំបាត់បាតុភាពមិនល្អជុំវិញសាលា (គ្រឿងញៀន ល្បែងស៊ីសង...) | 3.60 | 0.59 | ខ្ពស់ | 2 |
| 11 | ចូលរួមផ្សព្វផ្សាយដល់សហគមន៍ មាតាបិតាឱ្យបញ្ជូនកូនទៅរៀនឱ្យបានទៀងទាត់ | 4.00 | 0.32 | ខ្ពស់ | 1 |
| 12 | ចូលរួមសហការណ៍ជាមួយអង្គការជាតិ និងអន្តរជាតិស្វែងរកជំនួយអភិវឌ្ឍសាលា | 3.05 | 0.51 | មធ្យម | 5 |
| **សរុប** | | **3.31** | **0.41** | **មធ្យម** | |

តាមរយៈតារាងបានបង្ហាញថា ការចូលរួមធ្វើផែនការអភិវឌ្ឍសាលារបស់អាជ្ញាធរដែនដី/គណៈកម្មការទ្រទ្រង់សាលា តាមសូចនាករនីមួយៗឃើញថាចូលរួមធ្វើផែនការអភិវឌ្ឍសាលាមានតម្លៃមធ្យម (Mean)=3.25, SD=0.55 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ4។ តាមដានការបំពេញការងាររបស់គ្រូបង្រៀនមានតម្លៃមធ្យម (Mean)=2.90, SD=0.44 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ6។ ចូលរួមកម្មវិធីផ្សេងៗនៅសាលាទាក់ទងការអប់រំ មានតម្លៃមធ្យម (Mean)=3.50, SD=0.51 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ3។ លើកយកបញ្ហាអប់រំទៅពិភាក្សាពេលប្រជុំក្នុងអង្គភាព មានតម្លៃមធ្យម (Mean)=2.85, SD=0.36 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ7។ ចូលរួមលុបបំបាត់បាតុភាពមិនល្អជុំវិញសាលា (គ្រឿងញៀន ល្បែងស៊ីសង...) មានតម្លៃមធ្យម (Mean)=3.60, SD=0.59 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ2។ ចូលរួមផ្សព្វផ្សាយដល់សហគមន៍ មាតាបិតាឱ្យបញ្ជូនកូនទៅរៀនឱ្យ បានទៀងទាត់មានតម្លៃមធ្យម (Mean)=4.00, SD=0.32 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ1។ ចូលរួមសហការណ៍ជាមួយអង្គការជាតិនិងអន្តរជាតិ ស្វែងរកជំនួយអភិវឌ្ឍសាលា ស្ថិតនៅកម្រិតមធ្យមដែលមានតម្លៃមធ្យម(Mean)= 3.05, SD=0.51 និងលំដាប់លេខ5។

តាមរយៈតារាងខាងលើបានបង្ហាញថាក្នុងចំណោមសូចនាករទាំងអស់ មានសូចនាករនិយាយពីចូលរួមផ្សព្វផ្សាយដល់សហគមន៍មាតាបិតាឱ្យបញ្ជូនកូនទៅរៀនឱ្យបានទៀងទាត់ ស្ថិតនៅកម្រិតខ្ពស់ពីព្រោះអាជ្ញាធរទាំងអស់យល់ពីតម្លៃនៃការអប់រំ ហើយថែមទាំងបានចូលរួមធ្វើការផ្សព្វផ្សាយដល់ប្រជាជនក្នុងមូលដ្ឋានរបស់ខ្លួនឱ្យបញ្ជូនកូនទៅរៀនឱ្យបានទៀងទាត់ទៀតផង។ ការចូលរួមរបស់អាជ្ញាធរនេះពិតជាមានសារៈសំខាន់យ៉ាងខ្លាំងណាស់ ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សពីព្រោះពេលសិស្សបានទៅរៀនទៀងទាត់គ្រប់គ្រាន់ ហើយនោះសិស្សនឹងមានចំណេះដឹងគ្រប់គ្រាន់ហើយការប្រឡងក៏ទទួលបានលទ្ធផលល្អដែរ។ ម៉្យាងទៀតសូចនាករដែលបានលើកឡើងថា អាជ្ញាធរចូលរួមលុបបំបាត់បាតុភាពមិនល្អជុំវិញសាលា (គ្រឿងញៀន ល្បែងស៊ីសង...) ក៏កាន់តែល្អថែមទៀត ពីព្រោះបានធ្វើឱ្យសហគមន៍ មានភាពល្អ គ្មានល្បែងស៊ីសង និងអំពើមិនល្អផ្សេងៗដែលស្របជាមួយគោលនយោបាយភូមិឃុំមានសុវត្ថិភាព

ដែលដាក់ចេញដោយរាជរដ្ឋាភិបាល។ មួយវិញទៀត អាជ្ញាធរក៏បានចូលរួមធ្វើផែនការអភិវឌ្ឍសាលារៀនផងដែរ ដោយស្ថិតនៅកម្រិតមធ្យម។ អាជ្ញាធរបានចូលរួមកម្មវិធីផ្សេងៗនៅក្នុងសាលាទាក់ទងការអប់រំស្ថិតនៅកម្រិតមធ្យមដែរ។ ដូចនេះការចូលរួមធ្វើផែនការអភិវឌ្ឍសាលារបស់អាជ្ញាធរដែនដី/គណៈកម្មការទ្រទ្រង់សាលាគឺស្ថិតនៅកម្រិតមធ្យម។

## ខ. ការកៀរគរកម្មវិធីអប់រំផ្សេងៗ

*តារាង 29 ៖ ការកៀរគរកម្មវិធីអប់រំផ្សេងៗរបស់អាជ្ញាធរ/គណៈកម្មការទ្រទ្រង់សាលា*

| ខ. ការកៀរគរកម្មវិធីអប់រំផ្សេងៗរបស់អាជ្ញាធរ/គណៈកម្មការទ្រទ្រង់សាលា | | | | | |
|---|---|---|---|---|---|
| ល.រ | បរិយាកាស | Mean | SD | កម្រិត | លំដាប់ |
| 13 | សហការណ៍ជាមួយក្រសួងផ្សេងៗដើម្បីផ្តល់ការអប់រំដល់សិស្សក្នុងសាលា( ច្បាប់ចរាចរ គ្រឿងញៀន...) | 3.40 | 0.68 | មធ្យម | 1 |
| 14 | ចូលរួមអភិវឌ្ឍសាលារៀន (សួនច្បារ រូបសំណាក់ផ្លូវបេតុងក្នុងសាលា បន្ទប់ទឹក...) | 2.70 | 0.57 | មធ្យម | 3 |
| 15 | ឃុំ/សង្កាត់លោក លោកស្រីមានផែនការទាក់ទង ការអប់រំ | 2.80 | 0.52 | មធ្យម | 2 |
| **សរុប** | | **2.96** | **0.37** | **មធ្យម** | |

តាមរយៈតារាងបានបង្ហាញថា ការកៀរគរកម្មវិធីអប់រំផ្សេងៗរបស់អាជ្ញាធរ/គណៈកម្មការទ្រទ្រង់សាលាតាមសូចនាករនីមួយៗឃើញថា សហការណ៍ជាមួយក្រសួងផ្សេងៗដើម្បីផ្តល់ការអប់រំ ដល់សិស្សក្នុងសាលា (ច្បាប់ចរាចរណ៍ គ្រឿងញៀន...) មានតម្លៃមធ្យម (Mean)=3.40, SD=0.68 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ1។ ចូលរួមអភិវឌ្ឍសាលារៀន( សួនច្បាររូបសំណាក់ផ្លូវបេតុងក្នុងសាលាបន្ទប់ទឹក...) មានតម្លៃមធ្យម (Mean)=2.70, SD=0.57 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ3។ ឃុំ/សង្កាត់ លោក លោកស្រីមានផែនការទាក់ទងការអប់រំ មានតម្លៃមធ្យម (Mean)=2.80, SD=0.52 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ2។ សរុបមកការកៀរគរកម្មវិធីអប់រំផ្សេងៗ របស់អាជ្ញាធរ/គណៈកម្មការទ្រទ្រង់សាលា ស្ថិតនៅកម្រិតមធ្យម ដែលមានតម្លៃមធ្យម (Mean)=2.96 និងSD=0.52។

តាមរយៈតារាងខាងលើបានបង្ហាញថា ក្នុងចំណោមសូចនាករទាំងអស់ មានសូចនាករដែលបានលើកឡើងថា សហការណ៍ជាមួយក្រសួងផ្សេងៗដើម្បីផ្តល់ការអប់រំដល់សិស្សក្នុងសាលា(ច្បាប់ចរាចរ គ្រឿងញៀន...) ស្ថិតនៅកម្រិតមធ្យម ពីព្រោះកម្មវិធីអប់រំទាំងនោះរៀបចំឡើងដោយក្រសួង ស្ថាប័នពាក់ព័ន្ធផ្ទាល់ ដោយគ្រាន់តែសហការណ៍ជាមួយអាជ្ញាធរដែនដី។ ការចូលរួមរបស់អាជ្ញាធរនេះ ពិតជាមានសារៈសំខាន់យ៉ាងខ្លាំងចំពោះចំណេះដឹងផ្សេងៗបន្ថែម ដូចជាទាក់ទងជំងឺអេដស៍ គ្រឿងញៀន ច្បាប់ចរាចរជាដើមសុទ្ធតែជាចំណេះដឹងល្អៗត្រូវរៀនដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។ ចំណែកឯការចូលរួមអភិវឌ្ឍសាលារៀនគឺស្ថិតនៅកម្រិតមធ្យមដោយពួកគាត់បានជួយជាកម្លាំង និងថវិកា តាមលទ្ធភាពក្នុងការជួសជុល កែលម្អបរិស្ថានសាលា។ ដូចនេះការកៀរគរកម្មវិធីអប់រំផ្សេងៗរបស់អាជ្ញាធរ/គណៈកម្មការទ្រទ្រង់សាលាដើម្បីចូលរួមលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស គឺស្ថិតនៅកម្រិតមធ្យម។

**ផ្នែកទី៣៖ អំពីទំនាក់ទំនងរបស់អាជ្ញាធរ/គណៈកម្មការទ្រទ្រង់សាលា**

*តារាង 30 ៖ ទំនាក់ទំនងរបស់អាជ្ញាធរ/គណៈកម្មការទ្រទ្រង់សាលា*

| ការទំនាក់ទំនងរបស់អាជ្ញាធរ/គណៈកម្មការទ្រទ្រង់សាលា | | | | | |
|---|---|---|---|---|---|
| ល.រ | បរិយាកាស | Mean | SD | កម្រិត | លំដាប់ |
| 16 | មានភាពងាយស្រួលក្នុងការទំនាក់ទំនងជាមួយគ្រូៗនិងនាយកសាលា | 3.85 | 0.36 | ខ្ពស់ | 1 |
| 17 | ទំនាក់ទំនងល្អជាគ្រូៗនិងនាយកសាលាដើម្បីដឹងពីការសិក្សា និងព័ត៌មានផ្សេងៗរបស់សិស្ស(កូន) | 3.15 | 0.48 | មធ្យម | 2 |
| 18 | បានដឹងពីលទ្ធផលសិក្សារបស់សិស្ស(កូន) ប្រចាំខែ ឆមាស ឆ្នាំ | 2.90 | 0.44 | មធ្យម | 3 |
| **សរុប** | | **3.30** | **0.49** | **មធ្យម** | |

តាមរយៈតារាងបានបង្ហាញថា ទំនាក់ទំនងរបស់អាជ្ញាធរ/គណៈកម្មការទ្រទ្រង់សាលា តាមសូចនាករនីមួយៗឃើញថា មានភាពងាយស្រួលក្នុងការទំនាក់ទំនងជាគ្រូៗ និងនាយកសាលាមានតម្លៃ

មធ្យម (Mean)=3.85, SD=0.36 ស្ថិតនៅកម្រិតខ្ពស់ និងលំដាប់លេខ1។ ទំនាក់ទំនងល្អជាគ្រូៗនិងនាយក សាលាដើម្បីដឹងពីការសិក្សា និងព័ត៌មានផ្សេងៗរបស់សិស្ស (កូន) មានតម្លៃមធ្យម (Mean)=3.15 និង SD=0.48 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ2។ បានដឹងពីលទ្ធផលសិក្សារបស់សិស្ស (កូន) ប្រចាំខែ ឆមាស ឆ្នាំមានតម្លៃមធ្យម (Mean)=2.90, SD=0.44 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ3។ ដូចនេះការទំនាក់ទំនងរបស់អាជ្ញាធរ/គណៈកម្មការទ្រទ្រង់សាលា ស្ថិតនៅកម្រិតមធ្យម ដែលមានតម្លៃមធ្យម (Mean)=3.30 និងSD=0.49។

សរុបមកតាមរយៈតារាងខាងលើបានបង្ហាញថា ក្នុងចំណោមសូចនាករទាំងអស់ ដែលបានលើកឡើងមានសូចនាករមួយនិយាយពីអាជ្ញាធរ/គណៈកម្មការទ្រទ្រង់សាលា មានភាពងាយស្រួលក្នុងការទំនាក់ទំនងជាគ្រូៗនិងនាយកសាលាស្ថិតនៅកម្រិតខ្ពស់នេះសរបញ្ជាក់ឱ្យឃើញថាអាជ្ញាធរ/គណៈកម្មការទ្រទ្រង់សាលាពិតជាមានទំនាក់ទំនងល្អជាមួយគ្រូនិងនាយកសាលា។ ចំណែកឯសូចនាករផ្សេងទៀតនិយាយពីទំនាក់ទំនងដើម្បីដឹងពីការសិក្សា ព័ត៌មានផ្សេងៗ និងដឹងពីលទ្ធផលសិក្សារបស់កូន មានប្រចាំខែ ឆមាស និងឆ្នាំស្ថិតនៅកម្រិតមធ្យម ដោយពួកគាត់រវល់ធ្វើការ រកស៊ីផ្សេងៗ មិនសូវបានទាក់ទង សួរនាំពីការសិក្សារបស់កូន។ ជារួមការចូលរួមរបស់អាជ្ញាធរ/គណៈកម្មការទ្រទ្រង់សាលា ពិតជាមានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។ ដូចនេះការចូលរួមរបស់អាជ្ញាធរដែនដី / គណៈកម្មការទ្រទ្រង់សាលាក្នុងការទំនាក់ទំនងគឺស្ថិតនៅកម្រិតមធ្យម។

***តារាង 31៖ ការចូលរួមរបស់អាជ្ញាធរក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស***

| ការចូលរួមរបស់អាជ្ញាធរក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស | | | | | |
|---|---|---|---|---|---|
| ល.រ | បរិយាកាស | Mean | SD | កម្រិត | លំដាប់ |
| 1 | ការចូលរួមធ្វើផែនការអភិវឌ្ឍសាលា | 3.31 | 0.41 | មធ្យម | 1 |
| 2 | ការកៀរគរកម្មវិធីអប់រំផ្សេងៗ | 2.96 | 0.37 | មធ្យម | 3 |
| 3 | អំពីការទំនាក់ទំនង | 3.30 | 0.49 | មធ្យម | 2 |
| សរុប | | 3.19 | 0.19 | មធ្យម | |

តាមរយៈតារាងបានបង្ហាញថា កម្រិតនៃការចូលរួមរបស់អាជ្ញាធរក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សតាមសូចនាករនីមួយៗឃើញថា ការចូលរួមធ្វើផែនការអភិវឌ្ឍសាលា មានតម្លៃមធ្យម (Mean)=3.31, SD=0.41 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ1។ ការកៀរគរកម្មវិធីអប់រំផ្សេងៗ មានតម្លៃមធ្យម (Mean)=2.96, SD=0.37 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ3។ អំពីការទំនាក់ទំនង មានតម្លៃមធ្យម (Mean)=3.30, SD=0.49 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ2។ ដូចនេះកម្រិតនៃការចូលរួមរបស់អាជ្ញាធរក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ស្ថិតនៅកម្រិតមធ្យម ដែលមានតម្លៃមធ្យម (Mean)=3.19, SD=0.19។

សរុបមកតាមរយៈតារាងខាងលើបានបង្ហាញថា ក្នុងចំណោមសូចនាករទាំងអស់ ដែលបានលើកឡើងមានសូចនាករមួយនិយាយពីៈ ការចូលរួមធ្វើផែនការអភិវឌ្ឍសាលា ការកៀរគរកម្មវិធីអប់រំផ្សេងៗ និងការទំនាក់ទំនង ស្ថិតនៅកម្រិតមធ្យមដូចគ្នាដែលមានតម្លៃមធ្យមចន្លោះពី 2.96 , 3.30 , 3.3 នេះសរបញ្ជាក់ឱ្យឃើញថា ការចូលរួមរបស់អាជ្ញាធរ/គណៈកម្មការទ្រទ្រង់សាលាក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សស្ថិតនៅកម្រិតមធ្យម។ ដូចនេះកម្រិតនៃការចូលរួមរបស់អាជ្ញាធរក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សគឺស្ថិតនៅកម្រិតមធ្យម។

**ផ្នែកទី៤៖ បញ្ហាប្រឈមរបស់អាជ្ញាធរ**



*ក្រាប 3 ៖ បញ្ហាប្រឈមរបស់អាជ្ញាធរដែលមិនសូវបានចូលរួមក្នុងការសិក្សារបស់សិស្ស*

តាមរយៈក្រាប3 បញ្ហាប្រឈមរបស់អាជ្ញាធរដែលមិនសូវបានចូលរួមក្នុងការសិក្សារបស់សិស្ស ដែលបានចូលរួមបំពេញកម្រងសំណួរគឺ ជីវភាពគ្រួសារខ្វះខាត មានចំនួន១០ ស្មើ១២.៥០%។ រវល់ធ្វើការនិងរកស៊ី មានចំនួន១៥ ស្មើ១៨.៧៥%។ ចំណេះដឹងទាប មានចំនួន១១ ស្មើ១៣.៧៥%។ គ្មានជំនាញក្នុងការអប់រំមានចំនួន១០ ស្មើ១២.៥០%។ ឱ្យកូនទៅរៀននៅសាលា (គិតថាគ្រប់គ្រាន់ហើយ) មាន១៤ ស្មើ១៧.៥០%។ ឱ្យកូនជួយធ្វើការរក និងកិច្ចផ្ទះខ្លះៗ មានចំនួន៦ ស្មើ៧.៥%។ មិនមានពេលវេលាបង្រៀនកូន មានចំនួន៤ ស្មើ៥%។ មិនបានតាមដានការសិក្សាកូន មាន៦ ស្មើ៧.៥% និងផ្សេងៗ មានចំនួន៣ ស្មើ ៣.៧៥%។

សរុបមកបញ្ហាប្រឈមសំខាន់ៗរបស់អាជ្ញាធរមិនសូវបានចូលរួមក្នុងការសិក្សារបស់សិស្សមានដូចជារវល់ធ្វើការនិងរកស៊ី ដោយសារត្រូវធ្វើការងារស្នូលរបស់គាត់និងធ្វើស្រែ រួមទាំងការងារចិញ្ចឹមសត្វខ្លះដើម្បីជួយដល់ជីវភាពគ្រួសារ។ អាជ្ញាធរខ្លះគាត់គិតថាឱ្យកូនទៅរៀននៅសាលារៀន ជាមួយគ្រូគ្រប់គ្រាន់ហើយ ពីព្រោះនៅសាលាមានលោកគ្រូ អ្នកគ្រូដែលមានចំណេះដឹង បទពិសោធន៍អាចបង្រៀនកូនគាត់ចេះហើយ។ ចំណែកឯអ្នកខ្លះទៀតគិតថា ខំតែរកស៊ីឱ្យមានបាន ហើយឱ្យកូនខំទៅរៀននៅសាលា និងរៀនដោយខ្លួនឯង ដោយពួកគាត់មិនបានតានដានការសិក្សារបស់កូននោះទេ ម្យ៉ាងទៀតពួកគាត់និយាយថា គ្មានជំនាញក្នុងការអប់រំទេ ចឹងហើយគឺត្រូវបញ្ជូនកូនឱ្យទៅរៀនជាមួយគ្រូដែលមានជំនាញចំណេះដឹង និងបទពិសោធន៍ ទើបធ្វើឱ្យកូនរបស់ពួកគាត់ទទួលបានចំណេះដឹងពិតប្រាកដ។

***តារាង 32 ៖ ការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស***

| កម្រិតនៃការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស(កូន) | | | | | |
|---|---|---|---|---|---|
| ល.រ | បរិយាកាស | Mean | SD | កម្រិត | លំដាប់ |
| 1 | ការចូលរួមរបស់មាតាបិតាសិស្ស | 3.49 | 0.33 | មធ្យម | 1 |
| 2 | ការចូលរួមរបស់អាជ្ញាធរ | 3.19 | 0.19 | មធ្យម | 2 |
| សរុប | | 3.34 | 0.21 | មធ្យម | |

តាមរយៈតារាងបានបង្ហាញថា កម្រិតនៃការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស (កូន) បានបង្ហាញឱ្យឃើញថា ការចូលរួមរបស់មាតាបិតាសិស្សគឺ មានតម្លៃមធ្យម (Mean=3.51, SD=019 ស្ថិតនៅកម្រិតមធ្យមនិងលំដាប់លេខ១។ ចំណែកឯការចូលរួមរបស់អាជ្ញាធរមានតម្លៃមធ្យម (Mean)=3.19, SD=019 ស្ថិតនៅកម្រិតមធ្យម និងលំដាប់លេខ២។ សរុបមក ការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស (កូន) គឺស្ថិតនៅកម្រិតមធ្យម ដែលមានតម្លៃមធ្យម (Mean) = 3.34, SD = 0.21។

## សំយោគទិន្នន័យលទ្ធផលតាមក្រុមខសំណួរដែលបានរកឃើញ

*តាមរយៈលទ្ធផលនៃការស្រាវជ្រាវ ខាងលើបានបង្ហាញឱ្យឃើញថា៖ (តារាង 33 ៖ សង្ខេបទិន្នន័យ)*

១. ការចូលរួមរបស់នាយកសាលាក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សតាមផ្នែកនីមួយៗគឺ៖

| ប្រភេទនៃការគ្រប់គ្រង | កម្រិត | តម្លៃមធ្យម (Mean) | គម្លាតស្តង់ដា (SD) | ផ្សេងៗ |
|---|---|---|---|---|
| ការគ្រប់គ្រងផ្នែករដ្ឋបាល | ខ្ពស់ | 4.26 | 0.10 | ស្ថិតនៅក្នុងលំដាប់លេខ២ ក្នុងចំណោមសូចនាករទាំង៥ |
| ការគ្រប់គ្រងផ្នែកបុគ្គលិក | ខ្ពស់ | 4.30 | 0.10 | ស្ថិតនៅក្នុងលំដាប់លេខ១ ក្នុងចំណោមសូចនាករទាំង៥ |
| ការគ្រប់គ្រងផ្នែកបច្ចេកទេស | ខ្ពស់ | 3.94 | 0.19 | ស្ថិតនៅក្នុងលំដាប់លេខ៤ ក្នុងចំណោមសូចនាករទាំង៥ |
| ការគ្រប់គ្រងផ្នែកថវិកា | ខ្ពស់ | 4.24 | 0.07 | ស្ថិតនៅក្នុងលំដាប់លេខ៣ ក្នុងចំណោមសូចនាករទាំង៥ |
| ការទំនាក់ទំនង | ខ្ពស់ | 3.84 | 0.14 | ស្ថិតនៅក្នុងលំដាប់លេខ៥ ក្នុងចំណោមសូចនាករទាំង៥ |
| សរុបសេចក្តីមក | **ការចូលរួមរបស់នាយកក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស គឺស្ថិតនៅកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)=4.12 និងគម្លាត ស្តង់ដា (SD)=0.21។** | | | |

២. ការចូលរួមរបស់លោកគ្រូ អ្នកគ្រូក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សតាមផ្នែកនីមួយៗគឺៈ

| ប្រភេទនៃចូលរួមរបស់គ្រូ | កម្រិត | តម្លៃមធ្យម (Mean) | គម្លាតស្តង់ដា (SD) | ផ្សេងៗ |
|---|---|---|---|---|
| ការបង្រៀន | ខ្ពស់ | 3.97 | 0.36 | ស្ថិតនៅក្នុងលំដាប់លេខ២ក្នុងចំណោមសូចនាករទាំង៣ |
| ការលើកទឹកចិត្តសិស្ស | ខ្ពស់ | 3.99 | 0.24 | ស្ថិតនៅក្នុងលំដាប់លេខ១ក្នុងចំណោមសូចនាករទាំង៣ |
| ការទំនាក់ទំនង | ខ្ពស់ | 3.74 | 0.36 | ស្ថិតនៅក្នុងលំដាប់លេខ៣ ក្នុងចំណោមសូចនាករទាំង៣ |
| សរុបមក | ការចូលរួមរបស់លោកគ្រូ អ្នកគ្រូក្នុងការលើកកម្ពស់លទ្ធផលសិក្សា របស់សិស្ស គឺស្ថិតនៅកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)=3.90 និង គម្លាតស្តង់ដា (SD)=0.13។ | | | |

៣. ការខិតខំរៀនរបស់សិស្សដើម្បីទទួលបានលទ្ធផលល្អ

| ប្រភេទនៃការគ្រប់គ្រង | កម្រិត | តម្លៃមធ្យម (Mean) | គម្លាតស្តង់ដា(SD) | ផ្សេងៗ |
|---|---|---|---|---|
| កត្តាក្នុងខ្លួន | ខ្ពស់ | 3.51 | 0.36 | ស្ថិតនៅក្នុងលំដាប់លេខ៤ ក្នុងចំណោមសូចនាករទាំង៤ |
| កត្តាក្រៅខ្លួន (ការលើកទឹកចិត្តរបស់គ្រូ) | ខ្ពស់ | 3.71 | 0.37 | ស្ថិតនៅក្នុងលំដាប់លេខ១ក្នុងចំណោមសូចនាករទាំង៤ |
| កត្តាក្រៅខ្លួន(ការលើកទឹកចិត្តពីមាតាបិតា បងប្អូន និងមិត្តភក្តិ) | ខ្ពស់ | 3.56 | 0.56 | ស្ថិតនៅក្នុងលំដាប់លេខ៣ ក្នុងចំណោមសូចនាករទាំង៤ |
| ការទំនាក់ទំនងរបស់សិស្ស | ខ្ពស់ | 3.60 | 0.57 | ស្ថិតនៅក្នុងលំដាប់លេខ២ ក្នុងចំណោមសូចនាករទាំង៤ |
| សរុបមក | ការខិតខំរៀនរបស់សិស្សដើម្បីទទួលបានលទ្ធផលល្អ គឺស្ថិតនៅកម្រិត ខ្ពស់ ដែលមានតម្លៃមធ្យម(Mean)=3.90 និងគម្លាតស្តង់ដា (SD)=0.13។ | | | |

៤. ការចូលរួមរបស់មាតាបិតាក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សតាមផ្នែកនីមួយៗគឺៈ

| ប្រភេទនៃការចូលរួមរបស់មាតាបិតា | កម្រិត | តម្លៃមធ្យម (Mean) | គម្លាតស្តង់ដា (SD) | ផ្សេងៗ |
|---|---|---|---|---|
| ការតាមដានការសិក្សាកូន | ខ្ពស់ | 3.78 | 0.63 | ស្ថិតនៅក្នុងលំដាប់លេខ១ ក្នុងចំណោមសូចនាករទាំង៣ |
| ការផ្តល់ថវិកា និងការលើកទឹកចិត្តកូនរបស់មាតាបិតា | ខ្ពស់ | 3.65 | 0.42 | ស្ថិតនៅក្នុងលំដាប់លេខ២ ក្នុងចំណោមសូចនាករទាំង៣ |
| ការទំនាក់ទំនង(ជាមួយកូន លោកគ្រូ អ្នកគ្រូ នាយកសាលា និងសហគមន៍) | មធ្យម | 3.11 | 0.93 | ស្ថិតនៅក្នុងលំដាប់លេខ៣ ក្នុងចំណោមសូចនាករទាំង៣ |
| **សរុបមក** | **ការចូលរួមរបស់មាតាបិតាក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស គឺស្ថិតនៅកម្រិតមធ្យម ដែលមានតម្លៃមធ្យម (Mean)=3.49 និងគម្លាតស្តង់ដា (SD)=0.33។** | | | |

៥. ការចូលរួមរបស់អាជ្ញាធរក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស

| ប្រភេទនៃការចូលរួមរបស់អាជ្ញាធរដែនដី | កម្រិត | តម្លៃមធ្យម (Mean) | គម្លាតស្តង់ដា (SD) | ផ្សេងៗ |
|---|---|---|---|---|
| ការចូលរួមធ្វើផែនការអភិវឌ្ឍសាលា | មធ្យម | 3.31 | 0.41 | ស្ថិតនៅក្នុងលំដាប់លេខ១ក្នុងចំណោមសូចនាករទាំង៣ |
| ការកៀរគរកម្មវិធីអប់រំផ្សេងៗ | មធ្យម | 2.96 | 0.37 | ស្ថិតនៅក្នុងលំដាប់លេខ៣ ក្នុងចំណោមសូចនាករទាំង៣ |
| ការទំនាក់ទំនង | មធ្យម | 3.30 | 0.49 | ស្ថិតនៅក្នុងលំដាប់លេខ២ ក្នុងចំណោមសូចនាករទាំង៣ |
| **សរុបមក** | **ការចូលរួមរបស់អាជ្ញាធរក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស គឺស្ថិតនៅកម្រិតមធ្យម ដែលមានតម្លៃមធ្យម (Mean)=3.19 និងគម្លាតស្តង់ដា (SD)=0.19។** | | | |

## សរុបមកការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សៈ

- សរុបមកការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សគឺ **ស្ថិតនៅកម្រិតមធ្យម** ដែលមានតម្លៃមធ្យម (Mean)=3.34, SD=0.21

**បញ្ហាប្រឈមរបស់សហគមន៍ (មាតាបិតា និងអាជ្ញាធរ)ដែលពុំសូវបានចូលរួមក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សមានដូចជា៖**

- ❖ **បញ្ហាប្រឈមរបស់មាតាបិតា**




តាមរយៈក្រាបទាក់ទង បញ្ហាប្រឈមរបស់មាតាបិតាសិស្សមិនសូវបានចូលរួមក្នុងការសិក្សា របស់កូន ដែលបានចូលរួមបំពេញកម្រងសំណួរគឺ មិនសូវមានទាក់ទងជាមួយលោកគ្រូ អ្នកគ្រូ និងនាយក មានចំនួន១១.៦៦%។ ជីវភាពខ្វះខាតមានចំនួន១១.៦៦%។ រវល់ធ្វើការរកស៊ី មានចំនួន២២.៣៣%។ មានចំណេះដឹងទាបមានចំនួន១៥.៣៣%។ គ្មានជំនាញក្នុងការអប់រំ បង្រៀនកូនមានចំនួន១០%។ គិត ថាឱ្យកូនទៅរៀននៅសាលាគ្រប់គ្រាន់ហើយមានចំនួន១១.៣៣%។ឱ្យកូនជួយធ្វើការងារផ្ទះនិងការងាររកលុយមានចំនួន៣.៣៣%។ មិនមានពេលវេលាបង្រៀនកូនចំនួន៩.៣៣%។ មិនបានតាមដាន ការសិក្សាកូនមានចំនួន៥%។

❖ **បញ្ហាប្រឈមរបស់អាជ្ញាធរ**




តាមរយៈក្រាប បានបង្ហាញថាបញ្ហាប្រឈមរបស់អាជ្ញាធរដែលមិនសូវបានចូលរួមក្នុងលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សគឺ ជីវភាពគ្រួសារខ្វះខាត មានចំនួន១០ ស្មើ១២.៥០%។ រវល់ធ្វើការ និងរកស៊ី មានចំនួន១៥ ស្មើ១៨.៧៥%។ ចំណេះដឹងទាប មានចំនួន១១ ស្មើ១៣.៧៥%។ គ្មានជំនាញ និងវិធីសាស្ត្រក្នុងការអប់រំមានចំនួន១០ ស្មើ១២.៥០%។ ឱ្យកូនទៅរៀននៅសាលា (គិតថាគ្រប់គ្រាន់ហើយ) មាន១៤ ស្មើ១៧.៥០%។ ឱ្យកូនជួយធ្វើការរកលុយ និងកិច្ចផ្ទះខ្លះៗ មានចំនួន៦ ស្មើ៧.៥%។ មិនមានពេលវេលាបង្រៀនកូន មានចំនួន៤ ស្មើ៥%។ មិនបានតាមដានការសិក្សាកូន មាន៦ ស្មើ៧.៥% និងផ្សេងៗមានចំនួន៣ ស្មើ៣.៧៥%។

## ៤.៤. ការពិភាក្សាចំពោះលទ្ធផល

### ៤.៤.១. គោលបំណងទី១

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវខាងលើ បានឆ្លើយតបទៅនឹងគោលបំណងនៃការស្រាវជ្រាវទីមួយគឺ សិក្សាពីកម្រិតនៃការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស

នៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅក្នុងខេត្តស្វាយរៀង។ តាមរយៈលទ្ធផលបានបង្ហាញឱ្យឃើញថា ការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស នៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅក្នុងខេត្តស្វាយរៀងស្ថិតនៅកម្រិតមធ្យម ដែលមានតម្លៃមធ្យម (Mean)=3.34 ហើយ SD=0.21។ យោងលទ្ធផលនៃការសិក្សានេះ គឺស្របតាមការសិក្សារបស់ លោកកាន់ ពុទ្ធី ដែលនិយាយអំពីការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលាបឋមសិក្សាស្ថិតនៅកម្រិតមធ្យម(កាន់ ពុទ្ធី.2015)។ ចំណែកឯការសិក្សាស្រាវជ្រាវរបស់ លោក សុខ ផល្លា ដែលស្រាវជ្រាវអំពីស្ថានភាពនៃការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំក្នុងខេត្តឧត្តរមានជ័យតាមលទ្ធផលឃើញថាស្ថានភាពនៃការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំក្នុងខេត្តឧត្តរមានជ័យ ស្ថិតនៅកម្រិតមធ្យម(សុខផល្លា,2018)។ ក្នុងការសិក្សាស្រាវជ្រាវពីការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស នៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅក្នុងខេត្តស្វាយរៀង ស្ថិតក្នុង**កម្រិតមធ្យម** ដោយផ្អែកទៅលើសូចនាករពីរធំៗ(២)គឺការចូលរួមរបស់មាតាបិតា និងការចូលរួមរបស់អាជ្ញាធរ ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។ ការចូលរួមរបស់មាតាបិតាមានដូចជា ការតាមដានការសិក្សារបស់កូន ស្ថិតនៅក្នុងកម្រិតខ្ពស់ មានមធ្យម (Mean)=3.71 ហើយការផ្តល់លុយ និងការលើកទឹកចិត្តកូនរបស់មាតាបិតា ស្ថិតនៅកម្រិតខ្ពស់ មានមធ្យម (Mean)=3.65។ ចំណែកឯការទំនាក់ទំនងរបស់មាតាបិតា (ជាមួយលោកគ្រូ អ្នកគ្រូ និងនាយកសាលា) ស្ថិតនៅក្នុងកម្រិតមធ្យម ដែលមានតម្លៃមធ្យម (Mean)=3.11។ សរុបជារួមការចូលរួមរបស់មាតាបិតា គឺស្ថិតនៅកម្រិត**មធ្យម** ដែលមានតម្លៃជាមធ្យម (Mean)=3.49។ ចំណែកឯការចូលរួមរបស់អាជ្ញាធរ មានដូចជា ការចូលរួមធ្វើផែនការអភិវឌ្ឍសាលា ស្ថិតនៅកម្រិតមធ្យម ដែលមានតម្លៃមធ្យម (Mean)=3.31 ហើយការកៀរគរកម្មវិធី អប់រំផ្សេងៗស្ថិតនៅកម្រិតមធ្យម ដែលមានតម្លៃ(Mean)=2.96។ ចំណែកឯការទំនាក់ទំនងក៏ស្ថិតនៅ កម្រិតមធ្យមដែរដែលមានតម្លៃមធ្យម (Mean)=3.30។ សរុបជារួម ការចូលរួមរបស់អាជ្ញាធរ ស្ថិតនៅ**កម្រិតមធ្យម** ដែលមានតម្លៃមធ្យម (Mean)=3.19។ ការចូលរួមរបស់សហគមន៍នេះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការជួយធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សបានល្អប្រសើរឡើង ពីព្រោះថាសហគមន៍

(មាតាបិតា អាណាព្យាបាល) ជាអ្នកដែលរស់នៅផ្ទាល់ជាមួយសិស្ស មានពេលវេលាគ្រប់គ្រាន់ និងផ្តល់នូវក្តីស្រឡាញ់ ការលើកទឹកចិត្ត ការយកចិត្តទុកដាក់ យ៉ាងខ្លាំងទៅលើសិស្សគ្រប់ៗគ្នា ជាហេតុធ្វើឱ្យសិស្សមានកម្លាំងចិត្ត មានចំណង់ចង់សិក្សារៀនសូត្រ អាចធ្វើឱ្យពួកគេទទួលបានលទ្ធផលល្អប្រសើរផងដែរ។

តាមរយៈសៀវភៅដែលនិពន្ធដោយឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដែលបានលើកឡើងថា លទ្ធផលសិក្សារបស់សិស្សចំណុះឱ្យកត្តាធំៗចំនួន៤គឺៈ ១. នាយកល្អ ២. គ្រូល្អ ៣. សិស្សល្អ ៤. មាតាបិតានិងសហគមន៍ល្អ(បណ្ឌិតសភាចារ្យហង់ជួន ណារ៉ុន 2020)។ ដូចនេះដើម្បីឱ្យសិស្សទទួលបានលទ្ធផលល្អក្នុងការសិក្សា គឺត្រូវមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធដែលមានដូចជា ការចូលរួមរបស់នាយកសាលា (គណៈគ្រប់គ្រងសាលា) ការចូលរួមរបស់លោកគ្រូ អ្នកគ្រូ ការខិតខំប្រឹងប្រែងរៀនរបស់សិស្ស និងការចូលរួមរបស់សហគមន៍ (មាតាបិតា និងអាណាព្យាបាល)។

ក្នុងការសិក្សាស្រាវជ្រាវនេះតាមលទ្ធផលបានបង្ហាញថា ការចូលរួមរបស់គណៈគ្រប់គ្រងសាលា (នាយកសាលា)ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុង ខេត្តស្វាយរៀង គឺមានតម្លៃមធ្យម(Mean)=4.12 ហើយ SD=0.21 ស្ថិតនៅកម្រិតខ្ពស់។ ការចូលរួមរបស់លោកគ្រូ អ្នកគ្រូ ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅ កម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀង គឺមានតម្លៃមធ្យម (Mean)=3.90 ហើយ SD=0.13 ស្ថិតនៅកម្រិតខ្ពស់។ ការខិតខំប្រឹងប្រែងរៀនរបស់សិស្សក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់ខ្លួននៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តស្វាយរៀង គឺមានតម្លៃមធ្យម (Mean)=3.59 ហើយ SD=0.08 ស្ថិតនៅកម្រិតខ្ពស់។ ចំណែកឯការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស នៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅក្នុងខេត្តស្វាយរៀង ស្ថិតនៅក្នុងកម្រិតមធ្យម ដែលមានតម្លៃមធ្យម (Mean)=3.34 ហើយ SD=0.21។

ភាពវិជ្ជមាននៃការចូលរួមក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិបានឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់ខ្ពស់ ពីគ្រប់ភាគីពាក់ព័ន្ធមានដូចជាៈ គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងសហគមន៍(មាតាបិតា អាណាព្យាបាល) ក៏ដូចជាភាគីពាក់ព័ន្ធផ្សេងទៀត។

### ៤.៤.២. គោលចំណោទទី២

តាមរយៈលទ្ធផលបានបង្ហាញថា៖ មានបញ្ហាប្រឈមជាច្រើនដែលនាំឱ្យសហគមន៍ (មាតាបិតា និងអាជ្ញាធរ) មិនសូវបានចូលរួមក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។ បញ្ហាទាំងនោះមានដូចជា៖ (១) បញ្ហាគ្រួសារមានជីវភាពខ្វះខាត ពីព្រោះថាមាតាបិតាសិស្សភាគច្រើនមានមុខរបរជាកសិករមានរហូត ដល់៤៧% ដែលជីវភាពរបស់ពួកគាត់ពឹងផ្អែកលើការធ្វើស្រែ ចិញ្ចឹមសត្វ និងធ្វើការងារផ្សេងបន្ទាប់បន្សំ ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ (២) បញ្ហារវល់ធ្វើការ និងរកស៊ី ដោយសារពួកគាត់ មួយចំនួនខិតខំធ្វើការ រកស៊ីច្រើន មិនមានពេលវេលាគ្រប់គ្រាន់សម្រាប់ជួយបង្រៀនកូនបន្ថែម ហើយការងាររបស់ពួកគាត់ជាការងារដែលប្រើកម្លាំងច្រើនក្នុងការធ្វើវាជាហេតុធ្វើឱ្យមានការហត់នឿយខ្លាំងពេលត្រឡប់មកផ្ទះវិញ តែចំណូលគ្រួសារមិនសូវច្រើនឡើយ (៣) បញ្ហាប្រឈមមួយទៀតនោះគឺ មាតាបិតាខ្លះគិតថាឱ្យកូនទៅរៀន នៅសាលាគឺគ្រប់គ្រាន់ហើយ ពីព្រោះថាពួកគាត់រវល់រកស៊ី ចិញ្ចឹមគ្រួសារ ណាមួយពួកគាត់មិនសូវបានយល់ពីតម្លៃនៃការចូលរួមរបស់គាត់ក្នុងការអប់រំ ណែនាំកូនឡើយដោយសារពួកគាត់ គិតថានៅសាលាជា ប្រភពនៃចំណេះដឹងដែលមាននាយកសាលា លោកគ្រូ អ្នកគ្រូ មានចំណេះដឹង ជំនាញបទពិសោធន៍ល្អៗ ជាច្រើនអាចបង្រៀនកូនគាត់ឱ្យមានចំណេះដឹង សីលធម៌ សុជីវធម៌និងចេះរស់នៅក្នុងសង្គមបានយ៉ាងល្អ (៤) បញ្ហាប្រឈមម្យ៉ាងទៀតនោះគឺពួកគាត់គ្មានជំនាញក្នុងការអប់រំកូន ដោយហេតុថាគាត់មានមុខរបរ និងការរកស៊ីផ្សេងៗទៅតាមជំនាញរៀងៗខ្លួន មិនសូវបានដឹងពីវិធីសាស្ត្រក្នុងការអប់រំណែនាំកូនដែលមានប្រសិទ្ធភាព ហើយអ្នកខ្លះក៏មិនបានរៀនបានខ្ពង់ខ្ពស់ដែរ (៥) បញ្ហាប្រឈមនោះគឺមាតាបិតាសិស្សមួយចំនួន មានចំណេះដឹងទាប (២៨%រៀនត្រឹមកម្រិតបឋមសិក្សា និង៣៧%ត្រឹមកម្រិតអនុវិទ្យាល័យ) ដែលជាឧបសគ្គ ក្នុងការចូលរួមណែនាំ និងជួយពន្យល់មេរៀន ឬលំហាត់កិច្ចការផ្ទះរបស់កូន ដែលគ្រូបានដាក់ឱ្យធ្វើ ហើយពួកគាត់មិនអាចជួយបង្រៀនណែនាំកូនដែលសិក្សានៅថ្នាក់ខ្ពស់ជាងខ្លួនបាន។

# ជំពូក៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងលើកឡើងពីសេចក្តីសន្និដ្ឋាន និងសំណូមពរ ព្រមទាំងលើកឡើងពីអនុសាសន៍មួយចំនួន ពាក់ព័ន្ធទៅនឹងការចូលរួមរបស់សហគមន៍ ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀង។

## ៥.១. សេចក្តីសន្និដ្ឋាន

យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវយើងអាចសន្និដ្ឋានបានថា ការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស នៅមធ្យមសិក្សាទុតិយភូមិក្នុង ខេត្តស្វាយរៀង គឺស្ថិតនៅក្នុងកម្រិតមធ្យម ដែលមានតម្លៃមធ្យម (Mean)=3.34 ហើយគម្លាតស្តង់ដា (SD)=0.21។ ការចូលរួមរបស់សហគមន៍នេះដោយផ្អែកទៅលើផ្នែកធំៗ២ដែលតំណាងឱ្យសហគមន៍ គឺការចូលរួមរបស់មាតាបិតា និងការចូលរួមរបស់អាជ្ញាធរ ក្នុងការលើកកម្ពស់លទ្ធផលសិក្សា របស់សិស្ស។ ការចូលរួមរបស់មាតាបិតាមានដូចជា ការតាមដានការសិក្សារបស់កូន ស្ថិតក្នុងកម្រិតខ្ពស់ មានតម្លៃមធ្យម (Mean)=3.71 ហើយការផ្តល់លុយនិងការលើកទឹកចិត្តកូនរបស់មាតាបិតាស្ថិតនៅ កម្រិតខ្ពស់ មានតម្លៃមធ្យម(Mean)=3.65 ។ ចំណែកឯការទំនាក់ទំនង របស់មាតាបិតា (ជាមួយលោក គ្រូ អ្នកគ្រូ និងនាយកសាលា) ស្ថិតនៅក្នុងកម្រិតមធ្យម ដែលមានតម្លៃមធ្យម (Mean)=3.11។ សរុបជារួម ការចូលរួមរបស់មាតាបិតា គឺស្ថិតនៅកម្រិតមធ្យម ដែលមានតម្លៃមធ្យម (Mean)=3.49។ ចំណែកឯការចូលរួមរបស់អាជ្ញាធរមានដូចជា ការចូលរួមធ្វើផែនការអភិវឌ្ឍសាលា ស្ថិតនៅក្នុងកម្រិតមធ្យម ដែលមានតម្លៃមធ្យម (Mean)=3.31 ហើយការកៀរគរកម្មវិធីអប់រំផ្សេងៗ ស្ថិតនៅកម្រិតមធ្យម ដែលមានតម្លៃ មធ្យម (Mean)=2.96។ ចំណែកឯការទំនាក់ទំនងក៏ស្ថិតនៅកម្រិតមធ្យមដែរ ដែលមានតម្លៃមធ្យម (Mean)=3.30។ សរុបជារួមការចូលរួមរបស់អាជ្ញាធរគឺស្ថិតនៅកម្រិតមធ្យម ដែលមានតម្លៃជាមធ្យម (Mean)=3.19។

ដើម្បីឱ្យសិស្សទទួលបានលទ្ធផលល្អប្រសើរក្នុងការសិក្សា គឺត្រូវមានការចូលរួមពីគ្រប់ភាគី

ពាក់ព័ន្ធដែលមានដូចជា៖ ការចូលរួមរបស់នាយកសាលា(គណៈគ្រប់គ្រង) ការចូលរួមរបស់លោកគ្រូអ្នកគ្រូ ការខិតខំប្រឹងប្រែងរៀនរបស់សិស្ស និងការចូលរួមរបស់សហគមន៍(មាតាបិតា និងអាជ្ញាធរ)។

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវបង្ហាញថាការចូលរួមរបស់គណៈគ្រប់គ្រងសាលា (នាយកសាលា) ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅ កម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀង គឺស្ថិតនៅ**កម្រិតខ្ពស់** ដែលមានតម្លៃមធ្យម (Mean)=4.12 ហើយ SD=0.21។ ការចូលរួមរបស់នាយក សាលាក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សដោយផ្អែកទៅលើ៥ផ្នែកគឺ (១) ការគ្រប់គ្រងផ្នែករដ្ឋបាល ស្ថិតនៅកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)=4.26។ (២) ការគ្រប់គ្រងផ្នែកបុគ្គលិក ស្ថិតនៅកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)=4.30។ (៣) ការគ្រប់គ្រងផ្នែកបច្ចេកទេស ស្ថិតនៅកម្រិតខ្ពស់ ដែលមានតម្លៃ(Mean)=3.94។ (៤) ការគ្រប់គ្រងផ្នែកថវិកា ស្ថិតនៅកម្រិតខ្ពស់ ដែលមានតម្លៃ (Mean)=4.24។ (៥) ការទំនាក់ទំនងស្ថិតនៅកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)=3.84។ ការចូលរួមរបស់លោកគ្រូ អ្នកគ្រូ ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀងគឺ ស្ថិតនៅ**កម្រិតខ្ពស់** ដែលមានតម្លៃមធ្យម(Mean)= 3.90 ហើយ SD=0.13។ ក្នុងការចូលរួមរបស់លោកគ្រូ អ្នកគ្រូក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សដោយផ្អែកទៅលើ៣ផ្នែកគឺ (១)ការបង្រៀនស្ថិតនៅកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)= 3.97។ (២) ការលើកទឹកចិត្តសិស្សស្ថិតនៅកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម(Mean)=3.99។ (៣)ការទំនាក់ទំនង ស្ថិតនៅកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)=3.74។ ការខិតខំប្រឹងប្រែងរៀនរបស់សិស្សក្នុងការលើកកម្ពស់ លទ្ធផលសិក្សារបស់ខ្លួននៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀង គឺស្ថិតនៅ**កម្រិតខ្ពស់** ដែលមានតម្លៃមធ្យម (Mean)=3.59។ ក្នុងនោះការខិតខំប្រឹងប្រែងរៀនរបស់សិស្សក្នុងការលើកកម្ពស់ លទ្ធផលសិក្សារបស់ខ្លួនដោយផ្អែកទៅលើ៤ផ្នែកគឺ(១) កត្តាខាងក្នុងខ្លួន ស្ថិតនៅកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)=3.51។ (2) កត្តាខាងក្រៅខ្លួន (ការលើកទឹកចិត្តរបស់គ្រូ) គឺស្ថិតនៅកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម(Mean) =3.71។ (៣) កត្តាខាងក្រៅខ្លួន (ការលើកទឹកចិត្ត

របស់មាតាបិតា បងប្អូន មិត្តភក្តិ)គឺស្ថិតនៅកម្រិតខ្ពស់ដែលមានតម្លៃមធ្យម (Mean)=3.56។ (៤) ការទំនាក់ទំនង របស់សិស្សគឺ ស្ថិតនៅកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម (Mean)=3.60។ ការចូលរួមរបស់សហគមន៍ (មាតាបិតា និង អាជ្ញាធរ) លោកគ្រូ អ្នកគ្រូ នាយកសាលា និងសិស្ស ខ្លួនឯង ពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សឱ្យបានល្អប្រសើរឡើង។

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវ អ្នកសិក្សាស្រាវជ្រាវបានរកឃើញនូវបញ្ហាប្រឈម ជាច្រើនដែលធ្វើឱ្យសហគមន៍ (មាតាបិតា និងអាជ្ញាធរ) មិនសូវបានចូលរួមក្នុង ការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។ បញ្ហាទាំងនោះមានដូចជា៖(១)បញ្ហាគ្រួសារមានជីវភាពខ្វះខាតពីព្រោះថាមាតាបិតាសិស្សភាគច្រើនមានមុខរបរជាកសិករមានរហូតដល់៤៧% ដែលជីវភាពរបស់ពួកគាត់ ពឹងផ្អែកលើ ការធ្វើស្រែ ចិញ្ចឹមសត្វ និងធ្វើការងារផ្សេងបន្ទាប់បន្សំដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។ (២) បញ្ហារវល់ធ្វើការ និងរកស៊ី ដោយសារពួកគាត់មួយចំនួនបានខិតខំធ្វើការរកស៊ីមិនទំនេរ មិនមានពេលវេលាច្រើន សម្រាប់ជួយបង្រៀនកូនបន្ថែម ហើយការងាររបស់ពួកគាត់ជាការងារដែលប្រើកម្លាំងច្រើនក្នុងការធ្វើវាជាហេតុធ្វើ ឱ្យមានការហត់នឿយខ្លាំងពេលត្រឡប់មកផ្ទះវិញ តែចំណូលគ្រួសារមិនសូវច្រើនឡើយ ចំពោះមាតាបិតា ជាកសិករ។ ចំណែកឯមាតាបិតាខ្លះទៀតពួកគាត់ជាអាជីវករ កម្មករ និងមន្ត្រីរាជការពួកគាត់ សុទ្ធតែ រវល់លើការងារ និងការរកស៊ីដូចគ្នា គ្រាន់តែរយៈពេលនៃការបំពេញការងារនោះវាខុសគ្នាពីប្រភេទមុខរបរទៅមុខរបរមួយតែប៉ុណ្ណោះ។ (៣) បញ្ហាប្រឈមមួយទៀតនោះគឺ មាតាបិតាខ្លះគិតថាឱ្យកូនទៅរៀន នៅសាលាគឺគ្រប់គ្រាន់ហើយ ពីព្រោះថាពួកគាត់រវល់រកស៊ី ចិញ្ចឹមគ្រួសារ ណាពួកគាត់មិនសូវបានយល់ ពីតម្លៃនៃការចូលរួមរបស់គាត់ក្នុងការអប់រំណែនាំកូនឡើយ ដោយសារពួកគាត់គិតថានៅសាលាជា ប្រភពនៃចំណេះដឹងដែលមាននាយកសាលា លោកគ្រូ អ្នកគ្រូ មានចំណេះដឹង ជំនាញ បទពិសោធន៍ ល្អៗជាច្រើនអាចបង្រៀនកូនគាត់ឱ្យមានចំណេះដឹង សីលធម៌ សុជីវធម៌និងចេះរស់នៅក្នុងសង្គម បានយ៉ាងល្អ។ (៤) បញ្ហាប្រឈមម្យ៉ាងទៀតនោះគឺពួកគាត់ គ្មានជំនាញក្នុងការអប់រំកូន ដោយហេតុថាគាត់ មានមុខរបរ និងការរកស៊ីផ្សេងៗទៅតាមជំនាញរៀងៗខ្លួន មិនសូវបានដឹងពីវិធីសាស្ត្រអប់រំណែនាំកូនដែលមាន

ប្រសិទភាព ហើយអ្នកខ្លះក៏មិនបានរៀនបានខ្ពង់ខ្ពស់ដែរ។ (៥) បញ្ហាប្រឈមនោះគឺមាតាបិតា សិស្សមួយចំនួនមានចំណេះដឹងទាប (២៨%រៀនត្រឹមកម្រិតបឋមសិក្សា និង៣៧%ត្រឹមកម្រិតអនុវិទ្យាល័យ) ដែលជាឧបសគ្គក្នុងការចូលរួមណែនាំ និងជួយពន្យល់មេរៀនឬលំហាត់កិច្ចការផ្ទះរបស់កូនដែលគ្រូបានដាក់ឱ្យធ្វើហើយពួកគាត់មិនអាចជួយបង្រៀនណែនាំកូនដែលសិក្សានៅថ្នាក់ខ្ពស់ជាងខ្លួនបាន។

សរុបមកបើតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀង អ្នកសិក្សាស្រាវជ្រាវបានធ្វើសេចក្តីសន្និដ្ឋានជារួមថា ការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀងគឺ**ស្ថិតនៅកម្រិតមធ្យម**។ ការចូលរួមរបស់សហគមន៍ **ស្ថិតនៅកម្រិតមធ្យម** នេះដោយសារមានបញ្ហាប្រឈមមួយចំនួនដែលធ្វើឱ្យពួកគាត់ មិនសូវបានចូលរួមក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សមានដូចជា៖គ្រួសារមានជីវភាពខ្វះខាត រវល់ធ្វើការ និងរកស៊ី មាតាបិតាសិស្សខ្លះគិតថាឱ្យកូនទៅរៀននៅសាលាគឺគ្រប់គ្រាន់ហើយ គ្មានជំនាញនិងវិធីសាស្ត្រក្នុងការអប់រំកូន និងមាតាបិតាសិស្សខ្លះមានចំណេះដឹងទាបជាដើម។

## ៥.២. សំណូមពរ

សព្វថ្ងៃវិស័យអប់រំ កំពុងត្រូវបានគ្រប់មជ្ឈដ្ឋានទូទៅចាប់អារម្មណ៍ និងយកចិត្តទុកដាក់យ៉ាងខ្លាំងជាពិសេសក្រោយកំណែទម្រង់វិស័យអប់រំតែម្តង ក្នុងនោះគុណភាពអប់រំជាកត្តាចម្បងជាងគេ ដែលត្រូវយកចិត្តទុកដាក់។ ទាក់ទងនឹងគុណភាពអប់រំនេះ ត្រូវមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធផ្សេងៗដូចជា៖ ការដឹកនាំគ្រប់គ្រងដំណើរការសាលារៀនរបស់នាយក លោកគ្រូ អ្នកគ្រូ សិស្សខ្លួនឯង និងសហគមន៍ជាកត្តាដែលក្រសួង មន្ទីរ អង្គភាពត្រូវគិតគូរនិងយកចិត្តទុកដាក់ឱ្យបានច្រើន។

តាមរយៈលទ្ធផលនៃការស្រាវជ្រាវ បទពិសោធន៍ផ្ទាល់ខ្លួន និងការអង្កេតទៅលើស្ថានភាពជាក់ស្តែង អ្នកស្រាវជ្រាវសូមសំណូមពរនូវចំណុចមួយចំនួនដូចខាងក្រោម៖

**១.ចំពោះសហគមន៍**

(១) សហគមន៍ត្រូវបង្កើនការចូលរួមក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ពីព្រោះថាតាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវឃើញថា ការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅមធ្យមសិក្សាទុតិយក្នុងខេត្តស្វាយរៀង ស្ថិតនៅកម្រិតមធ្យមនៅឡើង នេះហើយជាមូលហេតុដែលនាំឱ្យមានសំណូមពរនេះឡើង។ ការចូលរួមរបស់សហគមន៍ពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះការធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សល្អប្រសើរឡើង។

(២) សហគមន៍ត្រូវបន្តតាមដានការសិក្សារបស់កូនជាប្រចាំតាមរយៈការពិនិត្យមើលសៀវភៅតាមដាន ការសិក្សារបស់កូនដោយចុះហត្ថលេខាលើសៀវភៅដោយផ្ទាល់ ពីព្រោះលទ្ធផលសិក្សាប្រចាំខែ របស់សិស្សនៅសៀវភៅតាមដានការសិក្សាមានបញ្ជាក់ពីលទ្ធផលសិក្សា និងអវត្តមានរាល់ខែដែលសិស្សឈប់។

(៣) សហគមន៍ត្រូវបង្កើនការចូលរួមជាមូលនិធិសម្រាប់អភិវឌ្ឍសាលារៀន ព្រោះថវិកាដែលរដ្ឋ និងដៃគូអភិវឌ្ឍដ៏ទៃទៀតផ្តល់ជូនមិនទាន់គ្រប់គ្រាន់ទេ ពិសេសលើការកែលម្អបរិស្ថានសាលារៀន ពីព្រោះសាលារៀនជាមជ្ឈមណ្ឌលបណ្តុះបណ្តាល ចំណេះដឹង ជំនាញ សីលធម៌ជាដើម។ ម្យ៉ាងទៀតដើម្បីជាការទាក់ទាញនូវចំណាប់អារម្មណ៍សិស្សឱ្យចូលចិត្តមករៀននៅសាលាផងនោះ សាលារៀនចាំបាច់ត្រូវតែស្អាតមានសោភ័ណភាពល្អ មានអនាម័យ មានសម្ភារឧបទេសគ្រប់គ្រាន់។

**២.ចំពោះសាលារៀន**

សាលារៀនគួរតែមានសៀវភៅ (លេខទូរស័ព្ទ) ទំនាក់ទំនាក់ជាមួយសហគមន៍ដើម្បីជានា និងជំរុញការងារទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ឱ្យមានភាពសកម្មខ្លាំងឡើងប្រសើរជាងទុកតួនាទីនេះ ឱ្យគ្រូបន្ទុកថ្នាក់តែម្នាក់ឯង ពីព្រោះថាបើសៀវភៅទំនាក់ទំនងលេខទូរស័ព្ទទាំងសាលា និង សហគមន៍មាតាបិតាសិស្សអាចទំនាក់ទំនងគ្នាបានលឿន ទាន់ពេលវេលា ដើម្បីផ្តល់ព័ត៌មានពីការសិក្សា ការគោរពវិន័យ និងចំនួនអវត្តមានដល់មាតាបិតាសិស្សបានលឿនដល់ពួកគាត់ផ្ទាល់។

**៣.ចំពោះក្រសួងអប់រំ យុវជន និងកីឡា**

គួរតែបង្កើតជាគោលនយោបាយទាក់ទងតួនាទី ភារកិច្ច និងការចូលរួមសហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស និងការចូលរួមអភិវឌ្ឍសាលារៀន ហើយព្រមទាំងត្រូវផ្សព្វផ្សាយគោលនយោបាយឱ្យបានទូលំទូលាយដល់សហគមន៍ដើម្បីឱ្យពួកគាត់បានយល់និងចូលរួមអនុវត្តទាំងអស់គ្នា។

## ៥.៣. អនុសាសន៍សម្រាប់ការសិក្សាស្រាវជ្រាវបន្ត

ទាក់ទងនឹងប្រធានបទ **ការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិ**ខាងលើ ដោយសារតែវិសាលភាពធំទូលាយពេក អ្នកសិក្សាស្រាវជ្រាវ បានស្រាវជ្រាវ ផ្តោតសំខាន់តែខេត្តស្វាយរៀងមួយប៉ុណ្ណោះ។ លទ្ធផលនៃការសិក្សាស្រាវជ្រាវ និងទស្សនៈយល់ឃើញនានា មិនអាចឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែងនៅប្រទេសកម្ពុជាទាំងមូលបានទេ។

ដោយសារការរីកចម្រើននៃវិទ្យាសាស្ត្របច្ចេកវិទ្យាថ្មីៗ អ្នកសិក្សាជំនាន់ក្រោយៗ អាចសិក្សាស្រាវជ្រាវបន្តដើម្បីឱ្យលទ្ធផលដែលទទួលបានកាន់តែច្បាស់លាស់ជាក់លាក់ជាងនេះថែមទៀត ដោយត្រូវពង្រីកទំហំ វិសាលភាព និងសំណាកឱ្យបានគ្របដណ្តប់ទូលំទូលាយជាងនេះ។ ពិសេសសូមឱ្យអ្នកស្រាវជ្រាវធ្វើការស្រាវជ្រាវស្វែករកវិធីសាស្ត្រល្អៗ ក្នុងការទាក់ទាញសហគមន៍ ឱ្យចូលរួមឱ្យបានកាន់តែច្រើនដើម្បីឱ្យសិស្សទទួលបានលទ្ធផលកាន់តែល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំ។

# ឯកសារយោង

1. ក្រសួងអប់រំ យុវជន និងកីឡា (2009) *ឯកសារស្ដីពីទំនាក់ទំនងសាលារៀន និងសហគមន៍។*

2. ក្រសួងអប់រំ យុវជន និងកីឡា (2019) *ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣។*

3. ក្រសួងអប់រំ យុវជន និងកីឡា (2014) *ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨ ។*

4. ក្រសួងអប់រំ យុវជន និងកីឡា (2009) *ទំនាក់ទំនងរវាងសាលារៀន និងសហគមន៍។*

5. ក្រសួងអប់រំ យុវជន និងកីឡា (2016) ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ

6. បណ្ឌិតសភាចារ្យហង់ជួនណារ៉ុន (2020) *កំណែទម្រង់សាលារៀននៅកម្ពុជា។*

7. និក្ខេបបទ រ៉ុត សោភ័ណ្ឌ (2020) *កត្តានៃការជ្រើសរើសមុខវិជ្ជាវិទ្យាសាស្ត្រសង្គមរបស់សិស្ស នៅមធ្យមសិក្សា ទុតិយភូមិក្នុងខេត្តស្វាយរៀង។*

8. និក្ខេបបទ សុខ ផល្លា (2018) *ស្ថានភាពនៃការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំក្នុងខេត្តឧត្តរមានជ័យ។*

9. និក្ខេបបទ កាន់ ពុទ្ធី( 2015) *ការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលាបឋមសិក្សា។*

